New Zealand Food Safety
Ministry for Primary Industries
Manatū Ahu Matua

# បែបបទគំរូសម្រាប់ផែនការគ្រប់គ្រងចំណីអាហារ

## – គ្រាន់តែសម្រាប់ធានាឲ្យមានសុវត្ថិភាព & ភាពសមរម្យ

**លោកអ្នកអាចប្រើបែបបទគំរូនេះ ប្រសិនបើលោកអ្នកជា៖**

- ក្រុមហ៊ុនពាណិជ្ជកម្មលក់រាយចំណីអហាររាយដែលរៀបចំ ឬធ្វើ និងលក់ចំណីអាហារ - ដូចជាហាងលក់សាច់ ហាងលក់ត្រី ហាងលក់នំ (លក់រាយ) ហាងលក់ម្ហូបចំអិនស្រាប់ ឬផ្សារទំនើប
- ក្រុមហ៊ុនពាណិជ្ជកម្មសេវាកម្មអាហារ ដូចជាភោជនីយដ្ឋាន ហាងកាហ្វេ ហាងលក់អាហារសម្រាប់ខ្ចប់ទៅបរិភោគខាងក្រៅ ឬក្រុមហ៊ុនផ្គត់ផ្គង់អាហារនៅក្នុង ឬក្រៅហាង
- អ្នកបើកមជ្ឈមណ្ឌលថែទាំ រួមមានមន្ទីរពេទ្យ មន្ទីពេទ្យមើលថែអ្នកជំងឺក្នុងដំណាក់កាលចុងក្រោយ មណ្ឌលថែទាំមនុស្សចាស់ ពន្ធនាគារ និងគ្រឹស្ថានអប់រំនានា

**នេះជាឯកសារផ្នែកច្បាប់។**
**លោកអ្នកមិនត្រូវបន្ថែមនិតិវិធីផ្សេងទៀតចូលក្នុងផែនការនេះទេ។**

Khmer/Cambodian

S39-00002

# ខួបនៃថ្ងៃ


ការចាប់ផ្ដើម
ការបិទ
នៅពេលមានបញ្ហាអ្វីមួយ
ត្រូវអនុវត្តតាមដំណាក់កាលទាំងអស់
ការរៀបចំ
ការបម្រើ
ការធ្វើ + ការចំអិន

របៀបរៀបចំចាត់ចែង

# ខ្ទឹមសារ

## ប័ណ្ណពណ៌ខៀវចាស់៖ របៀបរៀបចំចាត់ចែង

ខួបនៃថ្ងៃ

ព័ត៌មានពាណិជ្ជកម្មលម្អិត

គម្រោងពាណិជ្ជកម្ម

ការពិនិត្យមើលថាផែនការមានដំណើរការល្អ

ការបណ្តុះបណ្តាល និងសមត្ថភាព

ការផ្គត់ផ្គង់ទឹក
ក្រុមហ៊ុនផ្គត់ផ្គង់ដែលបានចុះបញ្ជីរួច

ការផ្គត់ផ្គង់ទឹក៖
ទឹកពីដំបូល និងទឹកលើដី
ឬទឹកក្រោមដី

## ប័ណ្ណពណ៌ខៀវ៖ ការចាប់ផ្តើម

លាងដៃ

ការពារអាហារពីការចម្លងមេរោគពីបុគ្គលិក

ការរក្សាអាហារឲ្យត្រជាក់

ការពិនិត្យមើលសត្វចម្លងមេរោគ

## ប័ណ្ណពណ៌បៃតង៖ ការរៀបចំ

ការដាក់អាហារឲ្យនៅដាច់ពីគ្នា

ការរៀបចំអាហារឲ្យមានសុវត្ថិភាព

ការរកប្រភពផ្គត់ផ្គង់ ទទួល
និងរក្សាទុកអាហារ

## ប័ណ្ណពណ៌លឿង៖ ការធ្វើ + ការចំអិន

ការចំអិនអាហារ

ការចំអិនសាច់បសុបក្សី សាច់ម៉ត់
និងថ្លើមមាន់

ការបញ្ជាក់ឲ្យឃើញថាវិធីដែលអ្នកប្រើ
ដើម្បីសម្លាប់មេរោគមានប្រសិទ្ធិភាពគ្រប់ពេលវេលា

ការកំដៅអាហារឡើងវិញ

ការធ្វើឲ្យអាហារដែលចំអិនថ្មីៗឲ្យត្រជាក់

ការរំលាយទឹកកកពីអាហារ

ការប្រើសកម្មភាពទឹក អាស៊ីត ឬការធ្វើឲ្យក្តៅដើម្បីគ្រប់គ្រងមេរោគ

របៀបរៀបចំចាត់ចែង

# ខ្ទឹមសារ

### ប័ណ្ណពណ៌ទឹកក្រូច៖ ការបម្រើ + ការលក់

ការរក្សាអាហារឲ្យក្តៅ

ការដឹកជញ្ជូនអាហាររបស់អ្នក

ការដាក់តាំងបង្ហាញអាហារ និងអតិថិជនបម្រើដោយខ្លួនឯង

ការដឹងថាមានអ្វីនៅក្នុងអាហាររបស់អ្នក

ការខ្ចប់ និងដាក់ស្លាកអាហាររបស់លោកអ្នក

ការលក់អាហារទៅឲ្យអាជីវកម្មផ្សេង

### ប័ណ្ណពណ៌ស្វាយ៖ ការបិទហាង

ការលាងសម្អាតហាង

ការថែទាំឧបករណ៍ប្រើប្រាស់ និងហាង

### ប័ណ្ណពណ៌ក្រហម៖ ការដោះស្រាយបញ្ហា

នៅពេលមានបញ្ហាអ្វីមួយ

ការដោះស្រាយបណ្តឹងរបស់អតិថិជន

ការតាមដានអាហាររបស់អ្នក

ការប្រមូលអាហាររបស់លោកអ្នកត្រឡប់មកប់វិញ

### ប័ណ្ណពណ៌ទឹកសមុទ្រ៖ អ្នកឯកទេស

ការធ្វើស៊ុសស៊ី (sushi) ដោយប្រើបាយមានថែមជាតិជូរ

ការធ្វើទាខ្វៃតាមរបៀបចិន

ការធ្វើកេបាបសាច់ចៀម (Doner Kebabs)

ការចំអិនដែលប្រើវិធីចំអិនដោយដាក់អាហារក្នុងស្បោងគ្មានខ្យល់ ហើយចំអិនក្នុងឆ្នាំងមានទឹកទៅតាមសីតុណ្ហភាពត្រូវការ (sous vide)

ការរៀបចំសាច់ក្រហមសម្រាប់កិនឲ្យម៉ត់ និងការបម្រើសាច់ស្ទើរឆ្អិន ឬឆៅ

របៀបរៀបចំចាត់ចែង

# ព័ត៌មានពាណិជ្ជកម្មលម្អិត

**សូមបំពេញព័ត៌មានពាណិជ្ជកម្មលម្អិតរបស់អ្នកនៅខាងក្រោម**

| ព័ត៌មានពាណិជ្ជកម្មលម្អិត | |
|---|---|
| ឈ្មោះតាមផ្លូវច្បាប់ | |
| ឈ្មោះធ្វើអាជីវកម្ម | |
| សកម្មភាព [គូសយកចំណុចណាដែលសមស្រប] | |
| **សេវាអាហារ៖** ☐ បរិភោគក្នុងហាង ☐ យកបរិភោគខាងក្រៅហាង ☐ ផ្គត់ផ្គង់អាហារនៅក្នុងហាង ☐ ផ្គត់ផ្គង់អាហារនៅក្រៅហាង ☐ ផ្សេងៗ [សូមបញ្ជាក់]៖ ______ **ហាងលក់អាហារ៖** ☐ ហាងលក់សាច់ ☐ ហាងលក់អហារចំអិនសម្រាប់ ☐ ហាងលក់នំ ☐ ហាងលក់ត្រី ☐ ហាងលក់កសិផលស្រស់ ☐ ហាងលក់គ្រឿងទេស ☐ ដឹកជញ្ជូន/ប្រគល់ឲ្យ ☐ សេវាអាហារចល័ត ឬហាងលក់រាយ ☐ ដឹកជញ្ជូន/ការផ្គត់ផ្គង់ ☐ ផ្សេងៗ [សូមបញ្ជាក់]៖ ______ | |
| អាសយដ្ឋានផ្ញើសំបុត្រ | |
| ទូរស័ព្ទ | |
| អ៊ីម៉េល | |
| **ទីកន្លែង** | |
| **អាសយដ្ឋានផ្ទះ (1)** (អាគារដែលក្រុមហ៊ុនពាណិជ្ជកម្មអាហារធ្វើប្រតិបត្តិការ) | |
| ការផ្គត់ផ្គង់ទឹក | |

របៀបរៀបចំចាត់ចែង

| | |
|---|---|
| **តំបន់បន្ថែម** [បន្តនៅក្រដាសដោយឡែក ប្រសិនបើលោកអ្នកត្រូវការ ហើយភ្ជាប់មកជាមួយ] ខាងក្រោមនេះ សូមរាយឈ្មោះអាគារណាផ្សេងទៀតដែលប្រើប្រាស់ទាក់ទិននឹងក្រុមហ៊ុនពាណិជ្ជកម្មអាហារ (ឧទាហរណ៍ដូចជាអាគារប្រើប្រាស់សម្រាប់រក្សាទុក ឬរៀបចំអាហារ)។ សកម្មភាព និងតំបន់ទាំងនេះនឹងត្រូវគ្របដណ្តប់ដោយផែនការត្រួតពិនិត្យអាហារ (FCP) នេះ។ ប្រសិនបើទឹកត្រូវបានប្រើសម្រាប់គោលបំណងធ្វើអាហារ សូមកំណត់ប្រភពនៃការផ្គត់ផ្គង់ទឹក។ | |
| អាសយដ្ឋានផ្ទះ (2) | |
| សកម្មភាព/<br>ប្រភពផ្គត់ផ្គង់ទឹក | |
| អាសយដ្ឋានផ្ទះ (3) | |
| សកម្មភាព/<br>ប្រភពផ្គត់ផ្គង់ទឹក | |
| អាសយដ្ឋានផ្ទះ (4) | |
| សកម្មភាព/<br>ប្រភពផ្គត់ផ្គង់ទឹក | |
| **អ្នកគ្រប់គ្រងជំនួញ៖** អ្នកគ្រប់គ្រងជំនួញគឺជាម្ចាស់ ឬមនុស្សផ្សេងដែលកាន់កាប់ក្រុមហ៊ុនពាណិជ្ជកម្មអាហារ។ ប្រសិនបើផែនការត្រួតពិនិត្យអាហារអនុវត្តចំពោះក្រុមហ៊ុនពាណិជ្ជកម្មអាហារច្រើនជាងមួយ អ្នកធ្វើប្រតិបត្តិការពាណិជ្ជកម្មគឺជាអ្នកទទួលខុសត្រូវសម្រាប់ផែនការត្រួតពិនិត្យអាហារ* | |
| ឈ្មោះ | |
| អាសយដ្ឋានពិតប្រាកដ<br>(ក្រុមហ៊ុនពាណិជ្ជកម្ម<br>ឬលំនៅដ្ឋាន) | |
| ទូរស័ព្ទ | |
| អ៊ីម៉េល | |

| ***អ្នកគ្រប់គ្រងក្រុមហ៊ុនពាណិជ្ជកម្មអាហារនិមួយៗ** (ប្រសិនបើផែនការអនុវត្តចំពោះក្រុមហ៊ុនពាណិជ្ជកម្មអាហារច្រើនជាងមួយ) សូមថែមជួរបន្ថែមតាមការចាំបាច់។ | |
|---|---|
| ឈ្មោះ | |
| អាសយដ្ឋានពិតប្រាកដ (ក្រុមហ៊ុនពាណិជ្ជកម្ម ឬលំនៅដ្ឋាន) | |
| ទូរស័ព្ទ | |
| អ៊ីម៉េល | |

| **អ្នកគ្រប់គ្រងប្រចាំថ្ងៃ** [សូមសរសេរ 'ដូចខាងលើ' ប្រសិនបើអ្នកគ្រប់គ្រងប្រចាំថ្ងៃជាអ្នកគ្រប់គ្រងជំនួញ] អ្នកគ្រប់គ្រងប្រចាំថ្ងៃគឺជាអ្នកដែលមានការទទួលខុសត្រូវទូទៅដើម្បីធានាថាផែនការត្រួតពិនិត្យអាហារត្រូវបានតាមដាន និងពិនិត្យបានសមស្រប ហើយបំពេញកំណត់ត្រាចប់សព្វគ្រប់ កំណត់ត្រា និងផែនការរបស់អ្នកត្រូវរក្សាទុកយ៉ាងហោចណាស់រយៈពេល 4ឆ្នាំ។ កំណត់ត្រាទាំងអស់ត្រូវតែសរសេរជាភាសាអង់គ្លេស ហើយមានលក្ខណៈងាយស្រួលអាន។ កំណត់ត្រាទាំងអស់ត្រូវតែដាក់បញ្ចូលកាលបរិច្ឆេទ និងឈ្មោះអ្នកដែលបំពេញកិច្ចការ។ | |
|---|---|
| ឈ្មោះ និង/ឬតួនាទី | |
| ទូរស័ព្ទ | |

| **អាជ្ញាធរចុះបញ្ជី** (អាជ្ញាធរនេះនឹងក្លាយជាក្រុមប្រឹក្សាប្រចាំតំបន់របស់លោកអ្នកលុះត្រាតែផែនការត្រួតពិនិត្យអាហាររបស់លោកអ្នកគ្របដណ្ដប់អាគារដែលមានទីតាំងនៅក្នុងយុត្តាធិការរបស់ក្រុមប្រឹក្សាច្រើនជាងមួយ ឬមានអ្នកផ្ទៀងផ្ទាត់ជាភាគីទីបី ដែលក្នុងករណីនេះក្រសួងឧស្សាហកម្មវត្ថុធាតុដើមនឹងក្លាយជាអាជ្ញាធរចុះបញ្ជីវិញ | |
|---|---|
| អាជ្ញាធរចុះបញ្ជី | ☐ ក្រសួងឧស្សាហកម្មវត្ថុធាតុដើម<br>☐ ក្រុមប្រឹក្សា<br>[ឈ្មោះក្រុមប្រឹក្សា]: ________ |
| អ្នកទាក់ទង | |
| អាសយដ្ឋាន | |
| ទូរស័ព្ទ | |
| អ៊ីម៉េល | |
| **អ្នកផ្ទៀងផ្ទាត់** (ប្រសិនបើមិនមែនជាក្រុមប្រឹក្សាប្រចាំតំបន់ទេ) | |
| ទីភ្នាក់ងារផ្ទៀងផ្ទាត់ | |
| អ្នកទាក់ទង | |
| អាសយដ្ឋាន | |
| ទូរស័ព្ទ | |
| អ៊ីម៉េល | |

# គម្រោងក្រុមហ៊ុនពាណិជ្ជកម្ម

លោកអ្នកត្រូវធានាឲ្យបានថាគំរូប្លង់ និងទីកន្លែងរបស់ក្រុមហ៊ុនពាណិជ្ជកម្មអាហាររបស់លោកអ្នក អនុញ្ញាតឲ្យលោកអ្នកធ្វើអាហារមានសុវត្ថិភាព និងសមរម្យ។

- លោកអ្នកត្រូវគូរផែនទី និងផែនការនៅខាងក្នុងអាគារដែលរាប់បញ្ចូល៖
  - អាគាររបស់លោកអ្នក
  - អាគារដែលនៅជុំវិញវា
  - អ្វីដែលកើតមានឡើងនៅកន្លែងផ្សេងៗគ្នានៅលើផែនទីរបស់លោកអ្នក ដោយរួមមានកន្លែងរៀបចំអាហាររបស់លោកអ្នក (ឧទាហរណ៍ដូចជា ចង្ក្រានបាយរបស់លោកអ្នក)
  - អ្វីដែលកើតមាននៅក្នុងអាគាររបស់លោកអ្នក ដោយរួមមានសកម្មភាពក្រៅពីការធ្វើអាហារ
  - អ្វីដែលកើតមាននៅកន្លែងផ្សេងៗនៃអាគារ
  - សកម្មភាពក្រៅពីការធ្វើអាហារមួយចំនួនដែលប្រព្រឹត្តឡើងនៅកន្លែងដូចគ្នា ឬអាគារជិតខាង/ផ្ទះដែលអាចប៉ះពាល់ដល់សុវត្ថិភាពអាហារអាចត្រូវដាក់បញ្ចូលក្នុងផែនទីនៃក្រុមហ៊ុនពាណិជ្ជកម្មរបស់លោកអ្នក។

របៀបរៀបចំចាត់ចែង

## គម្រោង — ខាងក្នុងក្រុមហ៊ុនពាណិជ្ជកម្ម

*គម្រោងនេះអាចជាប្លង់គូរដោយដៃ ឬរូបថត។

របៀបរៀបចំចាត់ចែង

## គម្រោង — ខាងក្រៅក្រុមហ៊ុនពាណិជ្ជកម្ម

*គម្រោងនេះអាចជាប្លង់គូរដោយដៃ ឬរូបថត។

# ការគ្រប់គ្រងហានិភ័យនៅជិតក្រុមហ៊ុនពាណិជ្ជកម្មរបស់លោកអ្នក

សូមកត់ទុកនៅទីនេះនូវសកម្មភាពក្រៅពីការធ្វើអាហារដែលធ្វើប្រតិបត្តិការនៅក្នុងអាគាររបស់លោកអ្នក ឬអាគារ/ផ្ទះជិតខាងដែលអាចប៉ះពាល់ដល់សុវត្ថិភាពអាហារ ឬភាពសមរម្យនៅក្នុងក្រុមហ៊ុនពាណិជ្ជកម្មរបស់លោកអ្នក ហើយនិងអ្វីផ្សេងទៀតដែលលោកអ្នកធ្វើដើម្បីគ្រប់គ្រងហានិភ័យ។

| ហានិភ័យចំពោះសុវត្ថិភាពអាហារ | តើយើងគ្រប់គ្រងហានិភ័យយ៉ាងដូចម្តេច? |
| --- | --- |
| ឧទាហរណ៍៖ ធូលីហុយចេញពីមជ្ឈមណ្ឌលសួនឧទ្យាននៅជិតនោះ (ជាពិសេសមកពីគំនរជីកំប៉ុស្ត) អាចនាំមកនូវមេរោគដែលឆ្លងដល់អាហារ និងធ្វើឲ្យវាគ្មានសុវត្ថិភាព។ | ឧទាហរណ៍៖ រក្សាបង្អួច/ទ្វារបិទជិតជានិច្ចនៅផ្នែកនៃអាគារបែរទៅខាងមជ្ឈមណ្ឌលសួនឧទ្យាន។ ការរៀបចំអាហារដែលអាចបរិភោគបានភ្លាមៗ និងកន្លែងផ្តល់សេវាអាហារឲ្យស្ថិតនៅឆ្ងាយពីច្រកចូលនៃកន្លែងផ្តល់សេវាកម្ម (ដែលនៅផ្នែកនៃអាគារបែរទៅខាងសួនឧទ្យាន) តាមដែលអាចធ្វើទៅបាន។ |
| | |
| | |
| | |

របៀបរៀបចំចាត់ចែង

# ការពិនិត្យមើលថាផែនការមានដំណើរការល្អ

K

ដឹង

## តើអ្នកត្រូវដឹងអ្វីខ្លះ?

- វាជាការទទួលខុសត្រូវរបស់អ្នកដើម្បីពិនិត្យមើលថាសុវត្ថិភាព និងភាពសមស្របនៃអាហារមានការគ្រប់គ្រងបានល្អនៅក្នុងអាជីវកម្មរបស់អ្នក។
- អ្វីដែលត្រូវពិនិត្យ ហើយត្រូវពិនិត្យមើលញឹកញាប់ប៉ុណ្ណាអាស្រ័យទៅលើផលប៉ះពាល់នៃអ្វីមួយដែលមានបញ្ហានៅក្នុងអាជីវកម្មរបស់អ្នក។ អ្នកគួរពិនិត្យមើលរបស់ដែលសំខាន់ជាងគេបំផុត (ឧទាហរណ៍ដូចជាឧបករណ៍ស្ទង់សីតុណ្ហភាព) ឲ្យមានញឹកញាប់បំផុត។
- សវនកម្មដែលធ្វើឡើងដោយក្រុមហ៊ុនមួយដែលអ្នកផ្គត់ផ្គង់ក៏ចាត់ទុកថាជាការពិនិត្យផ្ទៃក្នុងមួយដែរ ប៉ុន្តែអ្នកនៅតែត្រូវធ្វើការពិនិត្យឲ្យបានទៀតទាត់ដោយខ្លួនអ្នកផ្ទាល់។
- អ្នកគួរពិនិត្យមើល៖
    - ថាបុគ្គលិកធ្វើអ្វីដែលពួកគេត្រូវធ្វើ
    - បុគ្គលិកអនុវត្តតាមនីតិវិធីដែលអ្នកបានដាក់ឲ្យអនុវត្ត ហើយថាតើនីតិវិធីទាំងនេះមានប្រសិទ្ធភាពដែរឬទេ
    - ហាង និងឧបករណ៍របស់អ្នកមានលក្ខណៈសមស្របសម្រាប់សកម្មភាពផលិតអាហារនៅក្នុងអាជីវកម្មរបស់អ្នក។
- អ្នក ឬបុគ្គលិករបស់អ្នកម្នាក់ត្រូវតែធ្វើជាអ្នកផ្ទៀងផ្ទាត់ខាងក្នុងរបស់អ្នកផ្ទាល់ (ស្វ័យសវនករ)។

## ហេតុអ្វីបានជាស្វ័យសវនកម្មមានសារៈសំខាន់?

- អ្នកទទួលខុសត្រូវចំពោះអាជីវកម្មរបស់អ្នក ហើយនិងអាហារដែលអ្នកផលិត។ ប្រសិនបើអ្នករង់ចាំឲ្យអ្នកផ្សេងប្រាប់អ្នកថាមានបញ្ហាអ្វីមួយបានកើតមានឡើង នោះវាអាចធ្វើឲ្យអ្នកខាតបង់ថវិកាច្រើន ហើយអាហាររបស់អ្នកអាចធ្វើឲ្យមនុស្សឈឺ។

K

ដឹង

- ពិនិត្យមើលថាផែនការមានដំណើរការល្អ ដោយ (ឧទាហរណ៍)៖
  - ពិនិត្យមើលថាបុគ្គលិកអនុវត្តតាមនីតិវិធីស្តីពីសុវត្ថិភាពអាហារសំខាន់ៗ (ឧទាហរណ៍ដូចជា ការលាងដៃ ។ល។)
  - ការពិនិត្យមើលកំណត់ត្រាបំពេញរួច ហើយរក្សាទុកបានល្អ
  - ការពិនិត្យមើលកំណត់ត្រាដើម្បីពិនិត្យថាកិច្ចការនានាមានដំណើរការដូចការរំពឹងទុក
  - ការពិនិត្យឡើងវិញ ព័ត៌មានស្តីពី **'នៅពេលអ្វីមួយមានបញ្ហា'** និងពិនិត្យមើលជំហានដែលបានធ្វើដើម្បីទប់ស្កាត់បញ្ហាកុំឲ្យកើតឡើងម្តងទៀត
  - សួរសំណួរទាក់ទងនឹងសុវត្ថិភាពអាហារដល់បុគ្គលិក
  - ការប្រើប្រាស់ផ្នែក **'បង្ហាញ'** នៅក្នុងគំរូនេះដើម្បីសួរសំណួរដូចគ្នា ឬពិនិត្យមើលកិច្ចការដូចគ្នាដែលអ្នកផ្ទៀងផ្ទាត់នឹងសួរ ឬនឹងពិនិត្យមើល
  - ការធ្វើតេស្តបរិស្ថាន ឬអាហារដើម្បីរកមេរោគ ឬជាតិគីមីជាក់លាក់ ដើម្បីបង្ហាញថានីតិវិធីនានារបស់អ្នក (ឧទាហរណ៍ដូចជា ការសម្អាត និងអនាម័យ) មានប្រសិទ្ធភាព។

### កំណត់ត្រាខ្លះស្តីពីការធ្វើតេស្ត៖

- មានតម្រូវការជាក់លាក់សម្រាប់ធ្វើតេស្តនៅក្នុងស្ថានភាពមួយចំនួន (ឧទាហរណ៍ដូចជា ការផ្គត់ផ្គង់ទឹកដោយខ្លួនឯង)។ ក៏មានបទដ្ឋាននានាផងដែរស្តីអំពីកម្រិតជាក់លាក់សម្រាប់មេរោគ ឬជាតិគីមីនៅក្នុងក្រមស្តង់ដារអាហាររបស់ប្រទេសណូវែលហ្សីឡង់ និងអូស្ត្រាលី www.foodstandards.govt.nz/code/Pages/default.aspx។ កម្រិតមិនមែនមានន័យថាអ្នកត្រូវតែធ្វើតេស្តអាហាររកមេរោគ ឬជាតិគីមីនោះគ្រប់ពេលទេ។ ប្រសិនបើអ្នកគិតពីការប្រើប្រាស់ការជ្រើសរើសសំណាក និងការធ្វើតេស្តដើម្បីបង្ហាញថាផែនការរបស់អ្នកមានដំណើរការល្អ ការធ្វើបែបនេះមិនមែនជាការពិនិត្យមើលតែមួយដែលអ្នកធ្វើនោះទេ។ វាមិនអាចធ្វើតេស្តវិធីរបស់អ្នកដើម្បីឈានទៅសម្រេចឲ្យបាននូវសុវត្ថិភាពអាហារបានទេ។
- ការធ្វើតេស្តអាចជាឧបករណ៍មានប្រយោជន៍មួយ តែវាមានកម្រិត។ ប្រសិនបើឧទាហរណ៍ លទ្ធផលតេស្តរកឃើញមេរោគបង្កគ្រោះថ្នាក់ គឺអាចមានន័យថាផ្នែកខ្លះនៃដំណើរការរមិនប្រព្រឹត្តទៅបានល្អទេ។

**K**

**ដឹង**

- លទ្ធផលអវិជ្ជមានអាចមិនបង្ហាញថាផែនការរបស់អ្នកប្រព្រឹត្តទៅបានល្អឥតខ្ចោះនោះទេ (ឬថាអាហារមានសុវត្ថិភាពឡើយ)។ ជាពិសេស មេរោគជាធម្មតាមិនបែងចែកស្មើគ្នានៅក្នុងអាហារនោះទេ។ យើងអាចធ្វើតេស្តអាហារមួយចំនួន ហើយទទួលបានលទ្ធផលអវិជ្ជមាន នៅពេលផ្នែកមួយទៀតនៃអាហារក្នុងក្រុមដូចគ្នាមានមេរោគដែលបង្កការគ្រោះថ្នាក់កម្រិតខ្ពស់។
- ប្រសិនបើអ្នកចង់ដាក់បញ្ចូលការធ្វើតេស្តជាផ្នែកមួយនៃការពិនិត្យមើលរបស់អ្នក ជាញឹកញាប់ការធ្វើតេស្តបរិស្ថានមានប្រសិទ្ធភាពជាងការធ្វើតេស្តអាហារចុងក្រោយ។
- ប្រសិនបើអ្នកប្រើការជ្រើសរើសសំណាក និងការធ្វើតេស្តជាផ្នែកមួយនៃនីតិវិធីសម្រាប់ពិនិត្យ យើងផ្តល់អនុសាសន៍ថាអ្នកគួររកអ្នកជំនាញឲ្យធ្វើផែនការធ្វើតេស្ត។ ប្រសិនបើអ្នកមិនមានអ្នកជំនាញនៅក្នុងអាជីវកម្មរបស់អ្នកទេ ទីប្រឹក្សាអ្នកផ្ទៀងផ្ទាត់ ឬក៏ក្រសួងឧស្សាហកម្មវត្ថុធាតុដើមអាចផ្តល់ព័ត៌មានអំពីការតាក់តែងផែនការការជ្រើសរើសសំណាក និងការធ្វើតេស្ត។

**D**

**ធ្វើ**

## តើអ្នកត្រូវធ្វើអ្វីខ្លះ?

- អ្នកត្រូវរៀបចំនីតិវិធីនានាសម្រាប់ត្រួតពិនិត្យជាប្រចាំថាអ្នក និងបុគ្គលិករបស់អ្នកផលិតអាហារដែលមានសុវត្ថិភាព និងសមស្រប ហើយនិងឆ្លើយតបទៅនឹងតម្រូវការ និងការទទួលខុសត្រូវនានានៅក្នុង ***ច្បាប់ស្តីពីអាហារឆ្នាំ 2014***។
- អនុវត្តតាមនីតិវិធីស្តីពី **‘នៅពេលអ្វីមួយមានបញ្ហា’** ប្រសិនបើការពិនិត្យដោយខ្លួនឯងកំណត់រកឃើញកំហុស ឬសកម្មភាពដែលអាចធ្វើឲ្យអាហារគ្មានសុវត្ថិភាព ឬមិនសមស្រប។

**S**

**បង្ហាញ**

## តើអ្នកត្រូវបង្ហាញអ្វីខ្លះ?

- បង្ហាញអ្នកផ្ទៀងផ្ទាត់នូវ៖
  - វិធីដែលអ្នកពិនិត្យមើលឲ្យដឹងថាតើនីតិវិធីរបស់អ្នកមានដំណើរការល្អ
  - លទ្ធផលនៃការពិនិត្យនានាដែលអ្នកបានធ្វើ

របៀបរៀបចំចាត់ចែង

# ការបណ្តុះបណ្តាល និងសមត្ថភាព

K

ដឹង

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- បុគ្គលិកមានតម្រូវការបណ្តុះបណ្តាលផ្សេងៗគ្នា។ លោកអ្នកត្រូវតែដឹងថាតើការបណ្តុះបណ្តាលអ្វីដែលបុគ្គលិក និងភ្ញៀវត្រូវការដើម្បីសម្រេចឲ្យបាននូវអាហារមានសុវត្ថិភាព និងសមរម្យ។
- បុគ្គលិកនិងភ្ញៀវទាំងអស់ត្រូវតែយល់អំពីការបណ្តុះបណ្តាលដែលពួកគេទទួល។
- បុគ្គលិកទាំងអស់ត្រូវតែមានទំនុកចិត្តថាពួកគេដឹងច្បាស់នូវអ្វីដែលត្រូវធ្វើ និងអនុវត្តតាមផែនការដើម្បីធានាថាត្រូវផលិតអាហារដែលមានសុវត្ថិភាព និងសមរម្យ។

D

ធ្វើ

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

- ចាត់តាំងអ្នកណាម្នាក់ដែលទទួលខុសត្រូវដើម្បីធានាថាបុគ្គលិកអនុវត្តតាមផែនការ (គូសយកចំណុចសមស្រប)

  ☐ អ្នកគ្រប់គ្រងប្រចាំថ្ងៃ ឬ

  ☐ អ្នកមានសិទ្ធិសម្រេច ។

  ឈ្មោះ ______________________

- ☐ អ្នកគ្រប់គ្រងប្រចាំថ្ងៃ ឬ ☐ អ្នកមានសិទ្ធិសម្រេច (ជ្រើសយកចំណុចសមស្រប) ត្រូវធានាថាបុគ្គលិក និងភ្ញៀវទាំងអស់បានទទួលការបណ្តុះបណ្តាល ដើម្បីឲ្យពួកគេដឹងថាត្រូវធ្វើអ្វីដើម្បីឆ្លើយតបតាមបទដ្ឋានស្តីអំពី៖
  - ការលាងសម្អាតដៃ
  - ការស្លៀកសម្លៀកបំពាក់ស្អាត
  - ការរាយការណ៍នៅពេលមានជំងឺ
  - ការដោះស្រាយបញ្ហាអាហារដែលអាចធ្វើឲ្យមនុស្សឈឺ
  - ការលាងសម្អាត និងធ្វើអនាម័យ

D

ធ្វើ

- ការរក្សាអាហារឲ្យនៅដាច់ពីគ្នានៅក្នុងកន្លែងរៀបចំអាហារ (ដោយរួមមានការគ្រប់គ្រងអ្វីដែលបង្កឲ្យមានអាលែកហ្ស៊ី រក្សាអាហារឆៅ/មិនទាន់ចំអិនឲ្យឆ្ងាយពីអាហារឆ្អិន និងគ្រប់គ្រងជាតិគីមី និងថ្នាំពុល)
- និតិវិធីផ្សេងទៀតដែលជាក់លាក់សម្រាប់ក្រុមហ៊ុនពាណិជ្ជកម្មអាហាររបស់លោកអ្នក
- តើត្រូវធ្វើអ្វីខ្លះនៅពេលមានបញ្ហាអ្វីមួយ

- បណ្តុះបណ្តាលបុគ្គលិក៖
  - មុនពេលពួកគេចាប់ផ្តើមធ្វើការនៅក្នុងក្រុមហ៊ុនពាណិជ្ជកម្មអាហាររបស់លោកអ្នក
  - នៅពេលមានការដាក់ឲ្យប្រើប្រាស់ ឬកែប្រែនិតិវិធីណាមួយ។
- ភ្ញៀវទាំងអស់ (ឧទាហរណ៍អ្នកប្រគល់ទំនិញ អ្នកម៉ៅការ ។ល។) ត្រូវតែរក្សាអាហារឲ្យមានសុវត្ថិភាពក្នុងខណៈពួកគេស្ថិតក្នុងក្រុមហ៊ុនពាណិជ្ជកម្មអាហាររបស់លោកអ្នក។

S

បង្ហាញ

## តើអ្នកត្រូវការបង្ហាញអ្វីខ្លះ?

- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ៖
  - **កំណត់ត្រា** នៃវិធី និងពេលដែលបុគ្គលិកបានទទួលការបណ្តុះបណ្តាលឲ្យអនុវត្តតាមផែនការ។ រួមមាន៖
    - អ្នកណាខ្លះដែលបានទទួលការបណ្តុះបណ្តាល
    - ពេលណា
    - តើអ្នកបានគ្របដណ្តប់លើផ្នែកណានៃផែនការ
    - ហត្ថលេខាពីគ្រូបណ្តុះបណ្តាល និងសិក្ខាកាម។

រៀបរៀបចំចាត់ចែង

# ការផ្គត់ផ្គង់ទឹក ក្រុមហ៊ុនផ្គត់ផ្គង់ដែលចុះបញ្ជីរួច

**K**

ដឹង

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- ទឹកអាចនាំមកនូវមេរោគដែលមានគ្រោះថ្នាក់ និងជាតិគីមីដែលអាចធ្វើឲ្យមនុស្សឈឺ។ លោកអ្នកត្រូវតែប្រើទឹកស្អាត និងគ្មានមេរោគតែប៉ុណ្ណោះសម្រាប់រៀបចំអាហារ។
- ទឹកអាចមានមេរោគនៅពេលរក្សាទុកនៅក្នុងក្រុមហ៊ុន និងចែកចាយនៅជុំវិញកន្លែងផលិតអាហារ។
- លោកអ្នកត្រូវតែមានទឹកស្អាតគ្រប់គ្រាន់ដើម្បីលាងកន្លែងរៀបចំអាហាររបស់លោកអ្នក ឧបករណ៍ និងរបស់ប្រើប្រាស់ធ្វើអាហារ។
- លោកអ្នកត្រូវតែមានទឹកស្អាតសម្រាប់ឲ្យបុគ្គលិកលាងសំអាតដៃ។
- ទឹកអាចឆ្លងមេរោគនៅកន្លែងប្រភពផ្គត់ផ្គង់។
វាជាការចាំបាច់ត្រូវអនុវត្តតាមឱវាទរបស់ក្រុមប្រឹក្សាប្រចាំតំបន់របស់អ្នក។

**D**

ធ្វើ

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

- ផ្តល់ឈ្មោះក្រុមហ៊ុនផ្គត់ផ្គង់របស់អ្នកដែលបានចុះបញ្ជីរួច។

  ឈ្មោះក្រុមហ៊ុនផ្គត់ផ្គង់ ______________________________

- ជានិច្ចកាល ត្រូវប្រើទឹកដែលមានសុវត្ថិភាពសម្រាប់រៀបចំអាហារ សម្អាត និងលាងសម្អាតដៃ។ ប្រសិនបើក្រុមហ៊ុនផ្គត់ផ្គង់ទឹករបស់លោកអ្នកផ្តល់ឱវាទថាទឹកមិនមានសុវត្ថិភាពទេ លោកអ្នកត្រូវតែ៖
  - មិនប្រើទឹកនេះទេ ឬ
  - ដាំទឹកឲ្យពុះយ៉ាងហោចណាស់ 1នាទីមុនពេលប្រើប្រាស់ ឬ
  - សម្លាប់មេរោគដោយប្រើជាតិក្លរ ឬ
  - ប្រើការផ្គង់ផ្គង់ទឹកមួយផ្សេងទៀតដែលលោកអ្នកដឹងច្បាស់ថាមានសុវត្ថិភាព (ឧទាហរណ៍ ទឹកដប)។

របៀបរៀបចំចាត់ចែង

**D**

ធ្វើ

- ជានិច្ចកាលបោះចោលអាហារណាដែលបានឆ្លងមេរោគពីទឹកដែលមិនស្អាត។
- ប្រើប្រាស់តែទឹកក្នុងធុង ទុយយោ និងក្បាលម៉ាស៊ីនទឹកនៃការផ្គត់ផ្គង់ទឹកនៅក្នុងក្រុមហ៊ុនដែលសមស្របសម្រាប់ការផលិតអាហារ លាងសម្អាតដៃ និងសម្អាតកន្លែងធ្វើអាហារ។

**S**

បង្ហាញ

## តើអ្នកត្រូវការបង្ហាញអ្វីខ្លះ?

- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ៖
  - **កំណត់ត្រា** នៃការថែទាំដែលលោកអ្នកបានធ្វើ (សូមអាន **ប័ណ្ណ 'ការថែទាំឧបករណ៍ និងអាគារ'**)។

របៀបរៀបចំចាត់ចែង

# ការផ្គត់ផ្គង់ទឹក៖ ទឹកពីដំបូល និងទឹកលើ ឬក្រោមដី

**K**

ដឹង

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- ទឹកអាចនាំមកនូវមេរោគដែលមានគ្រោះថ្នាក់ និងជាតិគីមីដែលអាចធ្វើឲ្យមនុស្សឈឺ។ លោកអ្នកត្រូវប្រើតែទឹកស្អាត និងគ្មានមេរោគតែប៉ុណ្ណោះសម្រាប់រៀបចំអាហារ។
- ទឹកអាចមានមេរោគនៅពេលរក្សាទុកនៅក្នុងក្រុមហ៊ុន និងចែកចាយនៅជុំវិញកន្លែងផលិតអាហារ។
- លោកអ្នកត្រូវតែមានទឹកស្អាតគ្រប់គ្រាន់ដើម្បីលាងសម្អាតកន្លែងរៀបចំអាហារ ឧបករណ៍ និងរបស់ប្រើប្រាស់ធ្វើអាហារ។
- លោកអ្នកត្រូវតែមានទឹកស្អាតសម្រាប់ឲ្យបុគ្គលិកលាងសម្អាតដៃ។
- មានព័ត៌មានលើគេហទំព័ររបស់ក្រសួងឧស្សាហកម្មវត្ថុធាតុដើមនិយាយអំពីមន្ទីរពិសោធន៍ដែលមានការទទួលស្គាល់ត្រឹមត្រូវ។
- ការផ្គត់ផ្គង់ទឹករបស់លោកអ្នកអាចអាស្រ័យទៅតាមច្បាប់ផ្សេងទៀត។

**D**

ធ្វើ

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

- ជានិច្ចកាល ត្រូវប្រើទឹកដែលមានសុវត្ថិភាពសម្រាប់រៀបចំអាហារ សម្អាត និងលាងសម្អាតដៃ។ ប្រសិនបើការផ្គត់ផ្គង់ទឹករបស់លោកអ្នកមិនមានសុវត្ថិភាព លោកអ្នកត្រូវតែ៖
    - ឈប់ប្រើទឹកនោះ ឬ
    - ដាំទឹកឲ្យពុះយ៉ាងហោចណាស់ 1នាទីមុនពេលប្រើប្រាស់ ឬ
    - សម្លាប់មេរោគដោយប្រើជាតិក្លរ ឬ
    - ប្រើការផ្គង់ផ្គង់ទឹកផ្សេងទៀតដែលលោកអ្នកដឹងថាវាមានសុវត្ថិភាព (ឧទាហរណ៍ ទឹកដប)។

របៀបរៀបចំចាត់ចែង

# D

ធ្វើ

- ជានិច្ចកាលត្រូវបោះចោលអាហារណាដែលបានឆ្លងមេរោគពីទឹកមិនស្អាត។
- ជ្រើសរើសកន្លែងដែល លោកអ្នកយកទឹកមកពី៖
  - ☐ ការផ្គត់ផ្គង់ទឹកពីដំបូល
  - ☐ ការផ្គត់ផ្គង់ទឹកលើដី ឬការផ្គត់ផ្គង់ទឹកក្រោមដីដែលគ្មានស្ថេរភាព
  - ☐ ធានាការផ្គត់ផ្គង់ទឹកក្រោមដីឲ្យជាប់លាប់ (ជាការផ្គត់ផ្គង់ណាមួយដែលអាចឆ្លើយតបនឹងនិយមន័យនៃពាក្យ 'មិនខ្វះខាត' គឺនៅក្នុងស្តង់ដារទឹកបរិភោគសម្រាប់ប្រទេសនូវ៉ែលហ្សេឡង់)*
  - ☐ ការផ្គត់ផ្គង់ដែលបច្ចុប្បន្នអាស្រ័យទៅលើកម្មវិធីគ្រប់គ្រងហានិភ័យសុខភាពសាធារណៈ*

*លោកអ្នកមិនចាំបាច់ត្រូវធ្វើអ្វីបន្ថែមទេ ប្រសិនបើលោកអ្នកជ្រើសរើសប្រើកម្មវិធីមួយក្នុងចំណោមកម្មវិធីទាំងនេះ។

- ប្រសិនបើលោកអ្នកជ្រើសរើសផ្គត់ផ្គង់ទឹកស្អាតដោយខ្លួនឯង លោកអ្នកនឹងត្រូវធ្វើតេស្តវាយ៉ាងហោចណាស់មួយឆ្នាំម្តងដើម្បីធានាបានថាវាមានសុវត្ថិភាពសម្រាប់ប្រើប្រាស់។ លោកអ្នកត្រូវតែធ្វើតេស្តទឹក៖
  - មុនពេលចាប់ផ្តើមក្រុមហ៊ុនពាណិជ្ជកម្មថ្មី ឬ
  - ប្រសិនបើលោកអ្នកមិនមានកំណត់ត្រាស្តីពីការធ្វើតេស្តទឹកដែលផ្គត់ផ្គង់ដោយខ្លួនឯង។
- ទឹករបស់លោកអ្នកត្រូវតែឆ្លើយតបទៅនឹងកម្រិតកំណត់ទាំងអស់នៅក្នុងតារាងខាងក្រោម៖

| រង្វាស់ | លក្ខខណ្ឌ |
|---|---|
| *បាក់តេរីអ៊ីកូលី (Escherichia coli)* | តិចជាង 1 ក្នុងសំណាកណាមួយដែលមានបរិមាណទឹកចំនួន 100 មីលីលីត្រ* |
| ភាពល្អក់ | មិនត្រូវលើសពី 5 ខ្នាតរង្វាស់ភាពល្អក់ដោយម៉ាស៊ីននិហ្វិលឡូមីតធើ (Nephelometric Turbidity Units) |
| ក្លរ (នៅពេលប្រើក្លរ) | មិនតិចជាង 0.2 មីលីក្រាម/លីត្រ (ភាគក្នុងមួយលាន-ppm) នៃចំនួនក្លរដែលមាននៅក្នុងទឹកដោយមានរយៈពេលទឹកប៉ះនឹងក្លរជាអប្បបរមាចំនួន 20នាទី |
| កម្រិត pH (នៅពេលដាក់ក្លរ) | 6.5 – 8.0 |

* *បាក់តេរីអេកូលី* ការធ្វើតេស្តត្រូវធ្វើឡើងដោយមន្ទីរពិសោធន៍ដែលមានការទទួលស្គាល់ត្រឹមត្រូវ

របៀបរៀបចំចាត់ចែង

# D

ធ្វើ

- លោកអ្នកត្រូវតែធ្វើតេស្តទឹកឡើងវិញមិនឲ្យយឺតជាង 1សប្តាហ៍បន្ទាប់ពី៖
    - យកទឹកចេញពីប្រភពផ្គត់ផ្គង់ដោយខ្លួនឯងថ្មីមួយ ឬ
    - ដឹងពីការប្រែប្រួលក្នុងបរិស្ថាន ឬសកម្មភាពដែលអាចប៉ះពាល់ដល់សុវត្ថិភាព និងភាពសមរម្យនៃទឹក។
- លោកអ្នកត្រូវតែប្រើប្រព័ន្ធសម្លាប់មេរោគក្នុងទឹកដើម្បីធានាថាទឹកសម្រាប់ផលិតអាហារ លាងសម្អាតដៃ និងលាងសម្អាតនានា ជាទឹកស្អាតនៅកន្លែងប្រើ។ ជ្រើសរើសយកមួយណាដែលលោកអ្នកប្រើ៖

    ☐ ចំរោះ

    ☐ ដាក់ក្លរ

    ☐ សម្លាប់មេរោគដោយប្រើកាំរស្មី UV

    ☐ ផ្សេងទៀត ______________________

- លោកអ្នកត្រូវតែដាក់សញ្ញាឲ្យច្បាស់លើក្បាលម៉ាស៊ីនទឹក ធុង និងទុយយោដែលមិនមានទឹកស្អាត។ ទឹកនៅកន្លែងទាំងនេះមិនត្រូវប្រើសម្រាប់ផលិតអាហារ លាងសម្អាតដៃ និងលាងសម្អាតផ្សេងៗ ឡើយ។

សម្រាប់ទឹកនៅលើដី និងការបូមយកទឹកក្រោមដី (ដែលគ្មានស្ថេរភាព) ត្រូវតែ៖

- យ៉ាងហោចណាស់នៅឆ្ងាយ 10ម៉ែត្រពីកន្លែងចិញ្ចឹមសត្វ
- យ៉ាងហោចណាស់នៅឆ្ងាយ 50ម៉ែត្រពីប្រភពដែលអាចមានមេរោគ ដោយរួមមានគំនរចំបើង រណ្តៅកប់គ្រឿងក្នុងសត្វ កន្លែងកាកសំណល់សត្វ និងមនុស្ស កន្លែងឬធុងដែលអាចមានសារធាតុគីមី (ដូចជាធុងប្រេងឥន្ធនៈ)។

- លោកអ្នកត្រូវតែដឹង និងរាយបញ្ជីនូវគ្រប់សកម្មភាព និងជាតិគីមីដែលកើតមានពីធម្មជាតិដែលនាំឲ្យឆ្លងមេរោគដល់ការផ្គត់ផ្គង់ទឹករបស់លោកអ្នក។

S

បង្ហាញ

## តើអ្នកត្រូវការបង្ហាញអ្វីខ្លះ?

- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ**កំណត់ត្រា** អំពី៖
    - លទ្ធផលការធ្វើតេស្តទឹកដំបូង ឬប្រចាំឆ្នាំរបស់លោកអ្នក
    - បញ្ជីនៃសកម្មភាពនៅក្បែរទាំងអស់ដែលអាចប៉ះពាល់ដល់សុវត្ថិភាពទឹករបស់លោកអ្នក។
- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវវិធីដែលលោកអ្នកដឹងថាប្រព័ន្ធសម្លាប់មេរោគក្នុងទឹករបស់លោកអ្នកមានដំណើរត្រឹមត្រូវ។

ការចាប់ផ្តើម

# លាងសម្អាតដៃ

**K**

ដឹង

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- ការលាងសម្អាតដៃរបស់លោកអ្នកអាចជួយទប់មេរោគមិនឲ្យចូលចង្ក្រានបាយបាន។ ការលាងសម្អាតដៃទៀងទាត់ជួយទប់ស្កាត់ការឆ្លងមេរោគដល់អាហាររបស់លោកអ្នក។
- ស្នាមមុត និងដំបៅចំហរអាចចម្លងមេរោគ និងធ្វើឲ្យអាហារគ្មានសុវត្ថិភាព និងមិនសមរម្យ។

**D**

ធ្វើ

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

- លាងសម្អាតដៃលោកអ្នកដោយប្រើទឹកសាប៊ូរយៈពេល 20វិនាទី បន្ទាប់មកសម្ងួតឲ្យស្ងួតល្អដោយប្រើក្រដាសជូតដៃ ក្រណាត់ប្រើម្តងបោះចោល ឬប្រដាប់សម្ងួតប្រើខ្យល់។
- ជានិច្ចកាលដាក់ឲ្យមានសាប៊ូ និងក្រដាសជូតដៃ ក្រណាត់ប្រើម្តងបោះចោល ឬប្រដាប់សម្ងួតប្រើខ្យល់នៅក្បែរផើងលាងដៃ។
- លោកអ្នកត្រូវតែរក្សាកន្លែងលាងដៃរបស់លោកអ្នកឲ្យស្អាត។
- លោកអ្នកត្រូវតែលាងសម្អាតដៃរបស់លោកអ្នកៈ
  - នៅពេលចូលចង្ក្រានបាយ
  - មុនពេលធ្វើអាហារ
  - បន្ទាប់ពីក្អក ឬកណ្តាស់
  - ក្រោយចេញពីបង្គន់
  - បន្ទាប់ពីប្រើទូរស័ព្ទ
  - បន្ទាប់ពីយកសម្រាមបោះចោល
  - បន្ទាប់ពីប៉ះរបស់អ្វីមួយដែលលោកអ្នកគិតថាកខ្វក់។

ការចាប់ផ្ដើម

D

ធ្វើ

- លោកអ្នកត្រូវតែគ្រប់គ្រងស្នាមមុត ឬដំបៅដោយ៖
(គូសយកវិធីសមស្រប)
  - ☐ បិទបង់ទៅលើស្នាមមុត និងដំបៅ ឬ
  - ☐ មិនធ្វើអាហារ ប្រសិនបើស្នាមមុត និងដំបៅមានហូរទឹករងៃ ឬក្លាយ និងមិនអាចបិទបង់បានទាំងស្រុង។

S

បង្ហាញ

## តើអ្នកត្រូវការបង្ហាញអ្វីខ្លះ?

- សូមប្រាប់អ្នកផ្ទៀងផ្ទាត់លោកអ្នកថានរណាជាអ្នកទទួលខុសត្រូវធានាថាកន្លែងលាងសម្អាតដៃរបស់លោកអ្នកមានប្រដាប់ប្រើប្រាស់គ្រប់គ្រាន់ និងស្អាត។
- អ្នកផ្ទៀងផ្ទាត់របស់លោកអ្នកអាចពិនិត្យមើលថាបុគ្គលិកទាំងអស់បានលាងដៃនៅពេលពួកគេត្រូវតែលាងដៃរឬទេ។
- អ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនឹងលាងសម្អាតដៃរបស់ពួកគេនៅពេលចូលក្នុងក្រុមហ៊ុនពាណិជ្ជកម្មរបស់លោកអ្នក ដោយពិនិត្យមើលថារបស់របរដែលពួកគេត្រូវការទាំងអស់មាននៅទីនោះ។

ការចាប់ផ្ដើម



# ការពារអាហារពីការចម្លងមេរោគដោយសារបុគ្គលិក

**K**

**ដឹង**

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- អាហារអាចក្លាយទៅជាគ្មានសុវត្ថិភាព និងមិនសមរម្យ ប្រសិនបើវាឆ្លងមេរោគដោយសារមនុស្សឈឺ ឬសំលៀកបំពាក់កខ្វក់។
- មេរោគដែលបង្កគ្រោះថ្នាក់អាចឆ្លងទៅអាហារតាមរយៈលាមក កំអួត និងសារធាតុរាវនៃរាងកាយរបស់អ្នកជំងឺ (ឧទាហរណ៍ ឈាម សំបោរ)។
- ស្លៀកសម្លៀកបំពាក់ស្អាត (ដោយរាប់បញ្ចូលទាំងអាវអៀម។ល។) ជួយរក្សាកុំឲ្យមេរោគចូលក្នុងអាហារ ឧបករណ៍ និងកន្លែងរៀបចំអាហារ។
- សម្លៀកពាក់កខ្វក់អាចចម្លងមេរោគដល់អាហារ ផ្ទៃខាងក្រៅ និងឧបករណ៍ធ្វើអាហារ។
- ប្រសិនបើបុគ្គលិកដែលឈឺចម្លងមេរោគដល់អាហារ លោកអ្នកអាចត្រូវប្រមូលអាហារដែលបានលក់ចេញមកវិញទាំងអស់។ សូមអាន **‘ការប្រមូលអាហាររបស់លោកអ្នកត្រឡប់មកវិញ’**។

**D**

**ធ្វើ**

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

### គ្រប់គ្រងបុគ្គលិកដែលមានជំងឺ

- បុគ្គលិក ឬភ្ញៀវណា (ដោយរាប់ទាំងអ្នកម៉ៅការ) ដែលបានក្អួត ឬរាគក្នុងរយៈពេល 48ម៉ោង មុនពេលចូលក្នុងកន្លែងធ្វើអាហារត្រូវប្រាប់ទៅ៖ (គូសយកចំណុចសមស្រប)។

  ☐ អ្នកគ្រប់គ្រងប្រចាំថ្ងៃ ឬ

  ☐ អ្នកមានសិទ្ធិសម្រេច

  ឈ្មោះ ______________________

# D

ធ្វើ

- អ្នកធ្វើអាហារដែលបានក្អួត ឬរាគក្នុងរយៈពេល 48ម៉ោងមុនពេលចូលក្នុងកន្លែងធ្វើអាហារ ឬនៅក្នុងកន្លែងធ្វើអាហារ ត្រូវប្រាប់ទៅ

  ☐ អ្នកគ្រប់គ្រងប្រចាំថ្ងៃ ឬ

  ☐ អ្នកមានសិទ្ធិសម្រេច (គូសយកចំណុចសមស្រប)
  ឈ្មោះ៖ ______________________
  ឲ្យបានដឹងភ្លាម និងទៅជួបវេជ្ជបណ្ឌិតដើម្បីសុំយោបល់ ប្រសិនបើវាកើតឡើង 2 ឬច្រើនដង។
- បុគ្គលិកត្រូវតែនៅឲ្យឆ្ងាយពីកន្លែងធ្វើអាហារ រហូតដល់ពួកគេជាសះស្បើយឡើងវិញ ប្រសិនបើពួកគេមានជំងឺ ពួកគេអាចចម្លងទៅអ្នកដទៃបាន។
- បុគ្គលិកមានជំងឺអាចធ្វើកិច្ចការណាដែលមិនប៉ះពាល់ផ្ទាល់នឹងអាហារ ឬកន្លែងរៀបចំអាហារ។

## ស្លៀកសម្លៀកបំពាក់ស្អាត

- សម្លៀកបំពាក់ស្អាត (ឧទាហរណ៍ អាវអៀម។ល។) ត្រូវពាក់មុននឹងចាប់ផ្តើមធ្វើអាហារ ឬចូលកន្លែងរៀបចំអាហារ (នេះក៏ត្រូវអនុវត្តចំពោះអ្នកម៉ៅការ និងភ្ញៀវដែរ)។
- លោកអ្នកត្រូវធានាបាននូវកិច្ចការមួយនៃកិច្ចការដូចខាងក្រោមណាមួយ (គូសយកចំណុចសមស្រប)

  ☐ បុគ្គលិកស្លៀកសម្លៀកបំពាក់ស្អាតរបស់ពួកគេផ្ទាល់ ឬ

  ☐ ខ្ញុំផ្តល់សម្លៀកបំពាក់ស្អាតឲ្យបុគ្គលិក
- ដោះសម្លៀកបំពាក់ការពារខាងក្រៅចេញ (ឧទាហរណ៍ អាវអៀម។ល។) មុនពេលចាកចេញពីកន្លែងរៀបចំអាហារ (ឧទាហរណ៍ ទៅបង្គន់ ទៅខាងក្រៅ។ល។)

S

បង្ហាញ

## តើអ្នកត្រូវការបង្ហាញអ្វីខ្លះ?

- អ្នកផ្ទៀងផ្ទាត់របស់លោកអ្នកអាចសុំឲ្យលោកអ្នកពន្យល់ពីវិធីគ្រប់គ្រងបុគ្គលិកដែលមានជំងឺ។
- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់អ្នកនូវ៖
    - **កំណត់ត្រា** ជាលាយលក្ខអក្សរ ស្តីពីបុគ្គលិកដែលមានជំងឺ
    - ថា រាល់អ្នកធ្វើអាហារបានស្លៀកសម្លៀកបំពាក់/អាវអៀមស្អាតនៅពេលចាប់ផ្តើម (តាមតម្រូវការក្នុង) វេនធ្វើការនិមួយៗ
    - អំពីវិធីដែលលោកអ្នកធ្វើដើម្បីធានាថាសម្លៀកបំពាក់បុគ្គលិកទាំងអស់ស្អាត។
- អ្នកផ្ទៀងផ្ទាត់របស់លោកអ្នកក៏អាចសួរអំពីបទដ្ឋានរបស់លោកអ្នកជុំវិញសម្លៀកបំពាក់ស្អាត ឬបញ្ហាណាដែលលោកអ្នកមានទាក់ទងនឹងបទដ្ឋានរបស់លោកអ្នក។

ការចាប់ផ្តើម

# រក្សាអាហារឲ្យត្រជាក់

**K**

ដឹង

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- ការរក្សាអាហារទុកក្នុងសីតុណ្ហភាពដែលត្រឹមត្រូវ គឺអាចការពារមិនឲ្យមេរោគកើនឡើងលឿន។
- អាហារមួយចំនួនត្រូវតែរក្សាឲ្យត្រជាក់ (ត្រជាក់ ឬកក) ដើម្បីបញ្ឈប់មេរោគមិនឲ្យកើនឡើង។
- លោកអ្នកត្រូវដឹងភាពខុសគ្នារវាង៖
    - អាហារដែលលោកអ្នកត្រូវរក្សាឲ្យត្រជាក់ដើម្បីឲ្យវាមានសុវត្ថិភាព (ឧទាហរណ៍ ទឹកដោះគោ) និង
    - អាហារដែលលោកអ្នកអាចរក្សាឲ្យត្រជាក់ដើម្បីឲ្យអតិថិជនបរិភោគបានឆ្ងាញ់ពិសារ (ឧទាហរណ៍ ស្រាបៀរ)។
- លោកអ្នកត្រូវដឹងថាអាហារប្រភេទណាត្រូវរក្សាឲ្យត្រជាក់។ ស្វែងយល់ពីក្រុមហ៊ុនផ្គត់ផ្គង់របស់លោកអ្នក និងស្លាកអាហារ។

**D**

ធ្វើ

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

- ពិនិត្យមើលរាល់ថ្ងៃថាអាហារនៅក្នុងទូរទឹកកករបស់លោកអ្នករក្សានៅក្នុងសីតុណ្ហភាព 5 អង្សាសេ ឬទាបជាងនេះ។
- ពិនិត្យសីតុណ្ហភាពនៃអាហារនៅក្នុងទូរទឹកកករបស់លោកអ្នកដោយ៖(គូសយកចំណុចសមស្រប)

  ☐ ការប្រើប្រាស់ប្រដាប់វាស់សីតុណ្ហភាពដើម្បីស្ទង់សីតុណ្ហភាពអាហារ ឬសារធាតុផ្សេងទៀត (ឧទាហរណ៍ ថូទឹក) ឬ

ការចាប់ផ្ដើម

**D**

**ធ្វើ**

- ☐ ការប្រើប្រាស់ប្រដាប់វាស់សីតុណ្ហភាពដោយប្រើរលកពន្លឺ ដើម្បីវាស់សីតុណ្ហភាពផ្ទៃខាងក្រៅនៃអាហារ ឬ
- ☐ ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិដើម្បីពិនិត្យសីតុណ្ហភាពខាងក្នុង ឬផ្ទៃខាងក្រៅនៃអាហារ។

- ពិនិត្យថាអាហារនៅក្នុងទូកក វាស្ថិតនៅក្នុងសភាពកកដដែល។ លោកអ្នកមិនចាំបាច់កត់ត្រាសីតុណ្ហភាពនៃអាហារកកទេ។
- អនុវត្តតាមបទដ្ឋាន 2-ម៉ោង/4-ម៉ោង ដូចបង្ហាញនៅក្នុងដ្យាក្រាមខាងក្រោម។

### រយៈពេលសរុបដែលអាហារត្រូវរក្សាមានសីតុណ្ហភាពចន្លោះ 5 - 60អង្សាសេ



ការចាប់ផ្ដើម

# D

ធ្វើ

- ប្រសិនបើដឹកជញ្ជូនចំណីអាហារត្រជាក់ ជានិច្ចកាលលោកអ្នកត្រូវប្រើ៖ (រើសយកចំណុចសមស្រប)

  ☐ ទូកក/យានយន្តដែលមានទូទឹកកក

  ☐ ធុងទឹកកកដែលមានដាក់ដុំទឹកកកនៅខាងក្នុង

  ☐ ធុងដែលមានទ្រនាប់ការពារកំដៅ

  ☐ ផ្សេងទៀត ______________________

# S

បង្ហាញ

## តើអ្នកត្រូវការបង្ហាញអ្វីខ្លះ?

- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ៖
  - វិធីដែលលោកអ្នកប្រើដើម្បីពិនិត្យសីតុណ្ហភាពអាហារ ឬសីតុណ្ហភាពខាងក្នុងទូទឹកកករបស់លោកអ្នក
  - **កំណត់ត្រា**អំពីការពិនិត្យសីតុណ្ហភាពរបស់លោកអ្នក។

ការចាប់ផ្ដើម



# ពិនិត្យមើលសត្វចម្លងមេរោគ

**K**

**ដឹង**

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- សត្វចម្លងមេរោគដូចជាកណ្ដុរ បក្សាបក្សី និងសត្វល្អិតអាចចម្លងជំងឺ។ សត្វទាំងនេះអាចចម្លងមេរោគដោយនាំមកនូវមេរោគពីវត្ថុកខ្វក់ដូចជាកាកសំណល់ និងចម្លងមេរោគទាំងនេះទៅក្នុងអាហារ និងឧបករណ៍ធ្វើអាហារ។

**D**

**ធ្វើ**

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

- ពិនិត្យមើល និងលុបបំបាត់សញ្ញាថាមានសត្វចម្លងមេរោគរាល់ថ្ងៃ (ឧទាហរណ៍ អាហារជ្រុះ យកសត្វចេញពីអង្គប់ សត្វល្អិតងាប់)។
- សម្អាត និងធ្វើអនាម័យដល់ឧបករណ៍ និងកន្លែងដែលប៉ះពាល់ដល់អាហារ។
- អនុវត្តតាមនិតិវិធីលើអ្វីដែលត្រូវធ្វើ **'នៅពេលមានបញ្ហាអ្វីមួយ'** ប្រសិនបើលោកអ្នកឃើញមានសញ្ញាថាមានសត្វចម្លងមេរោគនៅក្នុងកន្លែងធ្វើអាហាររបស់លោកអ្នក។

**S**

**បង្ហាញ**

## តើលោកអ្នកត្រូវបង្ហាញអ្វីខ្លះ?

- បង្ហាញដល់អ្នកផ្ទៀងផ្ទាត់របស់លោកអ្នកពីវិធីដែលលោកអ្នកប្រើដើម្បីពិនិត្យរកមើលសត្វចម្លងមេរោគ។

ការរៀបចំ

# ការដាក់អាហារឲ្យនៅដាច់ពីគ្នា

K

ដឹង

## តើអ្នកត្រូវដឹងអ្វីខ្លះ?

- រក្សាអាហារឆៅ/អាហារមិនទាន់ចម្អិនឲ្យនៅដាច់ពីអាហារឆ្អិន/អាហារដែលអាចបរិភោគបានភ្លាមៗ (ឧទាហរណ៍ សាឡាដ) វានឹងអាចជួយបញ្ឈប់ការចម្លងមេរោគបាន។
- មានជាតិបង្កឲ្យមានអាលែកហ្ស៊ីនៅក្នុងអាហារទូទៅចំនួន 11ប្រភេទដែលអ្នកត្រូវដឹង។ ជាតិបង្កឲ្យមានអាលែកហ្ស៊ីទាំងនេះគឺ អំបិលមានអាស៊ីតស្ពាន់ធ័រ (sulphites) ធញ្ញជាតិដែលមានគ្លុយទីន (gluten) (ឧទាហរណ៍ស្រូវសាឡី) សត្វទឹកដែលមានសំបក (shellfish) ស៊ុត ត្រី ទឹកដោះគោ គ្រាប់សណ្តែកដី គ្រាប់សណ្តែកសៀង គ្រាប់ល្ង គ្រាប់ផ្លែឈើ និង គ្រាប់សណ្តែក។
- អាហារ/គ្រឿងផ្សំមួយចំនួនអាចបង្កឲ្យមានប្រតិកម្មអាលែកហ្ស៊ី។ ការរក្សាអាហារដែលគ្មានជាតិបង្កឲ្យមានអាលែកហ្ស៊ីឲ្យនៅដាច់ពីអាហារដែលមានជាតិបង្កឲ្យមានអាលែកហ្ស៊ីដូចមានក្នុងបញ្ជីខាងលើនឹងអាចបញ្ឈប់មនុស្សកុំឲ្យឈឺ និងអាចស្លាប់បាន។
- ត្រូវដឹងថាអ្វីជាជាតិបង្កឲ្យមានអាលែកហ្ស៊ីនៅក្នុងអាហារដែលអ្នកលក់ - អ្នកត្រូវតែប្រាប់អតិថិជន ប្រសិនបើពួកគេសួរ ឬមួយអ្នកអាចដាក់បញ្ចូលព័ត៌មាននៅលើកញ្ចប់អាហារ។
- ជាតិពុល និងជាតិគីមីគ្រោះថ្នាក់អាចធ្វើឲ្យមនុស្សឈឺ ប្រសិនបើវាធ្លាក់ចូលក្នុងអាហារ។

D

ធ្វើ

## តើអ្នកត្រូវធ្វើអ្វីខ្លះ?

- អ្នកត្រូវតែជ្រើសរើសយកវិធីមួយក្នុងចំណោមវិធីខាងក្រោម នៅពេលរៀបចំ៖(រើសយកវិធីដែលសមស្រប)
    - អាហារឆៅ និងឆ្អិន/អាហារអាចបរិភោគបានភ្លាមៗ
    - អាហារដែលមានជាតិបង្កឲ្យមានអាលែកហ្ស៊ីដែលមានរាយឈ្មោះនៅក្នុងផ្នែក**ដឹង** និងអាហារដែលគ្មានជាតិបង្កឲ្យមានអាលែកហ្ស៊ី

# D

**ធ្វើ**

- ☐ ប្រើកន្លែង និងឧបករណ៍ផ្សេងៗគ្នា (ជ្រុញ កាំបិត និងប្រដាប់ប្រើសម្រាប់ធ្វើអាហារ) ឬ
- ☐ ផលិតនៅពេលខុសៗគ្នា (សម្អាតក្នុងចន្លោះពេល) និង/ឬ
- ☐ សម្អាត និងសម្លាប់មេរោគលើផ្ទៃខាងក្រៅ ជ្រុញ កាំបិត និងប្រដាប់ប្រើធ្វើអាហារផ្សេងៗទៀតឲ្យស្អាតមែនទែន។

- លាងសម្អាតដៃរបស់អ្នក ហើយបើវាចាំបាច់ សូមប្តូរសម្លៀកបំពាក់ការពារ (ឧទាហរណ៍ ដូរអាវអៀម) នៅចន្លោះពេលចាត់ចែង៖
  - អាហារឆៅ និងឆ្អិន/អាហារអាចបរិភោគបានភ្លាមៗ
  - អាហារដែលមានជាតិបង្កឲ្យមានអាលែកហ្ស៊ីដូចមានរាយឈ្មោះនៅក្នុងផ្នែក **ដឹង** និងអាហារដែលគ្មានជាតិបង្កឲ្យមានអាលែកហ្ស៊ី
  - ជាតិគីមីគ្រោះថ្នាក់ ឬជាតិពុល និងអាហារ។
- រក្សាផលិតផលទាំងអស់ដែលមិនមែនសម្រាប់ឲ្យមនុស្សបរិភោគ (ឧទាហរណ៍ចំណីសត្វ) ឲ្យនៅឆ្ងាយពីអាហារ និងកន្លែងរៀបចំអាហារសម្រាប់មនុស្សបរិភោគ។
- ដាក់ស្លាកជាតិពុល និងគីមីគ្រោះថ្នាក់ឲ្យច្បាស់ រក្សាវាទុកឲ្យនៅឲ្យឆ្ងាយពីអាហារ និងត្រូវធានាថា ចំណីអាហារត្រូវបានការពារល្អនៅពេលប្រើប្រាស់វា។
- ដាក់ស្លាក និងរក្សាទុកអាហារទាំងអស់ដែលអាចបង្កប្រតិកម្មអាលែកហ្ស៊ីឲ្យនៅដាច់ពីគេ។
- ប្រាប់អតិថិជនរបស់អ្នកឲ្យបានដឹងថា តើអាហារណាដែលអ្នកធ្វើ ឬលក់មានជាតិបង្កឲ្យមានអាលែកហ្ស៊ី ប្រសិនបើពួកគេសួរ។

**D**

**ធ្វើ**

- នៅពេលដឹកជញ្ជូនចំណីអាហារ ត្រូវដាក់ឲ្យនៅដាច់ពីគ្នានូវ៖
  - អាហារឆៅ និងឆ្អិន/អាហារដែលអាចបរិភោគបានភ្លាមៗ
  - អាហារដែលមានជាតិបង្កឲ្យមានអាលែកហ្ស៊ីដែលមានរាយឈ្មោះនៅក្នុងផ្នែក**ដឹង** និងអាហារដែលគ្មានជាតិបង្កឲ្យមានអាលែកហ្ស៊ី

**S**

**បង្ហាញ**

## តើអ្នកត្រូវបង្ហាញអ្វីខ្លះ?

- អ្នកផ្ទៀងផ្ទាត់របស់អ្នក អាចសួរបុគ្គលិកអ្នកឲ្យពន្យល់ពីវិធីដែលពួកគេដឹងថាអាហារមួយណាដែលអ្នកធ្វើ ឬបម្រើមានជាតិបង្កឲ្យមានអាលែកហ្ស៊ី។
- បង្ហាញដល់អ្នកផ្ទៀងផ្ទាត់របស់អ្នកថាអាហារណាដែលមានជាតិបង្កឲ្យមានអាលែកហ្ស៊ីណាមួយដូចមានរាយឈ្មោះនៅក្នុងផ្នែក **ដឹង** និងជាតិពុល និងជាតិគីមីគ្រោះថ្នាក់ត្រូវបានដាក់ស្លាកឲ្យបានច្បាស់ ហើយរក្សាទុកឲ្យនៅឆ្ងាយពីអាហារ។
- បង្ហាញ ឬពន្យល់ដល់អ្នកផ្ទៀងផ្ទាត់របស់អ្នកពីវិធីដែលអ្នកដាក់ឲ្យនៅដាច់ពីគ្នានូវ៖
  - អាហារឆៅ និងឆ្អិន/អាហារដែលអាចបរិភោគបានភ្លាមៗ ឬ
  - អាហារដែលមានជាតិបង្កឲ្យមានអាលែកហ្ស៊ីដូចមានរាយឈ្មោះនៅក្នុងវគ្គ **ដឹង** និងអាហារដែលគ្មានជាតិបង្កឲ្យមានអាលែកហ្ស៊ី
  - ជាតិគីមីគ្រោះថ្នាក់ ឬជាតិពុល និងអាហារ។



# ការរៀបចំអាហារឲ្យមានសុវត្ថិភាព

**K**

ដឹង

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- មេរោគគ្រោះថ្នាក់ពីអាហារ និងជាតិបង្កឲ្យមានអាលែកហ្ស៊ីអាចឆ្លងដោយសារអាហារកខ្វក់ ភាពកខ្វក់ ដៃ សម្លៀកបំពាក់ និងផ្ទៃខាងក្រៅ។ កន្លែងរៀបចំអាហារដែលចាត់ចែងមិនបានល្អ ឬកខ្វក់ វាអាចធ្វើឲ្យមានមេរោគកើនឡើង និងឆ្លងយ៉ាងលឿន ហើយឆ្លងបានយ៉ាងងាយ។
- មានបទដ្ឋាននៅក្នុងក្រមស្តង់ដារអាហារនៃប្រទេសអូស្ត្រាលី និងនូវ៉ែលហ្ស៊ីឡង់ (ក្រម) ស្តីពីប្រភេទនៃគ្រឿងបន្ថែមក្នុងអាហារ (ឧទាហរណ៍ ថ្នាំបង្ការមិនឲ្យអាហារខូច) ដែលលោកអ្នកអាចដាក់ក្នុងអាហារមួយចំនួនបាន។ ក្រុមហ៊ុនពាណិជ្ជកម្មសេវាចំណីអាហារត្រូវតែដឹងអំពីបទដ្ឋានទាំងនេះ។ ប្រសិនបើលោកអ្នកប្រើគ្រឿងបន្ថែមក្នុងអាហារ ពិនិត្យមើលក្រម ឬសុំព័ត៌មានបន្ថែមពីអ្នកផ្សៀងផ្ទាត់របស់លោកអ្នក។
- មានបទដ្ឋានស្តីពីសមាសភាពនៅក្នុងក្រមដែលអនុវត្តចំពោះតែអាហារមួយចំនួនដែលលោកអ្នកអាចធ្វើបាន (ឧទាហរណ៍ សាច់ក្រក នំផាយដាក់សាច់ ។ល។)។ ពិនិត្យមើលក្រម ឬសុំព័ត៌មានបន្ថែមពីអ្នកផ្សៀងផ្ទាត់របស់លោកអ្នក។

**D**

ធ្វើ

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

- រៀបចំលំហូរការងាររបស់លោកអ្នកដើម្បីឲ្យលោកអ្នកអាចចល័តក្នុងកន្លែងលោកអ្នកបានដោយសុវត្ថិភាព (ឧទាហរណ៍ ដើម្បីឲ្យអ្នកមិនអាចយួរសាច់មាន់ឆៅឆ្លងកន្លែងដែលធ្វើអាហារឆ្អិន/អាហាអាចបរិភោគបានភ្លាម)។
- សម្អាត និងធ្វើអនាម័យដល់កន្លែងការងាររបស់លោកអ្នកនៅពេលលោកអ្នកធ្វើការងារ។
- ពិនិត្យមើលតម្រូវការនៃគ្រឿងបន្ថែមក្នុងអាហារនៅក្នុងក្រម ប្រសិនបើលោកអ្នកប្រើគ្រឿងបន្ថែមក្នុងអាហារ (ឧទាហរណ៍ ថ្នាំបង្ការមិនឲ្យអាហារខូច) ដើម្បីធ្វើអាហាររបស់លោកអ្នក។
- ពិនិត្យមើលថាតើអ្នកបានធ្វើតាមតម្រូវការនៃសមាសភាពនៅក្នុងក្រមនេះហើយឬនៅ (ប្រសិនបើទាក់ទង)។

S

បង្ហាញ

## តើអ្នកត្រូវបង្ហាញអ្វីខ្លះ?

- បង្ហាញ ឬពន្យល់ដល់អ្នកផ្ទៀងផ្ទាត់របស់លោកអ្នកពីវិធីដែលលោកអ្នកធ្វើការនៅក្នុងចង្ក្រានបាយដោយរាប់បញ្ចូលទាំង៖
    - វិធីដែលលោកអ្នកសម្អាតនៅពេលលោកអ្នកធ្វើការងារ
    - វិធីដែលកន្លែងរៀបចំអាហាររបស់លោកអ្នកមានដំណើរយ៉ាងរលូនដើម្បីបញ្ឈប់មេរោគកុំឲ្យកើនឡើង និងរាលដាល
    - រូបមន្តធ្វើអាហារដើម្បីបង្ហាញពីវិធីដែលលោកអ្នកឆ្លើយតបទៅនឹងបទដ្ឋានគ្រឿងបន្ថែម និងសមាសភាពក្នុងអាហារ ប្រសិនបើអ្នកត្រូវធ្វើតាមបទដ្ឋាននេះ។

ការរៀបចំ



# រកប្រភព ទទួល និងរក្សាទុកអាហារ

**K**

ដឹង

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- ការចំអិនមិនមែនមានន័យថាអាហារទាំងអស់មានសុវត្ថិភាពទេ។
- អាហារមួយចំនួនត្រូវតែរក្សាទុកក្នុងសីតុណ្ហភាពត្រជាក់ (ត្រជាក់ ឬកក) ដើម្បីបញ្ឈប់មេរោគមិនឲ្យលូតលាស់។
- ម៉ាស៊ីនលក់អាហារត្រូវរក្សាទុកអាហារក្នុងសីតុណ្ហភាពត្រឹមត្រូវដើម្បីបញ្ឈប់មេរោគមិនឲ្យលូតលាស់។
- អាហារ ឬគ្រឿងផ្សំមិនត្រូវប្រើ ឬលក់បន្ទាប់ពី ‘ប្រើ-ឲ្យបានមុនកាលបរិច្ឆេទ’ (នេះរាប់បញ្ចូលអាហារចេញពីម៉ាស៊ីនលក់អាហារ)។
- រកប្រភពអាហារតែមកពីក្រុមហ៊ុនផ្គត់ផ្គង់ដែលល្បីឈ្មោះ (ឧទាហរណ៍ ក្រុមហ៊ុនពាណិជ្ជកម្មអាហារដែលបានចុះបញ្ជីរួច)។

**D**

ធ្វើ

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

- ទិញអាហារតែពីក្រុមហ៊ុនផ្គត់ផ្គង់ដែលមានការអនុញ្ញាតត្រឹមត្រូវ។
- នៅពេលទទួលអាហារ ត្រូវកត់ត្រា៖
  - ឈ្មោះ និងព័ត៌មានទាក់ទងលម្អិតរបស់ក្រុមហ៊ុនផ្គត់ផ្គង់
  - ប្រភេទ និងបរិមាណអាហារ
  - សីតុណ្ហភាពនៃអាហារ ប្រសិនបើវាត្រូវការរក្សានៅក្នុងសីតុណ្ហភាពជាក់លាក់មួយដើម្បីធានាថាវាមានសុវត្ថិភាព និងសមរម្យ។
- នៅពេលប្រមូល ឬទទួលអាហារត្រជាក់ ត្រូវវាស់សីតុណ្ហភាពរបស់វាដោយប្រើប្រដាប់វាស់សីតុណ្ហភាព។ លោកអ្នកត្រូវតែពិនិត្យមើលថា៖

ការរៀបចំ

# D

ធ្វើ

- ◦ អាហារត្រជាក់នៅត្រជាក់
- ◦ អាហារកកនៅកក
- ◦ កញ្ចប់របស់វាមិនមានការខូចខាត ឬមិនកខ្វក់
- ◦ អាហារមិនហួសកាលបរិច្ឆេទកំណត់ឲ្យបរិភោគ។

- រក្សាទុកអាហារឲ្យមានសុវត្ថិភាព។ ជាដំបូងរៀបចំទុកដាក់អាហារត្រជាក់មុនគេ បន្ទាប់មកអាហារកក បន្ទាប់មកទៀតអាហារដែលអាចរក្សាទុកក្នុងសីតុណ្ហភាពក្នុងបន្ទប់បាន។
- រៀបចំទុកដាក់អាហាររបស់អ្នកដើម្បីឲ្យអាហារដែលជិតផុតពេលកំណត់ (ប្រើឲ្យបានមុនកាលបរិច្ឆេទ ឬគុណភាពល្អបំផុតនៅមុនកាលបរិច្ឆេទ) ជាងគេត្រូវយកមកប្រើប្រាស់មុនគេ។
- បោះចោលអាហារដល់ថ្ងៃផុតកំណត់របស់វា។
- រក្សាទុកអាហារដោយគ្របជិត និងដាក់ស្លាកឲ្យបានច្បាស់។
- អនុវត្តតាមបទដ្ឋាន 2-ម៉ោង/4-ម៉ោ ង ដូចមានបង្ហាញនៅក្នុងដ្យាក្រាមខាងក្រោម៖

## រយៈពេលសរុបដែលអាហារត្រូវរក្សាទុកក្នុងចន្លោះ 5 - 60អង្សាសេ

### 0 ម៉ោង

អាហារត្រូវយកចេញពីទូទឹកកក។ អាហារត្រូវមានសីតុណ្ហភាព 5 អង្សាសេ ឬទាបជាងនេះ។

### តិចជាង 2 ម៉ោង

- បម្រើអាហារដែលអាចបរិភោគបានភ្លាមៗ ឬ
- ឬចំអិនអាហារដល់សីតុណ្ហភាព 75 អង្សាសេ ឬ
- ដាក់ចូលក្នុងទូទឹកកកវិញ ហើយភ្លាសសេឲ្យត្រជាក់ដល់សីតុណ្ហភាព 5 អង្សាសេ ឬទាបជាង

### រហូតដល់ 4 ម៉ោង

- បម្រើអាហារដែលអាចបរិភោគបានភ្លាមៗ ឬ
- ចំអិនអាហារឲ្យដល់សីតុណ្ហភាព 75 អង្សាសេ

### 4 ម៉ោងជាង

បោះវាចោល

S

បង្ហាញ

## តើអ្នកត្រូវបង្ហាញអ្វីខ្លះ?

- អ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនឹងពិនិត្យ៖
    - **កំណត់ត្រា** បញ្ជីក្រុមហ៊ុនផ្គត់ផ្គង់ដែលមានការទទួលស្គាល់ត្រឹមត្រូវ និងការធានារបស់ក្រុមហ៊ុនផ្គត់ផ្គង់
    - **កំណត់ត្រា** ស្ដីពី៖
        - ឈ្មោះ និងព័ត៌មានទាក់ទងលម្អិតរបស់ក្រុមហ៊ុនផ្គត់ផ្គង់
        - ប្រភេទ និងបរិមាណអាហារ
        - សីតុណ្ហភាពនៃអាហារ ប្រសិនបើវាត្រូវការរក្សានៅក្នុងសីតុណ្ហភាពជាក់លាក់មួយដើម្បីធានាថាវាមានសុវត្ថិភាព និងសមរម្យ។
- បង្ហាញដល់អ្នកផ្ទៀងផ្ទាត់របស់លោកអ្នកថាអាហារត្រូវបានរក្សាទុក ដាក់ស្លាក និងគ្របជិត។

# ការចំអិនអាហារ

K

ដឹង

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- អាហារមួយចំនួនទំនងជាអាចឆ្លងមេរោគដែលអាចធ្វើឲ្យមនុស្សឈឺ ឬស្លាប់បាន។
- ការចំអិនគឺជាវិធីទូទៅមួយដើម្បីសម្លាប់មេរោគទាំងនេះ និងធ្វើឲ្យអាហារមានសុវត្ថិភាពសម្រាប់បរិភោគ។
- អាហារដែលត្រូវចំអិនដើម្បីឲ្យមានសុវត្ថិភាពរួមមានសាច់បសុបក្សី និងសាច់ផ្សេងទៀត។

D

ធ្វើ

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

- ចំអិនសាច់បសុបក្សី សាច់ម៉ត់ និងថ្លើមមាន់ដោយប្រើ **ប័ណ្ណស្ដីពី ‘ការចំអិនសាច់បសុបក្សី សាច់ម៉ត់ និងថ្លើមមាន់’។** សាច់ផ្សេងទៀតអាចបរិភោគឆៅបាន ប៉ុន្តែត្រូវតែដុតដោយកម្ដៅខ្លាំងហើយលឿនមុនពេលយកមកបរិភោគ។
- ត្រូវអនុវត្តតាមរាល់ការណែនាំរបស់ក្រុមហ៊ុនផលិតស្ដីពីដំណើការចំអិនអាហារដែលត្រូវរៀបចំ និងអាហារដែលអាចបរិភោគបានភ្លាម/គ្រឿងផ្សំ។
- ជានិច្ចកាល ពិនិត្យមើលរកចំណុចត្រជាក់របស់ម្ហូប វាត្រូវតែចំអិនឲ្យបានស្មើគ្នា និងសព្វកន្លែងទាំងអស់។
- ត្រូវកូរម្ហូបញឹកញាប់ដើម្បីកុំឲ្យមានចំណុចត្រជាក់។
- អាហារឆ្អិនដែលទុកចន្លោះសីតុណ្ហភាពពី 5 អង្សាសេ និង 60 អង្សាសេ អាចកម្ដៅវាឡើងវិញឲ្យឡើងដល់លើស 75 អង្សាសេ និងបរិភោគក្ដៅ (លើស 60 អង្សាសេ) ក្នុងរយៈពេល 4 ម៉ោង បើមិនដូច្នេះទេ យើងត្រូវបោះវាចោល។

# D

ធ្វើ

- ពិនិត្យសីតុណ្ហភាពអាហាររបស់លោកអ្នកដោយ៖
  - ☐ ការប្រើប្រដាប់វាស់សីតុណ្ហភាពដើម្បីពិនិត្យសីតុណ្ហភាពខាងក្នុងនៃអាហារ ឬ
  - ☐ ការប្រើប្រដាប់វាស់សីតុណ្ហភាពដោយប្រើរលកពន្លឺដើម្បីវាស់សីតុណ្ហភាពផ្ទៃខាងក្រៅនៃអាហារ ឬ
  - ☐ ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិដើម្បីពិនិត្យសីតុណ្ហភាពខាងក្នុង ឬផ្ទៃខាងក្រៅនៃចំណីអាហារ។

# S

បង្ហាញ

## តើអ្នកត្រូវបង្ហាញអ្វីខ្លះ?

- បង្ហាញដល់អ្នកផ្ទៀងផ្ទាត់របស់លោកអ្នកពីវិធីដែលលោកអ្នកប្រើដើម្បីអាចដឹងបានថាអាហាររបស់លោកអ្នកចំអិនបានល្អជានិច្ច ដោយការ៖
  - វាស់សីតុណ្ហភាពអាហារនិមួយដែលលោកអ្នកចំអិន និង/ឬ
  - ប្រើប្រាស់សេចក្តីណែនាំរបស់ក្រុមហ៊ុនផលិត។

# ចំអិនសាច់បសុបក្សី សាច់ម៉ត់ និងថ្លើមមាន់

K

ដឹង

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- ការចំអិនអាហារឲ្យបានឆ្អិនល្អអាចសម្លាប់មេរោគដែលបង្កគ្រោះថ្នាក់បាន។
- អាហារមួយចំនួនត្រូវតែចំអិនឲ្យឆ្អិនល្អដើម្បីសម្លាប់មេរោគ។ លោកអ្នកត្រូវតែដឹងថាអាហារណាមួយដែលមានហានិភ័យខ្ពស់ និងត្រូវតែចំអិនឲ្យឆ្អិនល្អរាល់ពេល (ឧទាហរណ៍ សាច់មាន់)។
- ការកិនសាច់ឲ្យម៉ត់មានន័យថាមេរោគណាដែលនៅផ្ទៃខាងក្រៅអាចរាលដាលពេញអាហារទាំងមូល។ ផលិតផលសាច់ម៉ត់ត្រូវតែចំអិនឲ្យឆ្អិនល្អ។
- លោកអ្នកមិនចាំបាច់វាស់សីតុណ្ហភាពសាច់បសុបក្សីដែលបានកាត់ជាចំណិតស្តើងៗទេ។

D

ធ្វើ

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

- ចំអិនសាច់បសុបក្សី (ឧទាហរណ៍ សាច់មាន់ សាច់ទា ថ្លើមមាន់) និងសាច់ម៉ត់ ឬសាច់កិន (ឧទាហរណ៍ សាច់ក្រក សាច់ប៉ាតេ) ឲ្យដល់សីតុណ្ហភាពជាក់លាក់មួយសម្រាប់រយៈពេលកំណត់មួយដើម្បីធានាថាសាច់ទាំងនេះមានសុវត្ថិភាព។
- ជានិច្ចកាលត្រូវប្រើប្រាស់ការបន្សំនៃពេល/សីតុណ្ហភាព បើលោកអ្នកចំអិនសាច់បសុបក្សី សាច់ម៉ត់ ឬសាច់កិន ឬថ្លើមមាន់៖

| សីតុណ្ហភាពខាងក្នុង | ពេលវេលាអប្បបរមានៅសីតុណ្ហភាព |
|---|---|
| 65 អង្សាសេ | 15 នាទី |
| 70 អង្សាសេ | 3 នាទី |
| 75 អង្សាសេ | 30 វិនាទី |

**D**

**ធ្វើ**

- ប្រើប្រដាប់វាស់សីតុណ្ហភាពដើម្បីពិនិត្យមើលថាចំណុចកណ្តាលនៃផ្នែកក្រាស់ជាងគេបំផុតនៃសាច់និង/ឬសាច់បសុបក្សីដែលក្រាស់ជាង 4 សម បានឈានដល់ពេល/សីតុណ្ហភាពមួយនៃបន្សំពេល/សីតុណ្ហភាពដូចបានចែងខាងលើ។
- លោកអ្នកត្រូវតែ៖
  - កត់ត្រាសីតុណ្ហភាពយ៉ាងហោចណាស់អាហារមួយដុំដែលយកចេញពីក្រុមនិមួយៗ ឬ
  - លោកអ្នកត្រូវតែធ្វើតេស្តក្រុមសាច់បសុបក្សីនិមួយៗ ឬសាច់ម៉ត់ដែលលោកអ្នកចំអិន លុះត្រាតែលោកអ្នកអាចបញ្ជាក់ថាវិធីចំអិនរបស់លោកមានប្រសិទ្ធិភាពគ្រប់ពេល។ សូមអានវគ្គ **ប័ណ្ណស្តីពី 'ការបញ្ជាក់ពីវិធីដែលអ្នកប្រើដើម្បីសម្លាប់មេរោគមានប្រសិទ្ធិភាពគ្រប់ពេល'**។

| ដំណើរការចំអិន<br>ខ្ញុំពិនិត្យរាល់ពេល៖ | ដំណើរការចំអិន<br>ខ្ញុំនឹង 'បញ្ជាក់'៖ |
|---|---|
| | |
| | |
| | |

- បោះចោលសាច់បសុបក្សី និងសាច់ម៉ត់ឆ្អិនណាដែលបានរក្សាទុកក្នុងសីតុណ្ហភាពពីរវាង 5 អង្សាសេ និង 60 អង្សាសេ ហើយកំដៅឡើងវិញដល់សីតុណ្ហភាពលើស 75 អង្សាសេ ប៉ុន្តែមិនបានបរិភោគក្នុងរយៈពេល 4 ម៉ោង។

**S**

**បង្ហាញ**

## តើអ្នកត្រូវបង្ហាញអ្វីខ្លះ?

- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់លោកអ្នក **នូវកំណត់ត្រា** ស្តីពីវិធីចំអិនសាច់បសុបក្សី និងសាច់ម៉ត់ប្រកបដោយសុវត្ថិភាព។ **កំណត់ត្រា៖**
  - អាហារ
  - កាលបរិច្ឆេទដែលបានចំអិន
  - សីតុណ្ហភាព ដែលអាហារបានចំអិនដល់ និងរយៈពេលដែលអាហារនេះស្ថិតក្នុងសីតុណ្ហភាពនេះ។
- ប្រសិនបើលោកអ្នកអាចបញ្ជាក់ថាវិធីចំអិនរបស់លោកអ្នកមានប្រសិទ្ធិភាព សូមបង្ហាញដល់អ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវកំណត់ត្រាដែលតម្រូវឲ្យមាននៅក្នុង **ប័ណ្ណស្តីពី 'ការបញ្ជាក់ថាវិធីដែលលោកអ្នកប្រើដើម្បីសម្លាប់មេរោគមានប្រសិទ្ធិភាពរាល់ពេល'**។

# ការបញ្ជាក់ពីវិធីដែលអ្នកប្រើដើម្បីសម្លាប់មេរោគដែលមានប្រសិទ្ធិភាពគ្រប់ពេល

**K**

**ដឹង**

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- ប្រសិនបើលោកអ្នកធ្វើ ឬចំអិនអាហារដូចខាងក្រោម លោកអ្នកអាចបញ្ជាក់ថាវិធីរបស់លោកអ្នកមានប្រសិទ្ធិភាពក្នុងការសម្លាប់មេរោគបានគ្រប់ពេល៖
    - សាច់បសុបក្សី (ឧទាហរណ៍ សាច់មាន់ ថ្លើម)
    - សាច់ម៉ត់ (ឧទាហរណ៍ សាច់ក្រក សាច់ប៉ាតេ)
    - ការសម្ងួត
    - សាច់និង/ឬបន្លែជ្រក់ ឬត្រាំទឹកអំបិល
    - សាច់ ឬគ្រឿងសមុទ្រឆ្អើរក្តៅ
    - សុស៊ី (ធ្វើពីបាយមានបន្ថែមជាតិជូរ)
    - ទាខ្វៃតាមរបៀបចិន
    - ចំអិនដោយដាក់សាច់ក្នុងថង់គ្មានខ្យល់ និងត្រាំក្នុងឆ្នាំងទឹកទៅតាមសីតុណ្ហភាពត្រូវការ (sous vide) (សាច់ ឬសាច់បសុបក្សី)។
- ការបញ្ជាក់ថាវិធីរបស់លោកអ្នកមានប្រសិទ្ធិភាព គឺមានន័យថាលោកអ្នកមិនចាំបាច់ត្រូវធ្វើតេស្តលើអាហារគ្រប់មុខ រាល់ពេលដែលលោកអ្នកធ្វើវានោះទេ។

**D**

**ធ្វើ**

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

- កំណត់វិធីដែលលោកអ្នកនឹងបញ្ជាក់៖ (គូសយកតាមសមស្រប)
    - ☐ សាច់បសុបក្សី (ឧទាហរណ៍ សាច់មាន់ ថ្លើម)
    - ☐ សាច់ម៉ត់ (ឧទាហរណ៍ សាច់ក្រក សាច់ប៉ាតេ)
    - ☐ ការសម្ងួត
    - ☐ សាច់និង/ឬបន្លែជ្រក់ ឬត្រាំទឹកអំបិល

# D

## ធ្វើ

- ☐ សាច់ ឬគ្រឿងសមុទ្រឆ្អើរក្តៅ
- ☐ សុស៊ី (ធ្វើពីបាយមានបន្ថែមជាតិជូរ)
- ☐ ទាខ្វៃតាមរបៀបចិន
- ☐ ចំអិនដោយដាក់សាច់ក្នុងថង់គ្មានខ្យល់ និងត្រាំក្នុងឆ្នាំងទឹកទៅតាមសីតុណ្ហភាពត្រូវការ (sous vide) (សាច់ ឬសាច់បសុបក្សី)។

- លោកអ្នកត្រូវតែប្រើឧបករណ៍ដដែល និងគ្រឿងផ្សំដដែល (ប្រភេទ ទម្ងន់ ទំហំ ទឹកខ្ទះ ។ល។) នៅរាល់ពេលដែលលោកអ្នកធ្វើអាហារ។
- ធ្វើ ឬចំអិនអាហារ/ឧបករណ៍ចំអិនអាហារដោយប្រើនិតិវិធីស្តង់ដារយកពីប័ណ្ណពាក់ព័ន្ធ។
- ពិនិត្យ/ធ្វើតេស្តអាហារដើម្បីធានាថា វាអាចឆ្លើយតបទៅនឹងកម្រិតដែលតម្រូវឲ្យធ្វើតាម (ឧទាហរណ៍ ផលិតផលសាច់បសុបក្សី និងសាច់ម៉ត់ត្រូវចំអិនឲ្យដល់សីតុណ្ហភាព 75 អង្សាសេ ក្នុងរយៈពេលយ៉ាងហោចណាស់ 30 វិនាទី កម្រិត pH នៃបាយមានបន្ថែមជាតិជូរក្នុងកម្រិត 4.6 ឬក៏ទាបជាងនេះ ឆ្នាំងទឹកចំអិនស្ថិតក្នុងសីតុណ្ហភាពត្រឹមត្រូវសម្រាប់ sous vide)។
- ប្រសិនបើវិធីតាមស្តង់ដាររបស់លោកអ្នកមិនឆ្លើយតបទៅនឹងសីតុណ្ហភាព/កម្រិតដែលតម្រូវឲ្យទេ លោកអ្នកត្រូវកែសម្រួលសីតុណ្ហភាព/គ្រឿងផ្សំរបស់លោកអ្នកដើម្បីធ្វើឲ្យវិធីរបស់លោកអ្នកមានប្រសិទ្ធិភាព។
- ពិនិត្យមើលថាវិធីរបស់លោកអ្នកមានប្រសិទ្ធិភាពចំនួន 3ដងទៅលើក្រុមអាហារប្រភេទផ្សេងៗគ្នាដើម្បីឲ្យលោកអ្នកអាចដឹងថាវាមានប្រសិទ្ធិភាព។
- កត់ត្រាវិធី និងការពិនិត្យរបស់លោកអ្នក។
- ពិនិត្យមើលថាវិធីរបស់លោកអ្នកមានប្រសិទ្ធិភាពរាល់សប្តាហ៍ដោយពិនិត្យមើលសីតុណ្ហភាពនៃអាហារមួយក្រុម។

# S

## បង្ហាញ

### តើលោកអ្នកត្រូវបង្ហាញអ្វីខ្លះ?

- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ**កំណត់ត្រា** អំពី៖
  - វិធីរបស់លោកអ្នក
  - ការពិនិត្យក្រុមអាហារប្រចាំសប្តាហ៍របស់លោកអ្នក។

# ការកំដៅអាហារឡើងវិញ

**K**

**ដឹង**

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- លោកអ្នកត្រូវតែកំដៅអាហារឡើងវិញឲ្យមានសុវត្ថិភាពដើម្បីឲ្យដឹងថាវាមិនស្ថិតនៅក្នុងតំបន់សីតុណ្ហភាពគ្រោះថ្នាក់ (5អង្សាសេ–60 អង្សាសេ)។
- ប្រសិនបើលោកអ្នកមិនកំដៅអាហារឡើងវិញឲ្យបានត្រឹមត្រូវទេ មេរោគនឹងលូតលាស់ ហើយធ្វើឲ្យអាហារគ្មានសុវត្ថិភាព និងមិនសមរម្យ។
- ម៉ាស៊ីនលក់អាហារត្រូវកំដៅអាហារឡើងវិញឲ្យមានសុវត្ថិភាព។
- រទេះកំដៅអាហារ និងទូក្ដៅមិនកំដៅអាហារឡើងវិញទេ។ ឧបករណ៍ទាំងនេះអាចរក្សាអាហារឲ្យក្ដៅអ៊ុនៗ នៅពេលអាហារឆ្អិន ឬកំដៅឡើងវិញរួច។

**D**

**ធ្វើ**

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

- ប្រើឧបករណ៍ត្រឹមត្រូវដើម្បីកំដៅអាហារឡើងវិញឲ្យបានលឿន៖ (គូសយកឧបករណ៍សមស្រប)
  - ☐ ឆ្នាំងកម្ដៅមីក្រូវ៉េវ (microwave)
  - ☐ ចង្ក្រាន (stovetop)
  - ☐ ឡ
  - ☐ ផ្សេងទៀត ______________________
- កំដៅអាហារឡើងវិញរហូតដល់ចេញចំហាយក្ដៅ (យ៉ាងហោចណាស់ក្នុងកម្រិត 75 អង្សាសេ) ក្នុងផ្នែកដែលត្រជាក់ជាងគេ (បើវាជាអាហាររាវ) ឬផ្នែកកណ្ដាល (បើវាជាអាហាររឹង) ហើយរក្សាទុកក្នុងសីតុណ្ហភាពលើសពី 60 អង្សាសេ រហូតដល់យកវាមកប្រើប្រាស់។

## D

ធ្វើ

- អាហារកំដៅឡើងវិញដែលត្រូវបានរក្សាទុកក្នុងចន្លោះសីតុណ្ហភាពពី 5 អង្សាសេ និង 60 អង្សាសេ ត្រូវយកវាមកកំដៅឡើងវិញឲ្យដល់កម្រិតលើសពី 75 អង្សាសេ និង បរិភោគនៅពេលវាក្តៅ (លើស 60 អង្សាសេ) ក្នុងរយៈពេល 4 ម៉ោង បើមិនដូច្នេះទេ ត្រូវបោះវាចោល។
- ម៉ាស៊ីនលក់អាហារដែលអាចកំដៅអាហារឡើងវិញបានត្រូវកំដៅអាហារឡើងវិញឲ្យសីតុណ្ហភាពឡើងដល់យ៉ាងហោចណាស់ 75 អង្សាសេនៅក្នុងផ្នែកដែលត្រជាក់ជាងគេ និងរក្សាអាហារឲ្យនៅលើសពី 60 អង្សាសេរហូតដល់ពេលយកវាទៅប្រើ។

## S

បង្ហាញ

### តើអ្នកត្រូវបង្ហាញអ្វីខ្លះ?

- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ៖
  - របៀបដែលអ្នកប្រើក្នុងការកំដៅអាហារឡើងវិញក្នុងកម្រិតសីតុណ្ហភាពលើសពី 75 អង្សាសេ
  - វិធីដែលលោកអ្នកអាចដឹងបានថា អាហារដែលលោកអ្នកកំដៅវាឡើងមានសីតុណ្ហភាពលើសពី 75 អង្សាសេ
  - វិធីដែលលោកអ្នកអាចដឹងបានថា ម៉ាស៊ីនលក់អាហាររបស់លោកអ្នកអាចកំដៅអាហារឡើងវិញឲ្យមានសុវត្ថិភាព។

ការធ្វើ + ការចំអិន

# ការធ្វើឲ្យអាហារដែលចំអិនថ្មីៗឲ្យត្រជាក់

**K**

ដឹង

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- លោកអ្នកត្រូវធ្វើអាហារឲ្យត្រជាក់ឲ្យបានត្រឹមត្រូវ ដើម្បីកុំឲ្យវាស្ថិតក្នុងតបន់សីតុណ្ហភាពគ្រោះថ្នាក់ (5អង្សាសេ–60 អង្សាសេ) ដែលជារយៈពេលយូរល្មមសម្រាប់ឲ្យមេរោគលូតលាស់ដល់កម្រិតគ្មានសុវត្ថិភាព។
- បើលោកអ្នកមិនធ្វើឲ្យអាហារក្តៅត្រជាក់បានរហ័សទេ មេរោគនឹងលូតលាស់ ហើយវាធ្វើឲ្យអាហាររបស់លោកអ្នកគ្មានសុវត្ថិភាព និងមិនសមរម្យ។

**D**

ធ្វើ

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

- ធ្វើឲ្យអាហារត្រជាក់បានរហ័ស ដើម្បីបញ្ឈប់មេរោគមិនឲ្យលូតលាស់ ឬមិនឲ្យវាផលិតជាតិពុល។
- នៅពេលលោកអ្នកធ្វើឲ្យអាហារចម្អិនថ្មីៗត្រជាក់ វាត្រូវតែមានសីតុណ្ហភាពចាប់ពី៖
  - 60 អង្សាសេ ទៅ 5 អង្សាសេ (ឬទាបជាងនេះ) ក្នុងរយៈពេលតិចជាង 6 ម៉ោង បើមិនអញ្ចឹងទេយើងត្រូវបោះវាចោល
  - 60 អង្សា ដល់សីតុណ្ហភាពក្នុងបន្ទប់ ឬ 21 អង្សាសេ (យកមួយណាដែលត្រជាក់ជាង) ក្នុងរយៈពេលតិចជាង 2 ម៉ោង បន្ទាប់មកសីតុណ្ហភាពក្នុងបន្ទប់ ឬ 21 អង្សាសេ (យកមួយណាដែលត្រជាក់ជាង) ចុះដល់ 5 អង្សាសេ (ឬទាបជាងនេះ) ក្នុងរយៈពេលតិចជាង 4 ម៉ោង។
- ប្រើប្រាស់វិធីណាមួយ (ឬបន្សំ) នៃវិធីទាំងនេះ៖ (គូសយកវិធីសមស្រប)៖
  - ☐ ដាក់អាហាររបស់លោកអ្នកទៅក្នុងប្រដាប់ដាក់អាហាររាក់
  - ☐ ប្រើប្រាស់ផើងដាក់ទឹកកក

# D
ធ្វើ

- ☐ ដាក់អាហាររបស់លោកអ្នកឲ្យនៅដាច់ពីគ្នាជាចំណែកតូចៗ។
- ☐ ដាក់អាហាររបស់លោកអ្នកទៅក្នុងម៉ាស៊ីនក្លាសសេបាញ់ខ្យល់ត្រជាក់ខ្លាំង (blast chiller)

- នៅពេលអាហាររបស់លោកអ្នកស្ថិតក្នុងសីតុណ្ហភាពក្នុងបន្ទប់ ឬសីតុណ្ហភាព 21 អង្សាសេ (យកមួយណាដែលត្រជាក់ជាង) សូមយកវាទៅទុកនៅក្នុងទូទឹកកក ឬទូក្លាសសេ។
- ត្រូវពិនិត្យមើលថាបន្ទាប់ពី 4 ម៉ោង អាហារស្ថិតក្នុងសីតុណ្ហភាព 5 អង្សាសេ ឬទាបជាងនេះ។
- បោះចោលអាហារណាដែលចំអិនថ្មីៗ ដែលបានស្ថិតក្នុងតំបន់សីតុណ្ហភាពគ្រោះថ្នាក់យូរជាង 6 ម៉ោង។

# S
បង្ហាញ

## តើអ្នកត្រូវបង្ហាញអ្វីខ្លះ?

- បង្ហាញ ឬពិពណ៌នាប្រាប់អ្នកផ្ទៀងផ្ទាត់របស់លោកអ្នក ពីវិធីដែលលោកអ្នកធ្វើអាហារដែលចំអិនថ្មីៗឲ្យត្រជាក់បានរហ័ស។
- បង្ហាញដល់អ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ **កំណត់ត្រា** ស្តីពីវិធីដែលលោកអ្នកទុកក្រុមអាហារដែលចំអិនថ្មីៗនិមួយៗឲ្យត្រជាក់ប្រកបដោយសុវត្ថិភាព (គឺថា មានសីតុណ្ហភាព 60 អង្សាសេ ដល់សីតុណ្ហភាពក្នុងបន្ទប់ ឬ 21 អង្សាសេ (យកមួយណាដែលត្រជាក់ជាង) ក្នុងរយៈពេល 2 ម៉ោង, បន្ទាប់មកសីតុណ្ហភាពក្នុងបន្ទប់ ឬ 21 អង្សាសេ (យកមួយណាដែលត្រជាក់ជាង) ដល់ 5 អង្សាសេ (ឬក្រោមនេះ) ក្នុងរយៈពេលតិចជាង 4 ម៉ោង។
- កត់ត្រាទុក៖
  - អាហារ
  - កាលបរិច្ឆេទពេលអាហារត្រូវបានចំអិន
  - រយៈពេលដែលត្រូវការដើម្បីធ្វើឲ្យអាហារត្រជាក់។

# ការរំលាយទឹកកកពីអាហារ

**K**

**ដឹង**

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- ទឹកហៀរចេញពីអាហារដែលបានរំលាយទឹកកកអាចមានមេរោគដែលបង្កគ្រោះថ្នាក់។ ប្រសិនបើទឹកទាំងនេះប៉ះទៅលើអាហារ និងកន្លែងផ្សេងទៀត វាអាចធ្វើឲ្យមនុស្សឈឺបាន។
- ប្រសិនបើអាហារគ្រាន់តែបានរំលាយទឹកកកចេញតែមួយផ្នែកទេ វាអាចឡើងមិនដល់សីតុណ្ហភាពត្រឹមត្រូវក្នុងអំឡុងពេលចំអិនដើម្បីសម្លាប់មេរោគឡើយ។

**D**

**ធ្វើ**

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

- ធ្វើផែនការជាមុន ប្រសិនបើប្រើអាហារកកដើម្បីឲ្យលោកអ្នកមានពេលគ្រប់គ្រាន់ដើម្បីរំលាយទឹកកកចេញឲ្យមានសុវត្ថិភាព មិនថានៅក្នុងទូទឹកកកឬក៏ទូក្លាសសេឡើយ។
- នៅពេលទទួល ត្រូវរំលាយទឹកកកចេញពីផលិតផលដោយធ្វើតាមការណែនាំរបស់ក្រុមហ៊ុនផលិត។
- ត្រូវទុកអាហារដែលកំពុងរំលាយទឹកកកនៅក្នុងប្រដាប់ដាក់អាហារ និងក្បែរបាតទូទឹកកក/ទូក្លាសសេដើម្បីបញ្ឈប់កុំឲ្យហៀរទឹករាលដាលដល់ផ្ទៃលើ និងអាហារផ្សេងទៀត។
- ប្រសិនបើលោកអ្នកមិនអាចរំលាយទឹកកកចេញពីអាហារនៅក្នុងទូទឹកកក/ក្លាសសេបានទេ លោកអ្នកអាចប្រើវិធីណាមួយ (ឬបន្សំ)នៃវិធីទាំងនេះ៖ (គូសយកវិធីដែលសមស្រប)
  - ☐ រំលាយទឹកកកនៅក្នុងឆ្នាំងកម្តៅមីក្រូវ៉េវ (microwave) និងប្រើប្រាស់អាហារនោះភ្លាម។
  - ☐ រំលាយទឹកកកនៅក្នុងទឹកត្រជាក់ចេញពីក្បាលម៉ាស៊ីនទឹកនៅក្នុងប្រដាប់ដាក់អាហារដែលបិទជិត។

D

ធ្វើ

□ រំលាយទឹកកកចេញពីអាហារដោយទុកវានៅលើតុក្នុងរយៈពេលមិនឲ្យលើសពី 4 ម៉ោង

- នៅពេលទឹកកករលាយហើយ អាហារដែលធម្មតាត្រូវរក្សាឲ្យត្រជាក់ ឬរក្សាឲ្យនៅក្ដៅ ត្រូវតែដាក់ក្លាសសេឡើងវិញ ចំអិន ឬរក្សាវាឲ្យនៅក្ដៅ។
- អាហារត្រូវតែរលាយទឹកកកឲ្យអស់មុនពេលកំដៅ ឬចំអិន។

S

បង្ហាញ

## តើអ្នកត្រូវបង្ហាញអ្វីខ្លះ?

- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ៖
  - វិធីដែលលោកអ្នកប្រើដើម្បីរំលាយទឹកកកចេញពីអាហារ
  - វិធីដែលលោកអ្នកប្រើដើម្បីរំលាយទឹកកកចេញពីអាហារឲ្យមានសុវត្ថិភាព។

ការធ្វើ + ការចំអិន

# ការប្រើសកម្មភាពទឹក អាស៊ីត ឬឆ្អើរក្តៅដើម្បីគ្រប់គ្រងមេរោគ

K

ដឹង

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- មេរោគដែលបង្កគ្រោះថ្នាក់ វាត្រូវការសំណើមដើម្បីរីកលូតលាស់។ កាត់បន្ថយបរិមាណសំណើម ចំនួន (សកម្មភាពទឹក) នៃអាហាររបស់លោកអ្នក នឹងជួយបញ្ឈប់ការលូតលាស់របស់មេរោគ
- មេរោគគ្រោះថ្នាក់ជាច្រើនមិនអាចលូតលាស់ ឬអាចលូតលាស់បានយ៉ាងយឺតៗ នៅក្នុងបរិស្ថានដែលមានជាតិអាស៊ីត (ដែលមានកម្រិត pH 4.6 ឬតិចជាង)។
- ដើម្បីសម្រេចលក្ខខណ្ឌខាងលើ (និមួយៗ) បាន៖
    - យកទឹកចេញ (សម្ងួត ឬ ប្រឡាក់ទឹកអំបិល) ដើម្បីសម្រេចឲ្យបានសកម្មភាពទឹក 0.85 ឬទាបជាងនេះ
    - បន្ទាបកម្រិត pH (ជ្រក់) ឲ្យដល់កម្រិត 4.6 ឬទាបជាងនេះ។
- ការឆ្អើរក្តៅអាចជួយបញ្ឈប់មេរោគមិនឲ្យលូតលាស់នៅក្នុងអាហារ ប៉ុន្តែវាអាចត្រូវការការកែច្នៃបន្ថែម ឬរក្សាទុកឲ្យត្រជាក់ដើម្បីធានាបានថាវាមានសុវត្ថិភាព។ វាអាចប្រើដើម្បីចំអិន ឬបន្ថែមរស់ជាតិដល់អាហារ។
- និតិវិធីនេះអនុវត្តចំពោះមនុស្សចូលចិត្តអាហារខាប់ និងស្ងួត។
- ក្រសួងឧស្សាហកម្មវត្ថុធាតុដើមបានចងក្រងសៀវភៅណែនាំមួយដើម្បីជួយលោកអ្នកឲ្យគណនាជីវិតនៃអាហារដែលមាននៅ http://www.foodsafety.govt.nz/elibrary/industry/determine-shelf-life-of-food/
- មានបទដ្ឋាននៅក្នុងក្រមស្តង់ដារចំណីអាហារនៃប្រទេសអូស្ត្រាលី និងនូវ៉ែលហ្សឺឡង់ (ក្រម) ស្តីពីប្រភេទនៃគ្រឿងបន្ថែមក្នុងអាហារ (ឧទាហរណ៍ ថ្នាំបង្ការមិនឲ្យអាហារខូច) ដែលលោកអ្នកអាចយកមកដាក់បន្ថែមក្នុងអាហារមួយចំនួនបាន។ សូមពិនិត្យមើលក្រម ឬសុំព័ត៌មានបន្ថែមពីអ្នកផ្គៀងផ្ទាត់របស់លោកអ្នក។

D

ធ្វើ

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

## កាត់បន្ថយសកម្មភាពទឹក

### ការសម្ងួត

- ផលិតផលអាហារស្ងួតត្រូវតែមានសកម្មភាពទឹកក្នុងកម្រិត 0.85 ឬទាបជាងនេះ លើកលែងតែ វាអាច៖ (គូសយកចំណុចសមស្រប)
  - ☐ រក្សាទុកឲ្យត្រជាក់ក្នុងសីតុណ្ហភាព 5 អង្សាសេ ឬទាបជាងនេះ រហូតដល់ពេលត្រូវយកវាទៅប្រើប្រាស់
  - ☐ អាស្រ័យទៅលើវិធីផ្សេងទៀតដែលមានសុពលភាព ក្នុងការបង្ការអាហារមិនឲ្យខូច (ឧទាហរណ៍ ការកាត់បន្ថយកម្រិត pH)
- ឧបករណ៍សម្ងួតទាំងអស់ (ឧទាហរណ៍ ម៉ាស៊ីនកម្ដៅ កង្ហារ ម៉ាស៊ីនសំណើម) ត្រូវតែពិនិត្យជាទៀងទាត់ថាម៉ាស៊ីនទាំងនេះមានដំណើរត្រឹមត្រូវ។
- ការសម្ងួតត្រូវធ្វើឡើង៖ (គូសយកចំណុចសមស្រប)
  - ☐ ក្នុងកន្លែងដែលមានការគ្រប់គ្រងសីតុណ្ហភាព
  - ☐ ក្នុងសីតុណ្ហភាពខ្យល់ជុំវិញ។
- ប្រសិនបើលោកអ្នកកំពុងធ្វើអាហារដោយប្រើសកម្មភាពទឹកក្នុងកម្រិត 0.85 ឬទាបជាងនេះ លោកអ្នកត្រូវតែធ្វើតេស្តដើម្បីធានាថាពួកគេសម្រេចបានគោលដៅនេះ។
- ប្រសិនបើលោកអ្នកបានបញ្ជាក់ពីវិធីសម្រាប់សម្ងួតអាហាររបស់អ្នកដោយមានសកម្មភាពទឹកក្នុងកម្រិត 0.85 ឬទាបជាងនេះ លោកអ្នកត្រូវតែបញ្ជូនផលិតផល 3 ក្រុមទៅមន្ទីរពិសោធន៍ដែលមានការទទួលស្គាល់ត្រឹមត្រូវឲ្យធ្វើតេស្តសកម្មភាពទឹក។ ការធ្វើតេស្តនេះត្រូវតែធ្វើយ៉ាងហោចណាស់ម្ដងនៅពេលដំបូង ហើយបន្ទាប់មកលោកអ្នកអាចប្រើវិធីរបស់លោកអ្នកផ្ទាល់ដើម្បីគណនាសកម្មភាពទឹក (ឧទាហរណ៍ ការបាត់បង់ទម្ងន់)។ សូមអាន ប័ណ្ណ 'ការបញ្ជាក់ពីវិធីដែលលោកអ្នកប្រើដើម្បីសម្លាប់មេរោគដែលមានប្រសិទ្ធិភាពគ្រប់ពេល'។

### ការត្រាំទឹកអំបិល

- ក្នុងអំឡុងពេលដាក់ត្រាំក្នុងទឹកអំបិល សាច់ត្រូវតែដាក់ត្រាំឲ្យលិចនៅក្នុងទឹកអំបិល។
- ចាក់ទឹកចោល ហើយសម្អាតធុងសម្រាប់ត្រាំទឹកអំបិលឲ្យបានទៀងទាត់។

D

ធ្វើ

- ពិនិត្យមើលឧបករណ៍ចាក់ មុនពេល និងក្រោយពេលប្រើប្រាស់ម្តងៗសម្រាប់ផ្នែកដែលបាក់បែក ឬបាត់។

## ធ្វើឲ្យអាហារមានជាតិអាស៊ីត

- ផលិតផលជ្រក់ត្រូវតែមានកម្រិត pH 4.6 ឬទាបជាងនេះ។

## ល្បាយទឹកអំបិល និងល្បាយទឹកសម្រាប់ធ្វើជ្រក់

- ប្រើតែគ្រឿងបន្ថែមក្នុងអាហារដែលត្រូវបានអនុញ្ញាត។ សូមអានបដ្ឋាននៅក្នុងក្រមសម្រាប់បញ្ជីរាយឈ្មោះគ្រឿងបន្ថែមដែលលោកអ្នកអាចប្រើបាន។
- ធ្វើ និងប្រើគ្រឿងសម្រាប់រៀបចំអាហារដោយអនុវត្តតាមការណែនាំរបស់ក្រុមហ៊ុនផលិត ឬសាកល្បង និងធ្វើតេស្តដោយប្រើក្បួនរបស់ខ្លួនផ្ទាល់។
- កុំពង្រាវកំហាប់នៃគ្រឿងបន្ថែមក្នុងអាហារ (ឧទាហរណ៍ ជាតិនីទ្រីត) និងអំបិលដែលចាំបាច់ដើម្បីឲ្យអាចប្រឡាក់ និងធ្វើជ្រក់បាន
- រក្សាគ្រឿងសម្រាប់រៀបចំអាហារឲ្យត្រជាក់ក្នុងសីតុណ្ហភាព 5 អង្សាសេ ឬទាបជាងនេះ។ រក្សាទុកអាហារទាំងអស់ដោយគ្របឲ្យជិតរហូតដល់ពេលយកវាមកប្រើប្រាស់។
- ចាប់ផ្តើមប្រឡាក់ទឹកអំបិល និងធ្វើជ្រក់ក្នុងសីតុណ្ហភាព 5 អង្សាសេ ឬទាបជាងនេះ។
- បោះចោលនូវគ្រឿងសម្រាប់រៀបចំអាហារដែលប្រើឡើងវិញ ឬបង្វិលមកប្រើម្តងទៀត និងគ្រឿងសម្រាប់រៀបចំអាហារដែលអាចឆ្លងមេរោគ ដូចជាគ្រឿងដែលបានប្រើប្រាស់ក្នុងពេលចាក់នៅចុងបញ្ចប់នៃក្រុមអាហារនិមួយៗ ឬប្រតិបត្តិការប្រចាំថ្ងៃ។

## ការឆ្អើរក្តៅ

- ប្រសិនបើឆ្អើរគ្រឿងសមុទ្រ សូមប្រើតែគ្រឿងសមុទ្រស្រស់។
- ប្រសិនបើការឆ្អើរជាផ្នែកមួយនៃលំនាំនៃការចំអិនផលិតផលសាច់ត្រូវចំអិនវាដល់កម្រិតសីតុណ្ហភាព 75អង្សាសេឲ្យបានយ៉ាងហោចណាស់ចំនួន 30 វិនាទី។ សូមអាន **ប័ណ្ណស្តីពី 'ចំអិនសាច់បសុបក្សី សាច់ម៉ត់ និងថ្លើមមាន់'**។
- ឧបករណ៍សម្រាប់ឆ្អើរទាំងអស់ (ឧទាហរណ៍ ម៉ាស៊ីនកំដៅ ម៉ាស៊ីនខ្យល់ កំទិចឈើ) ត្រូវតែមានសុវត្ថិភាព និងដំណើរការត្រឹមត្រូវ។

# D

ធ្វើ

- ការឆ្អើរត្រូវតែធ្វើ៖ (គូសយកចំណុចសមស្រប)
  - ☐ ក្នុងកន្លែងដែលមានការគ្រប់គ្រងសីតុណ្ហភាព
  - ☐ ដោយមានសីតុណ្ហភាពសម្រាប់ឆ្អើរដែលគ្រប់គ្រងដោយមនុស្ស។
- ផលិតផលអាហារត្រូវតែដាក់ឲ្យឃ្លាតចេញពីគ្នាស្មើៗគ្នា ដើម្បីជួយឲ្យមានចរន្តខ្យល់ និងការឆ្អើរផលិតផលឲ្យបានស្មើ។
- អនុវត្តតាមការណែនាំរបស់ក្រុមហ៊ុនផលិតនៅពេលប្រើវត្ថុរាវក្នុងការឆ្អើរ។
- បន្ទាប់ពីអាហាររបស់លោកអ្នកបានឆ្អើររួចហើយ អាហារដែលត្រូវការរក្សាទុកឲ្យត្រជាក់ត្រូវរក្សាទុកក្នុងកម្រិតសីតុណ្ហភាព 5 អង្សាសេ ឬទាបជាងនេះ ហើយត្រូវតែ៖ (គូសយកចំណុចណាមួយដែលសមស្រប)
  - ☐ ដាក់កាលបរិច្ឆេទ និងម៉ោងដែលអាហារបានឆ្អើរ និងបន្ទាប់មកប្រើប្រាស់ ឬលក់ឲ្យគេទទួលទានក្នុងរយៈពេល 5 ថ្ងៃក្រោយការឆ្អើរ
  - ☐ ដាក់ស្លាក 'ប្រើឲ្យបានមុន (use-by)' កាលបរិច្ឆេទ។
- កំណត់ហេតុផលដែលលោកអ្នកត្រូវឆ្អើរក្តៅ។ ជ្រើសរើសមួយណាដែលពាក់ព័ន្ធ៖
  - ☐ ឆ្អើរក្តៅដើម្បីចំអិនអាហារ
  - ☐ ឆ្អើរក្តៅដើម្បីឲ្យចេញរសជាតិ។
- សម្រាប់ក្រុមអាហារនិមួយៗដែលលោកអ្នកឆ្អើរក្តៅ ជាផ្នែកមួយនៃលំនាំចំអិនអាហារ លោកអ្នកត្រូវតែកត់ត្រាដូចខាងក្រោម៖
  - ◦ សីតុណ្ហភាពខ្យល់ក្នុងកន្លែងឆ្អើរ
  - ◦ ពេលចាប់ផ្តើមឆ្អើរ
  - ◦ ពេលឆ្អើរចប់
  - ◦ សីតុណ្ហភាពសំខាន់របស់អាហារនៅចុងបញ្ចប់នៃអំឡុងពេលចំអិន។
  - ◦ ប្រសិនបើត្រូវការពេលបន្ថែមសម្រាប់ចំអិន។
- សម្រាប់ក្រុមអាហារនិមួយៗដែលលោកអ្នកឆ្អើរក្តៅ ដើម្បីបន្ថែមរសជាតិលើអាហាររបស់លោកអ្នក លោកអ្នកត្រូវតែកត់ត្រាដូចខាងក្រោម៖

**D**

ធ្វើ

- ◦ សីតុណ្ហភាពខ្យល់ក្នុងកន្លែងឆ្អើរ
- ◦ រយៈពេលនៃដំណើការឆ្អើរ។

ប្រសិនបើលោកអ្នកសម្ងួត ប្រឡាក់ទឹកអំបិល ធ្វើជ្រក់ ឬឆ្អើរក្តៅផលិតផលអាហារឲ្យបានទៀងទាត់ លោកអ្នកអាចបញ្ជាក់ពីវិធីរបស់លោកអ្នកដើម្បីឲ្យលោកអ្នកអាចពិនិត្យក្រុមអាហារប្រចាំសប្តាហ៍តែប៉ុណ្ណោះ។ សូមអាន **បណ្ណស្តីពី 'បញ្ជាក់ពីវិធីដែលអ្នកប្រើដើម្បីសម្លាប់មេរោគមានប្រសិទ្ធិភាពគ្រប់ពេល'**។

---

**S**

បង្ហាញ

## តើអ្នកត្រូវបង្ហាញអ្វីខ្លះ?

### ការកាត់បន្ថយសកម្មភាពទឹក

បង្ហាញអ្នកផ្ទៀងផ្ទាត់របស់លោកអ្នក

- ◦ លទ្ធផលរបស់មន្ទីរពិសោធន៍ណាមួយ ឬលទ្ធផលចេញពីវិធីរបស់លោកអ្នកផ្ទាល់ (ឧទាហរណ៍ ការបាត់ទម្ងន់) សម្រាប់ធ្វើតេស្តសកម្មភាពទឹក (ប្រសិនបើទាក់ទង)
- ◦ វិធីដែលលោកអ្នកសម្ងួត និងប្រឡាក់ទឹកអំបិលអាហាររបស់លោកអ្នកឲ្យមានសុវត្ថិភាព
- ◦ **កំណត់ត្រា** ជាលាយល័ក្ខអក្សរ ស្តីពីវិធីសម្ងួតអាហាររបស់លោកអ្នក
- ◦ **កំណត់ត្រា** ជាលាយល័ក្ខអក្សរស្តីពីក្បួនសម្រាប់ផលិតទឹកប្រឡាក់របស់លោកអ្នក។

### ការកាត់បន្ថយកម្រិត pH

- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ៖
  - ◦ វិធីដែលលោកអ្នកប្រើដើម្បីសម្រេចបាន pH ក្នុងកម្រិតទាបជាង 4.6
  - ◦ **កំណត់ត្រា** ជាលាយល័ក្ខអក្សរស្តីពីរូបមន្តធ្វើទឹកធ្វើជ្រក់របស់លោកអ្នក។

### ការឆ្អើរក្តៅ

- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ៖
  - ◦ វិធីដែលលោកអ្នកឆ្អើរក្តៅអាហារឲ្យមានសុវត្ថិភាព។
  - ◦ ប្រសិនបើការឆ្អើរក្តៅជាផ្នែកមួយនៃដំណើរការចំអិនអាហារ សូមសូមធ្វើកំណត់ត្រាជាលាយល័ក្ខអក្សរនូវ៖

**S**

**បង្ហាញ**

   - សីតុណ្ហភាពខ្យល់ក្នុងកន្លែងឆ្អើរ
   - ពេលចាប់ផ្ដើមឆ្អើរ
   - ពេលឆ្អើរចប់
   - សីតុណ្ហភាពសំខាន់របស់អាហារនៅចុងបញ្ចប់នៃអំឡុងពេលចំអិន។
   - ប្រសិនបើត្រូវការពេលបន្ថែមសម្រាប់ចំអិន។
- ប្រសិនបើការឆ្អើរក្ដៅដើម្បីបន្ថែមរសជាតិលើអាហារ សូមធ្វើ**កំណត់ត្រា**ជាលាយលក្ខអក្សរស្ដីពី៖
   - សីតុណ្ហភាពខ្យល់ក្នុងកន្លែងឆ្អើរ
   - រយៈពេលនៃដំណើរការឆ្អើរ។

ការបម្រើ + ការលក់



# រក្សាអាហារឲ្យក្តៅ

**K**

ដឹង

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- លោកអ្នកត្រូវតែរក្សាអាហារដែលជាធម្មតាត្រូវរក្សាឲ្យត្រជាក់ ឬក្តៅ នៅក្រៅតំបន់សីតុណ្ហភាពគ្រោះថ្នាក់ (5 អង្សាសេ - 60 អង្សាសេ) ដើម្បីបញ្ឈប់មេរោគមិនឲ្យលូតលាស់ និងធ្វើឲ្យមនុស្សឈឺ។
- អាហារក្តៅត្រូវរក្សាទុកនៅសីតុណ្ហភាពលើសពី 60 អង្សាសេដើម្បីបញ្ឈប់មេរោគមិនឲ្យលូតលាស់។

**D**

ធ្វើ

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

- អនុវត្តតាមការណែនាំរបស់ក្រុមហ៊ុនផលិតសម្រាប់ការប្រើប្រាស់ឧបករណ៍។
- កំដៅអាហារឲ្យដល់សីតុណ្ហភាព 75 អង្សាសេ ឬខ្ពស់ជាងនេះ មុនពេលដាក់នៅក្នុងរទេះកំដៅ ឬទូកំដៅ។
- ឧបករណ៍របស់លោកអ្នកត្រូវអាចរក្សាអាហារឲ្យមានសីតុណ្ហភាពលើសពី 60 អង្សាសេ។ ការប្រើប្រាស់ប្រដាប់វាស់សីតុណ្ហភាពដើម្បីពិនិត្យសីតុណ្ហភាពអាហារ។
- នៅពេលអាហារត្រូវបានរក្សាឲ្យក្តៅដែលមានរយៈពេលច្រើនជាង 2 ម៉ោង សូមពិនិត្យសីតុណ្ហភាពរាល់ 2 ម៉ោងម្តង ដើម្បីឲ្យលោកអ្នកអាចដឹងបានថាវាពិតជាមានសីតុណ្ហភាពលើសពី 60 អង្សាសេ។
- ប្រសិនបើការពិនិត្យរយៈពេល 2 ម៉ោងម្តងបង្ហាញថាសីតុណ្ហភាពអាហារទាបពេក សូមកំដៅអាហារឡើងវិញឲ្យលើសពី 75 អង្សាសេ ហើយបង្កើនសីតុណ្ហភាពនៃរទេះកំដៅ ឬទូកំដៅ។ ប្រសិនបើវាមានសីតុណ្ហភាពក្រោម 60 អង្សាសេនៅពេលយើងពិនិត្យបន្ទាប់ សូម បោះវាចោលទៅ។
- ប្រសិនបើអាហារក្តៅបានស្ថិតក្នុងសីតុណ្ហភាពក្រោម 60 អង្សាសេអស់រយៈពេលជាង 2 ម៉ោង យើងត្រូវតែបោះវាចោល។

D

ធ្វើ

- ប្រសិនបើអាហារក្តៅត្រូវបានស្ថិតនៅក្នុងសីតុណ្ហភាពក្រោម 60 អង្សាសេអស់រយៈពេលជាង 2 ម៉ោង យើងអាចយកទៅ៖
    - កំដៅឡើងវិញឲ្យសព្វ និងបម្រើនៅក្តៅ (លើសពី 60 អង្សាសេ) ឬ
    - ក្លាសសេឲ្យដល់ក្រោម 5 អង្សាសេ ក្នុងរយៈពេលបួនម៉ោង និងរក្សាក្នុងសីតុណ្ហភាពនេះរហូតដល់ពេលបរិភោគ។
- កូរអាហារដើម្បីធានាបានថាវានៅក្តៅសព្វកន្លែងទាំងអស់។
- កុំដាក់ចូលគ្នានូវក្រុមអាហារចាស់ និងថ្មីដែលបានកំដៅឡើងវិញ ឬក្រុមអាហារក្តៅ ព្រមទាំងក្រុមអាហារដែលអាចបរិភោគបានភ្លាមៗ។

S

បង្ហាញ

## តើអ្នកត្រូវការបង្ហាញអ្វីខ្លះ?

- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ៖
    - វិធីដែលលោកអ្នករក្សាអាហារឲ្យនៅក្តៅ
    - វិធីដែលលោកអ្នកវាស់សីតុណ្ហភាព
    - វិធីដែលលោកអ្នកដឹងថាលោកអ្នកកំពុងពិនិត្យសីតុណ្ហភាពនៅក្នុងកម្រិតពេលវេលាតម្រូវឲ្យ។

# ការដឹកជញ្ជូនអាហាររបស់អ្នក

**K**

**ដឹង**

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- នៅពេលដឹកជញ្ជូនអាហារដែលជាធម្មតាជាអាហារដែលត្រូវរក្សាឲ្យត្រជាក់ ឬក្តៅជានិច្ច លោកអ្នកត្រូវតែចាត់ការតាមជំហានដើម្បីរក្សាអាហារឲ្យនៅក្រៅតំបន់សីតុណ្ហភាពគ្រោះថ្នាក់ (5អង្សាសេ - 60អង្សាសេ) ដើម្បីបញ្ឈប់មេរោគកុំឲ្យលូតលាស់។

**D**

**ធ្វើ**

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

### គ្រប់គ្រងសីតុណ្ហភាព

- អាហារត្រូវតែដឹកជញ្ជូន និងប្រគល់ជូនក្នុងសីតុណ្ហភាពត្រឹមត្រូវ។ លោកអ្នកត្រូវតែពិនិត្យសីតុណ្ហភាពនេះឲ្យបានទៀងទាត់។
- រក្សាអាហារកកឲ្យកក។
- ប្រគល់អាហារស្ថិតក្នុងតំបន់សីតុណ្ហភាពគ្រោះថ្នាក់បានតែនៅពេលដែលត្រូវយកទៅបរិភោគក្នុងរយៈពេល 4 ម៉ោងនៃការធ្លាក់ចូលក្នុងតំបន់សីតុណ្ហភាពគ្រោះថ្នាក់។
- ដឹកជញ្ជូនអាហារត្រជាក់ក្នុងសីតុណ្ហភាពត្រជាក់ (ក្នុងសីតុណ្ហភាព ឬក្រោម 5 អង្សាសេ) ឬដឹកជញ្ជូនអាហារក្តៅក្នុងសីតុណ្ហភាពក្តៅ (ក្នុងសីតុណ្ហភាពលើសពី 60 អង្សាសេ)។
- សូមប្រើឧបករណ៍សមស្របសម្រាប់ដឹកជញ្ជូនអាហារ ដើម្បីធានាថាអាហាររបស់លោកអ្នកមានសុវត្ថិភាព។ ប្រើប្រាស់៖(គូសយកអ្វីដែលសមស្រប)

  ☐ ស្បោង/ប្រអប់មានទ្រនាប់ការពារកំដៅ។

  ☐ ទូក្លាសសេដែលយកតាមខ្លួនបាន។

  ☐ ឧបករណ៍រក្សាអាហារឲ្យក្តៅ

  ☐ ផ្សេងទៀត ______________________

D

ធ្វើ

## រៀបចំផែនការមុននឹងដឹកជញ្ជូន

- មិនត្រូវឲ្យសត្វចូលផ្នែកណាមួយនៃយានយន្តដែលប្រើសម្រាប់ដឹកជញ្ជូនអាហារឡើយ។
- គ្រប់ផ្នែកទាំងអស់នៃយានយន្តដែលលោកអ្នកប្រើដើម្បីដឹកជញ្ជូនអាហារ ឬឧបករណ៍ធ្វើអាហារទាំងអស់ត្រូវតែស្អាត (ហើយសម្លាប់មេរោគប្រសិនបើឧបករណ៍ត្រូវប៉ះពាល់ផ្ទាល់ជាមួយនឹងអាហារដែលអាចបរិភោគភ្លាមបាន)។
- បោះចោល៖
  - អាហារណាដែលបានឆ្លងមេរោគ
  - អាហារណាដែលបានរក្សាទុកក្នុងតំបន់គ្រោះថ្នាក់ច្រើនជាង 4 ម៉ោង។

S

បង្ហាញ

## តើអ្នកត្រូវបង្ហាញអ្វីខ្លះ?

- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ៖
  - វិធីដែលលោកអ្នកប្រើ ដើម្បីធានាបានថាអាហារត្រូវរក្សាទុកក្នុងសីតុណ្ហភាពត្រឹមត្រូវ នៅពេលដឹកជញ្ជូន
  - វិធីអ្វីដែលលោកអ្នកប្រើដើម្បីរក្សាសីតុណ្ហភាព និងរក្សាអាហារឲ្យនៅដាច់ពីគ្នា ក្នុងពេលដឹកជញ្ជូន
  - យានយន្តរបស់លោកអ្នកសម្រាប់ដឹកជញ្ជូនអាហារ។
- **កំណត់ត្រា** ស្ដីពីសីតុណ្ហភាពអាហាររបស់លោកអ្នកក្នុងពេលដឹកជញ្ជូន ប្រសិនបើអាហារនោះមិនបានប្រើប្រាស់ក្នុងរយៈពេល 4 ម៉ោង។

# ការដាក់តាំងបង្ហាញអាហារ និងអតិថិជនបម្រើដោយខ្លួនឯង

**K**

ដឹង

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- អាហារអាចឆ្លងមេរោគពីមនុស្សឈឺ ឬពីសម្លៀកបំពាក់កខ្វក់។
- អតិថិជនរបស់លោកអ្នកអាចនាំមេរោគចូលក្នុងក្រុមហ៊ុនពាណិជ្ជកម្មអាហាររបស់លោកអ្នក។ មេរោគដែលបង្កគ្រោះថ្នាក់អាចឆ្លងទៅអាហារតាមរយៈលាមក កំអួត និងវត្ថុរាវចេញពីក្នុងខ្លួនមនុស្សឈឺ (ឧទាហរណ៍ ឈាម និងសំបោរ)។
- ការដាក់តាំងបង្ហាញអាហារឲ្យអតិថិជនបម្រើខ្លួនឯងមិនបានល្អអាចបង្កើនហានិភ័យនៃអតិថិជនចម្លងមេរោគទៅក្នុងអាហាររបស់លោកអ្នក (ឧទាហរណ៍ ការលូកដៃរំលងអាហារមួយទៅចាប់អាហារមួយទៀត)។

**D**

ធ្វើ

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

- អាហារដែលអាចបរិភោគបានភ្លាមសម្រាប់ឲ្យអតិថិជនជ្រើសរើសខ្លួនឯងត្រូវតែ៖ (គូសយកចំណុចសមស្រប)៖
  - ☐ ខ្ចប់ឲ្យហើយ មុនពេលដាក់តាំង ឬ
  - ☐ បានការពារដោយមានគម្រប និងប្រដាប់ការពារការកណ្ដាស់។
- ប្រសិនបើលោកអ្នកកំពុងបម្រើអាហារក្ដៅ លោកអ្នកត្រូវតែអនុវត្តបទដ្ឋានសម្រាប់ **'រក្សាអាហារឲ្យនៅក្ដៅ'**។
- ដាក់តាំងអាហារដែលអាចបរិភោគបានភ្លាមដែលជាធម្មតាត្រូវរក្សាឲ្យត្រជាក់ ឬក្ដៅមិនឲ្យលើសពី 4 ម៉ោង (ក្រោយពីអាហារបានស្ថិតនៅក្នុងសីតុណ្ហភាពរវាង 5 អង្សាសេ និង 60អង្សាសេ ច្រើនជាង4 ម៉ោង ត្រូវបោះវាចោល)។

**D**

ធ្វើ

- ជានិច្ចកាល ត្រូវផ្តល់ប្រដាប់ប្រើស្អាតសម្រាប់បម្រើអាហារ។ ដៃកាន់ប្រដាប់ប្រើសម្រាប់បម្រើអាហារមិនត្រូវឲ្យប៉ះនឹងអាហារទេ។ ដូរប្រដាប់សម្រាប់បម្រើអាហារនៅពេលវាកខ្វក់ (ឧទាហរណ៍ អតិថិជនធ្វើឲ្យជ្រុះស្លាបព្រានៅលើក្តារកម្រាល) ឬក៏ក្រុមអាហារ ឬម្ហូបដូរ។
- មានប្រដាប់សម្រាប់បម្រើអាហារប្រណិតសម្រាប់អាហារដែលមានជាតិបង្កឲ្យមានអាលែកហ្ស៊ីដែលមានរាយឈ្មោះនៅក្នុងប័ណ្ណស្តីពី **ដឹង** នៅក្នុងផ្នែក **'ការដាក់អាហារឲ្យដាច់ពីគ្នា'** និងអាហារដែលមិនមានជាតិបង្កឲ្យមានអាលែកហ្ស៊ីទាំងនោះ។

**S**

បង្ហាញ

## តើអ្នកត្រូវបង្ហាញអ្វីខ្លះ?

- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ៖
  - វិធីដែលលោកអ្នកធ្វើដើម្បីធានាថាអាហារសម្រាប់បម្រើខ្លួនឯងត្រូវរក្សាឲ្យមានសុវត្ថិភាព (ឧទាហរណ៍ វិធីដែលលោកអ្នកវាស់សីតុណ្ហភាពអាហាររបស់លោកអ្នក រយៈពេលដែលលោកអ្នកទុកអាហារនៅខាងក្រៅ)
  - វិធីដែលលោកអ្នកប្រើក្នុងការដាក់តាំងអាហារសម្រាប់បម្រើសេវាខ្លួនឯង និងបញ្ឈប់អតិថិជនកុំឲ្យឆ្លងមេរោគដល់អាហារ។

# ការដឹងថាមានអ្វីនៅក្នុងអាហាររបស់អ្នក

**K**

**ដឹង**

## តើអ្នកត្រូវដឹងអ្វីខ្លះ?

- អ្នកត្រូវដឹង និងអាចប្រាប់អតិថិជនរបស់អ្នកបាននូវអ្វីដែលមាននៅក្នុងអាហាររបស់ពួកគេ ដើម្បីឲ្យពួកគេអាចធ្វើការជ្រើសរើសដោយមានព័ត៌មានត្រឹមត្រូវ។ ចំណុចនេះមានសារៈសំខាន់ណាស់សម្រាប់មនុស្សដែលមានអាលែកហ្ស៊ីនឹងអាហារ។
- អ្នកត្រូវតែដឹងថាមានអ្វីនៅក្នុងគ្រឿងផ្សំដែលអ្នកប្រើដើម្បីធ្វើអាហារ។ ប្រសិនបើអ្នកកំពុងនាំចូលអាហារ អ្នកត្រូវតែយល់ដឹងអំពីស្លាកអាហារ។
- មានជាតិបង្កឲ្យមានអាលែកហ្ស៊ីនៅក្នុងអាហារទូទៅចំនួន 11ប្រភេទដែលអ្នកត្រូវដឹង។ ទាំងនេះគឺ អំបិលមានអាស៊ីតស្ពាន់ធ័រ (sulphites) ធញ្ញជាតិដែលមានគ្លុយទីន (gluten) (ឧទាហរណ៍ស្រូវសាឡី) សត្វទឹកដែលមានសំបក (shellfish) ស៊ុត ត្រី ទឹកដោះគោ គ្រាប់សណ្ដែកដី គ្រាប់សណ្ដែកសៀង គ្រាប់ល្ង គ្រាប់ផ្លែឈើ និង គ្រាប់សណ្ដែក។
- អាលែកហ្ស៊ីនឹងអាហារអាចបង្កឲ្យមានប្រតិកម្មដែលអាចគម្រាមកំហែងដល់អាយុជីវិត ដែលអាចកើតមានក្នុងរយៈពេលតែប៉ុន្មាននាទីបន្ទាប់ពីពិសាអាហារប៉ុណ្ណោះ។ ត្រូវដឹងថាអាហារណាមួយដែលអ្នកលក់អាចបង្កឲ្យមានប្រតិកម្មអាលែកហ្ស៊ី។
- អ្នកត្រូវដឹងអំពីបទដ្ឋានស្ដីពីគ្រឿងបន្ថែម និងសមាសភាពអាហារនៅក្នុងក្រមស្តង់ដារអាហាររបស់ប្រទេសអូស្ត្រាលី និងនូវ៉ែលហ្សឺឡង់។ មើលប័ណ្ណស្ដីពី **'ការរៀបចំអាហារឲ្យមានសុវត្ថិភាព'**។

**D**

**ធ្វើ**

## តើអ្នកត្រូវធ្វើអ្វីខ្លះ?

- ពិនិត្យមើលស្លាករបស់គ្រឿងផ្សំ។ អ្នកត្រូវយល់ព័ត៌មាននៅលើស្លាក។
- រក្សាព័ត៌មានលម្អិតនៃគ្រឿងផ្សំដែលអ្នកប្រើ (ឧទាហរណ៍ កំណត់ត្រា និងអនុវត្តតាមក្បួនធ្វើម្ហូបរបស់អ្នកដើម្បីឲ្យអ្នកដឹងថាអាហារទាំងនោះមានជាតិបង្កឲ្យមានអាលែកហ្ស៊ីអ្វីខ្លះ)។

## D
### ធ្វើ

- ប្រាប់បុគ្គលិករបស់អ្នកថាតើអាហារណាមានជាតិបង្កឲ្យមានអាលែកហ្ស៊ីដែលមានរាយឈ្មោះក្នុងវគ្គ **ដឹង**។ បុគ្គលិកទាំងអស់ត្រូវដឹងថាវាមានសារៈសំខាន់ប៉ុណ្ណាដែលពួកគេយល់ដឹងពីអាលែកហ្ស៊ី និងជាតិបង្កឲ្យមានអាលែកហ្ស៊ី។
- អ្នក ☐ គ្រប់គ្រងប្រចាំថ្ងៃ ឬក៏ ☐ អ្នកមានសិទ្ធិសម្រេចក៏បាន (រើសយកចំណុចសមស្រប)
  ឈ្មោះ៖ ____________________
  ត្រូវចេះនិយាយប្រាប់អតិថិជនអំពីអ្វីដែលមាននៅក្នុងអាហាររបស់ពួកគេ។
- ពិនិត្យមើលគ្រឿងផ្សំទាំងអស់នៅក្នុងអាហារ ក៏ដូចជាទឹកជ្រលក់ គ្រឿងតុបតែងលម្អអាហារដាក់ជាមួយ ឬបន្ថែមទៅលើអាហារ។

## S
### បង្ហាញ

### តើអ្នកត្រូវបង្ហាញអ្វីខ្លះ?

- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់អ្នកនូវវិធីដែលអ្នកប្រើដើម្បីឲ្យដឹងបានថាមានអ្វីនៅក្នុងគ្រឿងផ្សំដែលអ្នកប្រើ។
- អ្នកផ្ទៀងផ្ទាត់របស់អ្នកអាចសួរបុគ្គលិកឲ្យប្រាប់ពួកគេអំពីអាហារណាដែលមានជាតិបង្កឲ្យមានអាលែកហ្ស៊ី។

ការបម្រើ + ការលក់

# ការខ្ចប់ និងការដាក់ស្លាកអាហាររបស់អ្នក

K

ដឹង

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- លោកអ្នកមិនត្រូវដាក់ស្លាកអាហាររបស់លោកអ្នកទេ ប្រសិនបើអាហាររបស់លោកអ្នក៖
    - មិនបានវេចខ្ចប់
    - បានធ្វើ ខ្ចប់ និងលក់ក្នុងហាងតែមួយ
    - បានខ្ចប់នៅមុខអតិថិជន
    - ផ្លែឈើ និងបន្លែទាំងមូល ឬកាត់/បេះថ្មីៗ (លើកលែងតែលោកអ្នកលក់បន្លែបណ្ដុះ)
    - អាហារដែលអាចបរិភោគបានភ្លាមដែលបានប្រគល់ជូនក្រុមហ៊ុនពាណិជ្ជអាហារលោកអ្នកដែលបានខ្ចប់រួចហើយ និងត្រៀមរួចសម្រាប់លក់
    - លក់នៅក្នុងពិធីរៃអង្គាសប្រាក់
    - ដាក់តាំងនៅក្នុង ទូសេវាដែលអតិថិជនរបស់លោកអ្នកមិនអាចចូលដល់។
- ទោះបីជាអាហាររបស់លោកអ្នកមិនត្រូវបានដាក់ស្លាកក៏ដោយ លោកអ្នកត្រូវតែចេះប្រាប់ដល់អតិថិជនរបស់លោកអ្នក ឬដាក់តាំងបង្ហាញនូវ៖
    - អ្វីដែលមាននៅក្នុងអាហារ
    - សេចក្ដីក្រើនរំលឹកណាមួយ
    - ប្រសិនបើអាហារធ្វើពី ឬមានគ្រឿងផ្សំកែច្នៃដោយប្រើហ្សែន (genetically modified) ឬអាហារដែលមានចំហាយវិទ្យុសកម្ម។
- អាហារដែលធ្វើនៅក្នុងកន្លែងមួយ និងខ្ចប់នៅកន្លែងផ្សេងទៀតត្រូវតែដាក់ស្លាក។ អាហារដែល ដាក់ស្លាកត្រូវតែឆ្លើយតបទៅនឹងបទដ្ឋានស្ដីពីការដាក់ស្លាកដែលមានចែងនៅក្នុងក្រម
- ក្រសួងឧស្សាហកម្មវត្ថុធាតុដើមបានចងក្រងសៀវភៅណែនាំ ដើម្បីជួយលោកអ្នកក្នុងការធ្វើស្លាកអាហារ។ សូមអនុវត្តតាម 'សៀវភៅណែនាំពីការដាក់ស្លាកអាហារ' http://www.mpi.govt.nz/document-vault/2965

D

ធ្វើ

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

- ប្រសិនបើអាហាររបស់លោកអ្នកត្រូវដាក់ស្លាក លោកអ្នកត្រូវដាក់បញ្ចូលនូវ៖
    - ឈ្មោះអាហារ
    - ការកំណត់បរិមាណ/ក្រុម
    - ឈ្មោះ និងអាសយដ្ឋានរបស់ក្រុមហ៊ុនពាណិជ្ជកម្មនៅប្រទេសអូស្ត្រាលី ឬនូវ៉ែលហ្សឺឡង់របស់លោកអ្នក
    - សេចក្តីផ្តល់យោបល់ សេចក្តីក្រើនរំលឹក និងសេចក្តីប្រកាសដែលអាចអនុវត្តបានណាមួយ
    - លក្ខខណ្ឌសម្រាប់រក្សាទុក និងប្រើប្រាស់
    - បញ្ជីរាយឈ្មោះគ្រឿងផ្សំ
    - កាលបរិច្ឆេទនៃការដាក់សញ្ញាសម្គាល់ (ឧទាហរណ៍ ប្រើឲ្យបានមុន (use-by) ឬគុណភាពល្អបំផុតមុន (best before) ។ល។)
    - ផ្លាកព័ត៌មានស្តីពីអាហាររូបត្ថម្ភនៅក្នុងអាហារ
    - ព័ត៌មានស្តីពីអាហាររូបត្ថម្ភ សុខភាព និងការអះអាងនានាដែលទាក់ទិន (ក្នុងករណីតែលោកអ្នកបានធ្វើការអះអាង)
    - ព័ត៌មានស្តីពីសមាសភាព និងគ្រឿងផ្សំផ្សេងៗ
    - ថាតើផលិតផលធ្វើ ឬបានធ្វើដោយប្រើអាហារកែច្នៃដោយប្រើហ្សែន ឬអាហារមានចំហាយវិទ្យុសកម្ម។
- រក្សា ព័ត៌មានលម្អិតស្តីពីគ្រឿងផ្សំដែលលោកអ្នកប្រើនៅក្នុងអាហាររបស់លោកអ្នក។
- ដាក់ស្លាកអាហាររបស់លោកអ្នកឲ្យបានត្រឹមត្រូវ សម្រាប់បុគ្គលិកលោកអ្នក និងអតិថិជនរបស់លោកអ្នក។
- ប្រើប្រាស់សម្ភារៈសម្រាប់ខ្ចប់ និងប្រដាប់ខ្ចប់អាហារដែលមានសុវត្ថិភាព (ឧទាហរណ៍ ដង្កៀប) ដើម្បីទប់មេរោគ និងជាតិបង្កឲ្យមានអាលែកហ្ស៊ីមិនឲ្យចូលអាហារ។

S

បង្ហាញ

## តើលោកអ្នកត្រូវបង្ហាញអ្វីខ្លះ?

- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ៖
    - វិធីដែលលោកអ្នកប្រើដើម្បីអាចដឹងបានថាត្រូវបញ្ចូលព័ត៌មានអ្វីខ្លះនៅក្នុងស្លាកអាហាររបស់លោកអ្នក
    - ស្លាកអាហាររបស់លោកអ្នក។



# ការលក់អាហារ របស់អ្នក ទៅឲ្យអាជីវកម្មផ្សេង

K

ដឹង

## តើអ្នកត្រូវដឹងអ្វីខ្លះ?

- អ្នកអាចលក់តែអាហារដែលអ្នកបានធ្វើឲ្យអាជីវកម្មមួយទៀតប្រសិនបើ៖
    - វាមិនកែប្រែគោលបំណងចម្បងនៃអ្វីដែលអ្នកធ្វើទេនោះ (ឧទាហរណ៍ដូចជា លក់អាហាររបស់អ្នកជូនអតិថិជនដោយផ្ទាល់) ហើយ
    - អ្នកមិនចាំបាច់ធ្វើអ្វីដែលខុសប្លែកពីអាហាររបស់អ្នកទេ (ឧទាហរណ៍ដូចជា កែវិធីខ្ចប់ ឬដាក់ស្លាកអាហារ)។
    - អាជីវកម្មណាដែលអ្នកផ្គត់ផ្គង់អាចលក់តែអាហាររបស់អ្នកដោយផ្ទាល់ជូនអតិថិជនរបស់ពួកគេ ហើយមិនអាចលក់ទៅឲ្យអាជីវកម្មផ្សេងទៀតទេ។ ឧទាហរណ៍ពីអ្នកដែលអាចប្រើប្រាស់ផែនការនេះរួមមានដូចជាអ្នកដុតនំដែលលក់នំផាយ នំខេក នំចំណិតផ្សេងៗ ។ល។ ឲ្យទៅហាងកាហ្វេ ឬក៏ហាងលក់សាច់រាយដែលផ្តល់សាច់ក្រក/សាច់ស្ទេក ។ល។ ឲ្យទៅភោជនីយដ្ឋាននានា។
- នៅពេលអាហារចាកចេញពីហាងរបស់អ្នក អ្នកមិនអាចរក្សាវាឲ្យមានសុវត្ថិភាព និងភាពសមស្របទៀតទេ – អ្នកពឹងទៅលើអ្នកផ្សេងឲ្យធ្វើកិច្ចការនេះសម្រាប់អ្នក។
- អ្នកត្រូវការស្គាល់ឈ្មោះ និងព័ត៌មានទំនាក់ទំនងលម្អិតនៃអាជីវកម្មទាំងឡាយណាដែលអ្នកផ្គត់ផ្គង់ជាប្រចាំ ដើម្បីឲ្យអ្នកអាចប្រមូលអាហារណាមួយមកវិញ ប្រសិនបើមានបញ្ហា។
- អតិថិជនទាំងឡាយណាដែលបរិភោគអាហាររបស់អ្នកត្រូវការដឹងថាមានអ្វីខ្លះនៅក្នុងអាហារនេះ។ ប្រសិនបើអ្នកផ្គត់ផ្គង់ទៅឲ្យអាជីវកម្មផ្សេងដែលលក់អាហាររបស់អ្នក អ្នកត្រូវការផ្តល់ព័ត៌មានគ្រប់គ្រាន់ដល់ពួកគេ ដើម្បីឲ្យពួកគេអាចឆ្លើយសំណួរណាមួយស្តីពីមានអ្វីខ្លះនៅក្នុងអាហារ។

**K**

**ដឹង**

- ប្រសិនបើអ្នកយល់ថា ភាគច្រើន អ្នកធ្វើអាហារដើម្បីលក់ឲ្យអាជីវកម្មផ្សេង អ្នកអាចកំពុងតែប្រើប្រាស់ផែនការខុសហើយ។ សូមទាក់ទងមកក្រសួងឧស្សាហកម្មវត្ថុធាតុដើមតាម (foodactinfo@mpi.govt.nz) ដើម្បីសុំជំនួយ។
- ប្រសិនបើអ្នកចង់ផ្គត់ផ្គង់ផលិតផលរបស់អ្នកទៅឲ្យអាជីវកម្មមួយទៀត ជាកញ្ចប់ដែលអាជីវកម្មទាំងនោះបានបញ្ជាក់ (ឧទាហរណ៍ដូចជា ដោយមានផ្លាកយីហោពួកគេ) ជាជាងរបៀបដែលអ្នកប្រើប្រាស់ដើម្បីផ្គត់ផ្គង់អតិថិជនរបស់អ្នកផ្ទាល់ អ្នកមិនអាចប្រើផែនការនេះបានទេ។ សូមទាក់ទងមកក្រសួងឧស្សាហកម្មវត្ថុធាតុដើមតាម (foodactinfo@mpi.govt.nz) ដើម្បីសុំជំនួយ។

**D**

**ធ្វើ**

## តើអ្នកត្រូវធ្វើអ្វីខ្លះ?

- អ្នកត្រូវការរក្សាកំណត់ត្រាអំពី៖
  - អាជីវកម្មណាមួយដែលអ្នកដឹងថាផ្គត់ផ្គង់អាហារទៅឲ្យ
  - ផលិតផលដែលអ្នកបានផ្គត់ផ្គង់ទៅឲ្យអាជីវកម្មទាំងនោះ
  - ចំនួនដែលអ្នកបានផ្គត់ផ្គង់ទៅឲ្យអាជីវកម្មទាំងនោះ
  - កាលបរិច្ឆេទដែលអ្នកបានផ្គត់ផ្គង់ទៅឲ្យអាជីវកម្មទាំងនោះ។
- អ្នកត្រូវតែផ្តល់ព័ត៌មានឲ្យបានគ្រប់គ្រាន់ដល់អាជីវកម្មអាហារទាំងអស់ដែលលក់អាហាររបស់អ្នក ដើម្បីឲ្យពួកគេអាចឆ្លើយសំណួរណាមួយស្តីពីមានអ្វីខ្លះនៅក្នុងអាហារ។ អនុវត្តតាមប័ណ្ណ **'ការវេចខ្ចប់ និងដាក់ស្លាកអាហាររបស់អ្នក'** និង **'ការដឹងថាមានអ្វីខ្លះនៅក្នុងអាហាររបស់អ្នក'**។
- អ្នកត្រូវតែប្រាប់អាជីវកម្មណាដែលអ្នកផ្គត់ផ្គង់ឲ្យដឹងអំពីវិធីដើម្បើរក្សាអាហាររបស់អ្នកឲ្យមានសុវត្ថិភាព និងរយៈពេលដែលអាចរក្សាទុកអាហារនេះនៅមុនពេលប្រើប្រាស់ ឬក៏បោះចោល។
- អ្នកមិនត្រូវកែប្រែវិធីដែលអ្នកវេចខ្ចប់ ឬដាក់ស្លាកអាហារឲ្យខុសពីវិធីដែលអ្នកធ្វើជូនអតិថិជនរបស់អ្នកឡើយ ទោះជាអាជីវកម្មដែលអ្នកផ្គត់ផ្គង់សំណូមពរឲ្យអ្នកធ្វើក៏ដោយ។
- ប្រសិនបើអ្នករកឃើញថាអាហារដែលអ្នកបានផ្គត់ផ្គង់ទៅឲ្យអាជីវកម្មមួយមានបញ្ហាអ្វីមួយនោះ អ្នកត្រូវអនុវត្តតាមប័ណ្ណ **'ការប្រមូលអាហាររបស់អ្នកត្រឡប់មកវិញ'** ហើយនិងធ្វើតាមប័ណ្ណ **'នៅពេលមានបញ្ហាអ្វីមួយ'** ។

S

បង្ហាញ

## តើអ្នកត្រូវបង្ហាញអ្វីខ្លះ?

- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់អ្នកនូវ**កំណត់ត្រា** អំពី៖
    - អាជីវកម្មណាមួយដែលអ្នកដឹងថាផ្គត់ផ្គង់អាហារទៅឲ្យ
    - ផលិតផលដែលអ្នកបានផ្គត់ផ្គង់ទៅឲ្យអាជីវកម្មទាំងនោះ
    - ចំនួនដែលអ្នកបានផ្គត់ផ្គង់ទៅឲ្យអាជីវកម្មទាំងនោះ

    កាលបរិច្ឆេទដែលអ្នកបានផ្គត់ផ្គង់ទៅឲ្យអាជីវកម្មទាំងនោះ។
- បង្ហាញ ឬពន្យល់ដល់អ្នកផ្ទៀងផ្ទាត់របស់អ្នកនូវ៖
    - វិធីដែលអ្នកដឹងថាអាជីវកម្មណាមួយដែលអ្នកផ្គត់ផ្គង់អាហារទៅឲ្យ សម្រាប់លក់ដោយផ្ទាល់ជូនដល់អតិថិជនរបស់ពួកគេ
    - វិធីដែលអ្នកវេចខ្ចប់អាហារណាដែលអ្នកផ្គត់ផ្គង់ទៅឲ្យអាជីវកម្មផ្សេង ហើយ (ប្រសិនបើសមស្រប) វិធីដែលអ្នកដាក់ស្លាកអាហារ។

ការបិទ

# ការលាងសម្អាត

**K**

**ដឹង**

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- មេរោគនឹងលូតលាស់នៅផ្ទៃលើ និងសម្ភារៈកខ្វក់ ហើយអាចធ្វើឲ្យអតិថិជនរបស់លោកអ្នកឈឺបាន។
- ទីកន្លែងកខ្វក់អាចទាក់ទាញសត្វល្អិត ដូចជាកណ្ដុរប្រមេះ កណ្ដុរប្រែង និងកន្លាតដែលអាចចម្លងជំងឺ។
- លោកអ្នកចាំបាច់ត្រូវយកសម្រាមចេញដើម្បីកុំឲ្យវាទាក់ទាញសត្វចំលងមេរោគ។
- ការយកសម្រាមចេញកាត់បន្ថយហានិភ័យដែលមនុស្ស/សម្លៀកបំពាក់អាចឆ្លងមេរោគ ហើយនិងហានិភ័យដែលអាហាររបស់លោកអ្នកអាចឆ្លងមេរោគ។
- ការប្រើប្រាស់ទឹកមិនស្អាតអាចធ្វើឲ្យមនុស្សឈឺបាន។
- ការលាងសម្អាត និងធ្វើអនាម័យជារឿងពីរផ្សេងគ្នា៖
  - ការលាងសម្អាតគឺជាការជូតធូលី និងខ្លាញ់ចេញ
  - ការធ្វើអនាម័យគឺជាការសម្លាប់មេរោគគ្រោះថ្នាក់នៅផ្ទៃលើ។

**D**

**ធ្វើ**

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

### ការប្រើប្រាស់អាហារមានសុវត្ថិភាព

- បោះចោលអាហារក្នុងស្តុកឲ្យបានមុនពេលផុតកំណត់ចូលមកដល់។
- បោះចោលអាហារដែលបានរក្សាទុកឲ្យក្ដៅនៅពេលដាក់តាំង ឬត្រជាក់យ៉ាងរហ័សហើយដាក់ក្នុងទូទឹកកកដើម្បីប្រើទាំងត្រជាក់នៅថ្ងៃបន្ទាប់។
- បោះចោលអាហារ ឬគ្រឿងផ្សំណាដែលបានឆ្លងមេរោគ។
- បោះចោលសាច់ប្រឡាក់ និងប្រដាប់ខ្ចប់ដែលនៅសល់។

ការបិទ

D

ធ្វើ

- បោះចោលទឹកប្រឡាក់សាច់ ឬទឹកត្រាំជ្រក់ដែលនៅសល់។
- បោះចោលអាហារណាដែលប៉ះពាល់ផ្ទាល់ជាមួយទឹកមិនស្អាត។
- ត្រូវដាក់ស្លាក និងរក្សាទុកឲ្យបានត្រឹមត្រូវនូវអាហារនៅសល់ទាំងអស់ដែលមានសុវត្ថិភាពអាចប្រើបានថ្ងៃក្រោយទៀត (ឧទាហរណ៍ អាហារត្រជាក់ដាក់ក្នុងទូទឹកកក អាហារត្រូវការពារកុំឲ្យឆ្លងមេរោគដាក់ក្នុងប្រអប់ជាដើម)។

## លាងសម្អាតកន្លែងរៀបចំអាហាររបស់លោកអ្នក

- រៀបចំ និង/ឬបោកខោអាវកខ្វក់ (ប្រសិនបើលោកអ្នកជ្រើសរើសផ្គត់ផ្គង់ខោអាវស្អាតដល់បុគ្គលិករបស់លោកអ្នក)។
- ចាក់សំរាមចេញពីធុងឲ្យអស់ និងយកសម្រាមចេញពីកន្លែងធ្វើអាហារនៅពេលបិទហាង និងនៅពេលសម្រាមពេញធុង។
- បោះសម្រាមចោលឲ្យបានទៀងទាត់។
- លាងសំអាតធុងសម្រាម និងកន្លែងដាក់សម្រាមឲ្យបានទៀងទាត់។
- លោកអ្នកត្រូវលាងសម្អាត និងធ្វើអនាម័យផ្ទៃខាងក្រៅដែលប៉ះពាល់ជាមួយអាហារ។
- លោកអ្នកត្រូវប្រើទឹកក្តៅលាយសាប៊ូ ឬជាតិគីមីដែលមានគុណភាពសម្រាប់លាងសម្អាតកន្លែងធ្វើអាហារ។
- ជានិច្ចកាល អនុវត្តតាមការណែនាំនៅពេលប្រើជាតិគីមីសម្រាប់លាងសម្អាត។
- ជានិច្ចកាល ធ្វើអនាម័យកន្លែង និងសម្ភារៈរៀបចំអាហារបន្ទាប់ពីលាងសម្អាត។
- លោកអ្នកត្រូវតែប្រើទឹកស្អាតសម្រាប់លាងកន្លែង និងសម្ភារៈរៀបចំអាហាររបស់លោកអ្នក។
- លោកអ្នកត្រូវតែបោស បូមធូលី និង/ឬជូតគ្រប់កន្លែងទាំងអស់ក្នុងហាងអាហាររបស់លោកអ្នក។

ការបិទ

S

បង្ហាញ

## តើលោកអ្នកត្រូវបង្ហាញអ្វីខ្លះ?

- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ៖
    - ការងារប្រចាំនៅ 'មុនពេលបិទហាង' របស់លោកអ្នក ដោយរួមមានទាំងការពិនិត្យឥវ៉ាន់ក្នុងស្តុក។
    - **កំណត់ត្រា** ស្តីពីការងារលាងសម្អាតរបស់លោកអ្នក អ្នកណាជាអ្នកលាងសម្អាត និងលាងនៅពេលណា
    - វិធីដែលលោកអ្នកប្រើដើម្បីយកកាកសំណល់ចេញ
    - វិធីដែលលោកអ្នកប្រើដើម្បីលាងសម្អាតធុងសម្រាម និងកន្លែងដាក់សម្រាម ហើយអ្នកណាជាអ្នកទទួលខុសត្រូវ
    - ថាទីកន្លែង និងឧបករណ៍ប្រើប្រាស់ស្អាតល្អ ហើយថាខោអាវកខ្វក់ត្រូវបោកបើសិនចាំបាច់
    - វិធីដែលលោកអ្នកប្រើដើម្បីលាងសម្អាត និងធ្វើអនាម័យកន្លែង និងឧបករណ៍រៀបចំអាហាររបស់លោកអ្នក
    - វិធីដែលលោកអ្នកប្រើដើម្បីប្រើជាតិគីមីប្រកបដោយសុវត្ថិភាព។

# ការថែទាំឧបករណ៍ប្រើប្រាស់ និងហាង

K

ដឹង

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- ប្រសិនបើទីកន្លែងនិងឧបករណ៍របស់លោកអ្នកមិនបានរៀបចំឡើងឲ្យបានត្រឹមត្រូវសម្រាប់ប្រើដើម្បីធ្វើអាហារទេ វាមិនមានស្ថានភាពល្អ និង/ឬមិនដំណើរការល្អទេនោះ លោកអ្នកអាចធ្វើអាហារដែលគ្មានសុវត្ថិភាព និង/ឬមិនសមរម្យសម្រាប់បរិភោគឡើយ។
- វាជាការសំខាន់ដើម្បីវាយតំលៃទីកន្លែងដែលលោកអ្នកធ្វើអាហារ និងធានាថាវាមិនធ្វើពីសម្ភារៈដែលអាចចម្លងមេរោគដល់អាហារ ងាយលាងសម្អាត មានសេវាកម្មចាំបាច់នានា (ឧទាហរណ៍ ភ្លើង ទឹក) និងធំល្មមសម្រាប់សកម្មភាពធ្វើអាហារទាំងអស់ (និងបុគ្គលិក) ដែលលោកអ្នកមាន។ លោកអ្នកត្រូវពិនិត្យឲ្យបានទៀងទាត់ថាទាំងអស់នេះស្ថិតនៅជាការពិត (បានថែទាំ) សម្រាប់អាជីវកម្មរបស់លោកអ្នក។
- ប្រសិនបើទីកន្លែង និងឧបករណ៍របស់លោកអ្នកមិនមានស្ថានភាពល្អ និង/ឬមិនដំណើរការល្អ លោកអ្នកអាចធ្វើអាហារគ្មានសុវត្ថិភាព និង/ឬមិនសមរម្យសម្រាប់បរិភោគ។
- ឧបករណ៍បាក់បែក និងអគារដែលខ្វះការថែទាំ (ឧទាហរណ៍ មានប្រហោងនៅតាមឥដ្ឋ និងជញ្ជាំង) អាចបណ្ដាលអោយមានសត្វល្អិត និងមេរោគចូលក្នុងអាហាររបស់លោកអ្នកបាន។ នេះអាចនាំឲ្យអាហារគ្មានសុវត្ថិភាព និងមិនសមរម្យសម្រាប់បរិភោគ។
- ទឹកដែលលោកអ្នកប្រើសម្រាប់រៀបចំអាហារ ការលាង និងសម្អាតដៃចាំបាច់ត្រូវតែស្អាតជានិច្ច។ លោកអ្នកត្រូវដឹងពី របៀបជួសជុល និងថែទាំបំពង់បង្ហូរទឹក ធុងទឹក និង ប្រព័ន្ធសម្លាប់មេរោគក្នុងទឹក។ល។

# D

ធ្វើ

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

- ពិនិត្យទីកន្លែងរបស់លោកអ្នក រកមើលសញ្ញាខូចខាត (ឧទាហរណ៍ មានប្រហោងនៅតាមឥដ្ឋ និងជញ្ជាំង) និងធ្វើការជួសជុលតាមការចាំបាច់។
- ពិនិត្យឧបករណ៍របស់លោកអ្នករកមើលសញ្ញាខូចខាត និងធ្វើការជួសជុលតាមការចាំបាច់។
- ថែទាំឧបករណ៍របស់លោកអ្នកជាប្រចាំ ហើយប្រសិនបើចាំបាច់ពិនិត្យកែសម្រួលទៅតាមកាលវិភាគពិនិត្យកែសម្រួលរបស់លោកអ្នក។
- សមាសធាតុប្រើសម្រាប់ការថែទាំ និងជាតិគីមីត្រូវតែ៖
    - មានស្លាកគ្រប់ទាំងអស់ ទុក បិទភ្ជិត និងប្រើប្រាស់ទៅតាមការណែនាំរបស់រោងចក្រផលិត
    - រក្សាទុក និងដឹកជញ្ជូនក្នុងប្រអប់ដែលខុសគ្នាពីប្រដាប់ដាក់អាហារ។
- លោកអ្នកត្រូវតែគ្រប់គ្រង និងត្រួតពិនិត្យសត្វបង្កមេរោគដោយ៖
    - ☐ ជួលអ្នកជំនាញសម្លាប់សត្វបង្កមេរោគ ឬ
    - ☐ គ្រប់គ្រងហានិភ័យនេះដោយខ្លួនឯង។

### សម្រាប់ការផ្គត់ផ្គង់ទឹកទាំងអស់

- បំពង់បង្ហូរទឹកត្រូវដំណើរការល្អដើម្បីបញ្ឈប់សត្វចតុបាទ សត្វស្លាប ធូលី និងកាកសំណល់កុំឲ្យចម្លងមេរោគទៅក្នុងទឹករបស់លោកអ្នក។
- ជានិច្ចកាល ចុចបង្ហូរទឹកតាមបំពង់បង្ហូរទឹកបន្ទាប់ពី៖
    - ជួសជុល និងថែទាំ
    - បន្ទាប់ពីខានប្រើទឹករយៈពេល 7 ថ្ងៃដើម្បីបង្ហូរទឹកកខ្វក់ចេញ
- រក្សាធុងទឹក៖
    - ឲ្យស្អាត និងមានសភាពល្អកុំឲ្យមានកើតកករ និង
    - គ្របវាដើម្បីកុំឲ្យសត្វចតុបាទ សត្វស្លាប និងធូលីចម្លងមេរោគចូលក្នុងទឹក។

ការបិទ

D

ធ្វើ

## សម្រាប់តែប្រព័ន្ធទឹកនៅលើ ឬក្រោមដី

- លោកអ្នកត្រូវតម្លើង ដាក់ឲ្យដំណើរការ និងថែទាំប្រព័ន្ធសម្លាប់មេរោគក្នុងទឹក ទៅតាមការណែនាំរបស់រោងចក្រផលិត។
- លោកអ្នកត្រូវអនុវត្តតាមការណែនាំរបស់រោងចក្រផលិតក្នុងការប្តូរ និងលាងសម្អាតតម្រងចម្រោះទឹក។
- ត្រូវរៀបចំ និងថែទាំរន្ធបង្ហូរដើម្បីការពារកុំឲ្យមានការឆ្លងមេរោគពីផ្ទៃកខ្វក់ខាងក្រៅ។

## សម្រាប់តែការផ្គត់ផ្គង់ទឹកពីដំបូល

- ចាំបាច់ត្រូវយកទឹកពីដំបូលដែលស្អាត ហើយទរទឹកត្រូវធ្វើពីសម្ភារៈដែលមានសុវត្ថិភាព (ឧទាហរណ៍ ថ្នាំពណ៌គ្មានជាតិសំណរ ជ័រកៅស៊ូ ទរឈើ ឬស្ពាន់)។
- លោកអ្នកត្រូវកាត់បន្ថយហានិភ័យនៃការចម្លងមេរោគឲ្យបានច្រើនតាមដែលអាចធ្វើបាន។ ការកាត់បន្ថយហានិភ័យនេះរួមមាន៖
    - ការដាក់របាំងបិទលើទរទឹក និង
    - យកមែកឈើ និងរុក្ខជាតិផ្សេងៗដែលគ្របលើទរចេញ និង
    - ដាក់អង់តែន និងថាសផ្កាយរណបឲ្យឆ្ងាយពីកន្លែងយកទឹក និង
    - តម្លើងឧបករណ៍សម្រាប់បង្ហូរទឹកភ្លៀងធ្លាក់ដំបូងចេញ (ឧបករណ៍ដែលបង្វែរទឹកហូរដំបូងចេញពីអាងទឹក នៅពេលមានភ្លៀង)
- លោកអ្នកត្រូវតម្លើង ដាក់ឲ្យដំណើរការ និងថែទាំប្រព័ន្ធសម្លាប់មេរោគក្នុងទឹក (ឧទាហរណ៍ ប្តូរតម្រងច្រោះទឹក) ទៅតាមការណែនាំរបស់រោងចក្រផលិត។

S

បង្ហាញ

## តើអ្នកត្រូវបង្ហាញអ្វីខ្លះ?

- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ៖
    - អ្វីដែលលោកអ្នកប្រើដើម្បីត្រួតពិនិត្យមើលឲ្យបានដឹងថាទីកន្លែង និង ឧបករណ៍របស់លោកអ្នកគឺបង្កើតឡើងសម្រាប់ប្រើប្រាស់ក្នុងការធ្វើអាហារ និងនៅដំណើរការល្អ
    - លោកអ្នកពិនិត្យមើលការថែទាំញឹកញាប់ប៉ុណ្ណា
    - អ្វីដែលលោកអ្នកពិនិត្យមើលនៅពេលធ្វើការត្រួតពិនិត្យការថែទាំ
    - **កំណត់ត្រា**ស្តីពីការងារថែទាំ ឬការជួសជុលជាប្រចាំ អ្នកណាជាអ្នកធ្វើការងារទាំងនេះ ហើយធ្វើនៅពេលណា
    - វិធីដែលលោកអ្នកប្រើដើម្បីសម្លាប់សត្វចម្លងមេរោគ
    - លោកអ្នកពិនិត្យ និងថែទាំប្រព័ន្ធទឹក និងធុងទឹកញឹកញាប់ប៉ុណ្ណា។ ព្រមទាំង **កំណត់ត្រា**ស្តីពីអ្នកណាជាអ្នកធ្វើ និងធ្វើនៅពេលណា។
- អ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនឹងពិនិត្យមើលថាលោកអ្នកកំពុងពិនិត្យកែសម្រួលឧបករណ៍របស់លោកអ្នកបានត្រឹមត្រូវតាមការណែនាំឬទេ។

**សម្រាប់តែ-ទឹកដែលផ្គត់ផ្គង់ដោយខ្លួនឯងប៉ុណ្ណោះ (ផ្គត់ផ្គង់ទឹកលើដី ទឹកក្រោមដី ឬទឹកពីដំបូល)**

- បង្ហាញថាតើលោកអ្នកត្រួតពិនិត្យមើល និងថែទាំប្រព័ន្ធសម្លាប់មេរោគក្នុងទឹករបស់លោកអ្នក (ដូចជា ការប្តូរតម្រងចំរោះទឹក) ញឹកញាប់ប៉ុណ្ណា។



# នៅពេលមានបញ្ហាអ្វីមួយ

**K**

ដឹង

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- លោកអ្នក ត្រូវរក្សាទុកកំណត់ត្រារយៈពេលយ៉ាងហោចណាស់ ៤ឆ្នាំ។
- កំណត់ត្រាត្រូវរៀបរាប់ឲ្យច្បាស់ថាអ្វីដែលមានបញ្ហា អ្នកណាជាប់ពាក់ព័ន្ធ និងបញ្ហាដោះស្រាយបានដោយរបៀបណា។
- អ្វីៗគ្រប់យ៉ាងមិនដំណើរការដូចដែលបានរំពឹងទុករាល់ពេលនោះទេ។ លោកអ្នកត្រូវតែមាននីតិវិធីដោះស្រាយអ្វីដែលមានបញ្ហានៅក្នុងផែនការរបស់លោកអ្នក។

**D**

ធ្វើ

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

- ចាត់វិធានការជាបន្ទាន់នៅពេលរកឃើញថាមានបញ្ហាប៉ះពាល់ដល់សុវត្ថិភាព និង/ឬភាពសមរម្យរបស់អាហារ។ កត់ត្រានូវសកម្មភាពដែលលោកអ្នកបានធ្វើ។
- ប្រើកំណត់ត្រារបស់លោកអ្នកដើម្បីពិនិត្យមើលសកម្មភាពកាលពីសប្តាហ៍មុន/ពីរបីថ្ងៃកន្លងទៅ។ កំណត់រកមើលថាតើមានអ្វីមួយនៅក្នុងផែនការរបស់លោកអ្នកមានបញ្ហាដែរឬទេ ដូចជា៖
    - សីតុណ្ហភាពទូរទឹកកកឡើងខ្ពស់ពេក
    - មានសញ្ញាថាមានសត្វឆ្លងមេរោគចូលមកក្នុងបរិវេណ
    - អាហារដែលបានទទួលវាមិនបានរក្សាទុកក្នុងសីតុណ្ហភាពត្រឹមត្រូវ
    - សាច់បសុបក្សីមិនបានចំអិនឲ្យដល់សីតុណ្ហភាពយ៉ាងហោចណាស់ 65 អង្សាសេ ក្នុងរយៈពេល15 នាទី
    - អាហារមិនបានកំដៅឡើងវិញឲ្យបានលើសពីសីតុណ្ហភាព 75 អង្សាសេ
    - ប្រើពេលយូរពេកក្នុងការធ្វើឲ្យអាហារត្រជាក់
    - អាហារត្រូវបានដឹកជញ្ជូនក្នុងសីតុណ្ហភាពមិនត្រឹមត្រូវ។

## D

ធ្វើ

- ប្រសិនបើមានបញ្ហាអ្វីមួយ ត្រូវកំណត់រកឲ្យឃើញថាបញ្ហានេះចាប់ផ្ដើមពីកន្លែងណា ហើយកើតឡើងប៉ុន្មានដងហើយ។ កំណត់រកឲ្យឃើញថា តើមាននិតិវិធីណាមួយដែល មិនបានដាក់បញ្ចូលក្នុងផែនការរបស់លោកអ្នកដែរឬទេ
- តើអាហារដែលលោកអ្នកផលិតគ្មានសុវត្ថិភាព ឬមិនសមរម្យសម្រាប់បរិភោគដែរឬទេ? តើលោកអ្នកត្រូវប្រាប់អតិថិជនលោកអ្នកឬទេ?
- ដោះស្រាយបញ្ហាដោយខ្លួនឯង ឬប្រាប់ដល់អ្នកទទួលខុសត្រូវនៅផ្នែកនោះអំពីបញ្ហាដែលបានកើតឡើង។
- ចាត់វិធានការទប់ស្កាត់កុំឲ្យបញ្ហាកើតមានសារជាថ្មីម្តងទៀត។
- រក្សាទុកកំណត់ត្រាច្បាស់លាស់ ត្រឹមត្រូវ និងពេញលេញឲ្យបានយ៉ាងហោចណាស់ចំនួន ៤ឆ្នាំ។
- ជូនដំណឹងដល់អ្នកផ្ទៀងផ្ទាត់ឲ្យបានដឹង ប្រសិនបើអាហារណាមួយរបស់លោកអ្នកក្លាយជាគ្មានសុវត្ថិភាព ឬមិនសមរម្យសម្រាប់បរិភោគ នៅពេលលោកអ្នកបានអនុវត្តតាមនិតិវិធីនៅក្នុងផែនការរបស់លោកអ្នក។

## S

បង្ហាញ

### តើលោកអ្នកត្រូវបង្ហាញអ្វីខ្លះ?

- បង្ហាញដល់អ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ**កំណត់ត្រា**របស់លោកអ្នកចាប់ពីពេលដែលមានបញ្ហាកើតឡើង។
- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ**កំណត់ត្រា** នៃ៖
  - តើបញ្ហាអ្វីដែលបានកើតឡើង
  - អ្វីដែលលោកអ្នកបានធ្វើដើម្បីដោះស្រាយបញ្ហាជាបន្ទាន់
  - តើលោកអ្នកបានផ្លាស់ប្តូរអ្វីខ្លះដើម្បីបញ្ឈប់កុំឲ្យកើតមានបញ្ហានេះជាថ្មីទៀត
  - តើលោកអ្នកបានធ្វើយ៉ាងណាដើម្បីរក្សាទុកអាហារអោយមានសុវត្ថិភាព ឬដើម្បីធានាថាអ្នកមិនបានលក់អាហារដែលគ្មានសុវត្ថិភាព និងមិនសមរម្យសម្រាប់បរិភោគដល់អតិថិជន។



# ការដោះ ស្រាយបណ្ដឹងរបស់អតិថិជន

K

ដឹង

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- លោកអ្នកត្រូវមានសមត្ថភាពកំណត់បានថាតើវាជាពាក្យបណ្ដឹងស្ដីពីសុវត្ថិភាព ភាពសមរម្យ និងគុណភាពរបស់អាហារមែនឬមិនមែន។
- ត្រូវដោះស្រាយបណ្ដឹងរបស់អតិថិជនអំពីសុវត្ថិភាព និង/ឬភាពសមរម្យរបស់អាហារសម្រាប់បរិភោគជាបន្ទាន់។
- លោកអ្នកត្រូវមានអ្នកទទួលខុសត្រូវក្នុងការដោះស្រាយបណ្ដឹងរបស់អតិថិជន។

D

ធ្វើ

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

- កំណត់រកមើលថា តើអ្នកណាជាអ្នកទទួលខុសត្រូវខាងពាក្យបណ្ដឹង៖
  ☐ អ្នកគ្រប់គ្រងប្រចាំថ្ងៃ ឬ ☐ អ្នកមានសិទ្ធិសម្រេច
  (គូសយកមនុស្សសមស្រប)
  ឈ្មោះ៖ ____________________
- កំណត់រកមើលថា តើពាក្យបណ្ដឹងជាពាក្យបណ្ដឹងស្ដីពីសុវត្ថិភាព ភាពសមរម្យ និងគុណភាពអាហារ មែនឬទេ។
- ប្រសិនបើពាក្យបណ្ដឹងប៉ះពាល់សុវត្ថិភាព និង/ឬភាពសមរម្យរបស់ក្រុមអាហារ ឬអាហារមួយមុខ លោកអ្នកត្រូវដាក់អាហារទាំងនោះឲ្យនៅដាច់ពីគ្នា រហូតដល់អាចបញ្ជាក់បានថាវាមានសុវត្ថិភាព ឬបោះចោលអាហារដែលរងការប៉ះពាល់ និងគ្រឿងផ្សំដែលពាក់ព័ន្ធ
  - ពិនិត្យមើលអាហារនៅកន្លែងជាមួយគ្នា ឬអាហារបានរៀបចំនៅពេលជាមួយគ្នា
  - កំណត់រកមើលថា តើបញ្ហាបានចាប់ផ្ដើមនៅកន្លែងណា
  - ដោះស្រាយបញ្ហា
  - ចាត់វិធានការទប់ស្កាត់កុំឲ្យបញ្ហាកើតមានជាថ្មីម្ដងទៀត។

## D ធ្វើ

- ជូនដំណឹងដល់អ្នកផ្ទៀងផ្ទាត់របស់លោកអ្នក៖
  - ប្រសិនបើ អ្នកដែលបរិភោគអាហាររបស់លោកអ្នកធ្លាក់ខ្លួនឈឺ ឬ
  - អាចធ្លាក់ខ្លួនឈឺប្រសិនបើគេបរិភោគអាហាររបស់លោកអ្នក

## S បង្ហាញ

### តើអ្នកត្រូវបង្ហាញអ្វីខ្លះ?

- បង្ហាញដល់អ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ **កំណត់ត្រា**ស្តីពីបញ្ហាទាំងអស់ដូចខាងក្រោម ប្រសិនបើពាក្យបណ្តឹងស្តីពីសុវត្ថិភាព ឬភាពសមរម្យរបស់អាហារ៖
  - ព័ត៌មានទំនាក់ទំនងលម្អិតរបស់បុគ្គលដែលដាក់ពាក្យបណ្តឹង
  - កាលបរិច្ឆេទនិងពេលវេលាដែលគេបានទិញអាហាររបស់លោកអ្នក
  - អាហាររបស់លោកអ្នកដែលមានបញ្ហា ដោយរួមទាំងលេខសំគាល់ក្រុម/បរិមាណអាហារនោះ
  - តើពាក្យបណ្តឹងនិយាយអំពីអ្វី
  - មូលហេតុនៃបញ្ហា
  - សកម្មភាពដែលលោកអ្នកបានធ្វើភ្លាមៗ និងសកម្មភាពដែលលោកអ្នកបានធ្វើដើម្បីការពារកុំឲ្យមានបញ្ហាប្រភេទនេះអាចកើតឡើងជាថ្មីម្តងទៀត។

ការដោះស្រាយបញ្ហា

# ការតាមដានអាហាររបស់អ្នក

K

ដឹង

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- លោកអ្នកត្រូវតែមានលទ្ធភាពតាមដានអាហាររបស់លោកអ្នក ប្រសិនបើផលិតផលដែលលោកអ្នកធ្វើបានប្រែក្លាយទៅជាគ្មានសុវត្ថិភាព និងមិនសមរម្យសម្រាប់បរិភោគ។
- លោកអ្នកមានជម្រើស 2 សម្រាប់តាមដានអាហាររបស់លោកអ្នក៖
  1. កត់ត្រាព័ត៌មានទាំងអស់ (ដោយរួមទាំងព័ត៌មានអំពីក្រុមហ៊ុនផ្គត់ផ្គង់ ដោយមានលេខសំគាល់ក្រុម/បរិមាណអាហារនោះ) ដើម្បីឲ្យលោកអ្នកអាចតាមដាន និងប្រមូលផលិតផលរបស់លោកអ្នកមកវិញបាន (បើចាំបាច់) ឬ
  2. កត់ត្រាតែព័ត៌មានអប្បបរមាដែលត្រូវការចាំបាច់ និងប្រមូលយកអាហារទាំងអស់មកវិញ ប្រសិនបើមានបញ្ហា។
- ព័ត៌មានអប្បបរិមាដែលលោកអ្នកត្រូវរក្សាទុក ពេលទទួលផលិតផលអាហារគឺ៖
  - ឈ្មោះ និងព័ត៌មានទាក់ទងលម្អិតរបស់ក្រុមហ៊ុនផ្គត់ផ្គង់
  - ប្រភេទ និងចំនួនអាហារ
  - សីតុណ្ហភាពអាហារ ប្រសិនបើវាត្រូវការរក្សានៅក្នុងសីតុណ្ហភាពជាក់លាក់មួយដើម្បីធានាថាវាមានសុវត្ថិភាព និងសមរម្យសម្រាប់បរិភោគ។
- ប្រសិនបើលោកអ្នកជ្រើសយកជម្រើសទី1 លោកអ្នកត្រូវមានផែនការជាលាយល័ក្ខអក្សរដើម្បីឲ្យអាចតាមដានអាហារ និងប្រមូលមកវិញបើចាំបាច់ ប្រសិនបើមានបញ្ហាលើសុវត្ថិភាពអាហារ ជាមួយផលិតផល ឬគ្រឿងផ្សំណាមួយនៅក្នុងផលិតផលរបស់លោកអ្នក។
- ប្រសិនបើលោកអ្នកជ្រើសយកជម្រើសទី2 លោកអ្នកត្រូវប្រមូលមកវិញ ឬបោះចោលអាហារដែលមិនល្អទាំងនោះ។

**K**

**ដឹង**

- ជម្រើសទី2 អាចចំណាយប្រាក់ច្រើន បើមានបញ្ហាលើសុវត្ថិភាពអាហារ លោកអ្នកត្រូវប្រមូលមកវិញ ឬបោះចោលអាហារមិនល្អទាំងអស់ដែលធ្វើនៅក្នុងកន្លែងលោកអ្នក។
- លោកអ្នកត្រូវរក្សាទុកព័ត៌មានជាក់លាក់ស្ដីពីអាហារដែលលោកអ្នកនាំចូលមក។

**D**

**ធ្វើ**

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

- ដើម្បីតាមដានអាហារដែលនាំចូល លោកអ្នកត្រូវរក្សាទុក៖
    - ឈ្មោះ និងព័ត៌មានទាក់ទងលម្អិតរបស់
        - ក្រុមហ៊ុនផ្គត់ផ្គង់របស់លោកអ្នក
        - ក្រុមហ៊ុនផលិតអាហារ
    - ព័ត៌មានណាមួយដែលបង្ហាញថាអាហារ៖
        - ត្រូវបានវាយតម្លៃ ឬបញ្ជាក់ថាមានសុវត្ថិភាព និងសមរម្យសម្រាប់បរិភោគ
        - ត្រូវបានដឹកជញ្ជូន និងទុកដាក់ប្រកបដោយសុវត្ថិភាពដើម្បីជៀសវាងការខូចខាត និងឆ្លងរោគ
    - ការពិពណ៌នាពីអាហារ ដោយរួមមានទំនិញ ម៉ាក និងលេខសំគាល់ក្រុម ឬបរិមាណទំនិញ
    - ព័ត៌មានណាដែលនឹងអនុញ្ញាតឲ្យយើងតាមដានអាហារបានដូចជា៖
        - ពីក្រុមហ៊ុនផ្គត់ផ្គង់ ដល់ក្រុមហ៊ុននាំចូលដែលបានចុះបញ្ជីរួច
        - ក្នុងពេលទំនិញនៅក្រោមការកាន់កាប់របស់ក្រុមហ៊ុននាំចូលដែលបានចុះបញ្ជីរួច
        - ដល់អ្នកបន្ទាប់ដែលអាហារត្រូវបានផ្ទេរឲ្យ (ក្រៅពីអតិថិជនចុងក្រោយ)។
- សម្រាប់អាហារទាំងអស់ សូមជ្រើសរើសមួយ (គូសយកចំណុចសមស្រប)៖

☐ ជម្រើសទី 1 – កត់ទុកព័ត៌មានទាំងអស់ដើម្បីឲ្យអ្នកអាចប្រមូលយកអាហារដែលមានបញ្ហាមកវិញ ឬ

☐ ជម្រើសទី 2 – កត់ទុកព័ត៌មានកម្រិតអប្បបរមា។

## D
ធ្វើ

ប្រសិនបើលោកអ្នកជ្រើសយកជម្រើសទី1៖

- លោកអ្នកត្រូវមានផែនការសម្រាប់កត់ត្រា ថាតើអាហាររបស់លោកអ្នកបាន ចេញមកពីណា ហើយនិងបានយកទៅទីណា
- បុគ្គលិករបស់លោកអ្នកត្រូវចេះអនុវត្តតាមផែនការ (ដូចជាការកត់ត្រាលេខសំគាល់ក្រុម/បរិមាណទំនិញ និងកន្លែងដែលត្រូវរកព័ត៌មានស្ដីពីផលិតផលដែលបានវេចខ្ចប់រួច)។

## S
បង្ហាញ

### តើអ្នកត្រូវបង្ហាញអ្វីខ្លះ?

- **កំណត់ត្រា** ស្ដីពីព័ត៌មានទាំងអស់ដែលមាននៅក្នុងផ្នែក ធ្វើ ប្រសិនបើលោកអ្នកនាំចូលអាហារ។
- ប្រសិនបើលោកអ្នកជ្រើសយកជម្រើសទី 1 គឺត្រូវមាន**កំណត់ត្រា** នៃព័ត៌មានទាំងអស់ស្ដីពីលេខសំគាល់ក្រុម/បរិមាណទំនិញ។
- ប្រសិនលោកអ្នកជ្រើសយកជម្រើសទី 2 គឺត្រូវមាន**កំណត់ត្រា** នៃព័ត៌មានអប្បបរមាដែលត្រូវការ។

ការដោះស្រាយបញ្ហា

# ការប្រមូលអាហាររបស់អ្នកមកវិញ

K

ដឹង

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- អាហារដែលគ្មានសុវត្ថិភាព ឬមិនសមរម្យសម្រាប់បរិភោគអាចធ្វើឲ្យមនុស្សឈឺបាន។
- លោកអ្នកត្រូវតែអាចប្រមូលអាហាររបស់លោកអ្នកមកវិញ ប្រសិនបើវាមានបញ្ហា។
- កំណត់ត្រាដែលលោកអ្នករក្សាទុកអាចជួយលោកអ្នកបាន ប្រសិនបើមានករណីត្រូវប្រមូលយកអាហារមកវិញ។
- មានព័ត៌មានដែលមានប្រយោជន៍ស្តីពីការប្រមូលអាហារមកវិញនៅលើគេហទំព័ររបស់ក្រសួងឧស្សាហកម្មវត្ថុធាតុដើម តាមអាសយដ្ឋាន៖ http://www.foodsafety.govt.nz/recalls-warnings/
- អាចមានមូលហេតុ 2 យ៉ាង សម្រាប់ការប្រមូលអាហារមកវិញ៖
  1. ក្រុមហ៊ុនផ្គត់ផ្គង់របស់លោកអ្នកអាចត្រូវការប្រមូលមកវិញនូវផលិតផលអាហារ ឬឧបករណ៍ ឬកញ្ចប់អាហារដែលលោកអ្នកប្រើប្រាស់ ឬ
  2. លោកអ្នកអាចត្រូវប្រមូលអាហារដែលលោកអ្នកបានផ្ញើមកពីអតិថិជនរបស់លោកអ្នកវិញ។

D

ធ្វើ

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

- ប្រសិនបើផលិតផលអាហារ ឬឧបករណ៍ ឬកញ្ចប់ដែលលោកអ្នកបានប្រើក្នុងអាជីវកម្មរបស់លោកអ្នកត្រូវបានប្រមូលយកមកវិញ លោកអ្នកត្រូវ៖
  - អាចកំណត់ថាអាហារលោកអ្នកបានរងការប៉ះពាល់មែន
  - កំណត់ឲ្យដឹងច្បាស់ថាអាហារណាដែលត្រូវប្រមូលមកវិញត្រូវបានដាក់តាំង មានក្នុងស្តុក ឬបានប្រើជាគ្រឿងផ្សំក្នុងអាហារផ្សេងទៀត
  - កំណត់ឲ្យដឹងច្បាស់ថាអាហារដែលត្រូវប្រមូលមកវិញបានប៉ះពាល់នឹងរបស់ផ្សេងៗដែលបានប្រើប្រាស់នៅក្នុងអាជីវកម្មរបស់លោកអ្នក (ដូចជាប្រអប់ជ័រ)

D

ធ្វើ

- អាចអនុវត្តតាម និងឆ្លើយតបទៅនឹងការណែនាំទាំងអស់ដែលមាននៅក្នុងសេចក្តីជូនដំណឹងអំពីការប្រមូលទំនិញមកវិញ
- ទុកកសិផលដែលត្រូវប្រមូលមកវិញឲ្យដាច់ពីគេ និងដាក់ស្លាក 'អាហារប្រមូលត្រឡប់វិញ-កុំយកវាទៅប្រើ'
- ប្រាប់ក្រុមហ៊ុនផ្គត់ផ្គង់ទំនិញរបស់លោកអ្នកឲ្យបានដឹងថា តើផលិតផលខូចគុណភាពរបស់ពួកគេមានប៉ុន្មាននៅក្នុងអាជីវកម្មអាហាររបស់លោកអ្នក
- រៀបចំឲ្យមានកាប្រមូល និងបោះចោលនូវផលិតផលខូចគុណភាព។

- ប្រសិនបើលោកអ្នកបានធ្វើ និងលក់អាហារដែលគ្មានសុវត្ថិភាព ឬមិនសមរម្យ លោកអ្នកត្រូវធ្វើដូចខាងក្រោមនេះ៖
  - ហៅទូរស័ព្ទទៅកាន់លេខ 0800 00 83 33 និងសួររកក្រុមអនុវត្តច្បាប់អាហារ (ប្រសិនបើក្នុងម៉ោងធ្វើការ) ឬសួររកមន្ត្រីសុវត្ថិភាពអាហារក្រសួងឧស្សាហកម្មវត្ថុធាតុដើមប្រចាំការ (ប្រសិនបើហៅទូរស័ព្ទក្រៅម៉ោងធ្វើការ)
  - បំពេញបែបបទវិភាគគ្រោះថ្នាក់/ហានិភ័យនៃការប្រមូលទំនិញមកវិញ ហើយផ្ញើវាទៅមន្ត្រីទទួលបន្ទុកផ្នែកច្បាប់អាហារ តាមអាសយដ្ឋាន http://www.foodsafety.govt.nz/elibrary/industry/recall-hazard/index.htm
  - លោកអ្នកត្រូវរាយការណ៍ទៅក្រសួងឧស្សាហកម្មវត្ថុធាតុដើមអំពីការសម្រេចចិត្តរបស់លោកអ្នកក្នុងការប្រមូលអាហារមកវិញក្នុងរយៈពេល២៤ ម៉ោង
  - ពង្រាងអត្ថបទប្រកាសផ្សាយក្នុងសារព័ត៌មានដោយប្រើទម្រង់បែបបទដែលសមស្រប៖
    - ទម្រង់បែបបទសេចក្តីប្រកាសពីការប្រមូលអាហារមកវិញ - ផលិតផលទូទៅ http://www.foodsafety.govt.nz/elibrary/industry/Food_Recall_Warning-Advertisement_Microsoft.rtf
    - ទម្រង់បែបបទសេចក្តីប្រកាសពីការប្រមូលអាហារមកវិញ – ការក្រើនរំលឹកពីជាតិបង្កឲ្យមានអាលែកហ្ស៊ី http://www.foodsafety.govt.nz/elibrary/industry/Food_Recall-Advertisement_Microsoft.rtf

D

ធ្វើ

- ◦ ផ្ញើអត្ថបទប្រកាសផ្សាយក្នុងសារព័ត៌មានទៅឲ្យមន្ត្រីទទួលបន្ទុកផ្នែកច្បាប់អាហារ ដើម្បីស្នើសុំការយល់ព្រម។ នៅពេលទទួលបានការអនុម័តហើយ លោកអ្នកអាចចុះផ្សាយអត្ថបទបាន។ ការផ្សាយពាណិជ្ជកម្មទាំងអស់ត្រូវតែមានការអនុញ្ញាតពីមន្ត្រីទទួលបន្ទុកផ្នែកច្បាប់អាហារ មុនពេលផ្សព្វផ្សាយ។
- ◦ សួរមន្ត្រីទទួលបន្ទុកផ្នែកច្បាប់អាហារ ថាតើមានអ្វីទៀតដែលលោកអ្នកត្រូវធ្វើ (ឧទាហរណ៍ សេចក្តីប្រកាសត្រង់ចំណុចលក់ ទម្រង់បែបបទសេចក្តីប្រកាសពីការប្រមូលអាហារមកវិញ http://www.foodsafety.govt.nz/elibrary/industry/Food_Recall-Microsoft_Word.rtf ) សេចក្តីប្រកាសព័ត៌មាន (ឧទាហរណ៍ សេចក្តីប្រកាសព័ត៌មាន៖ http://www.foodsafety.govt.nz/elibrary/industry/Example_Press-Demonstrates_Main.htm ) ផ្សាយតាមវិទ្យុ ប្រកាសលើវិបសាយថ៍) និងបំពេញទៅតាមអ្វីដែលតម្រូវឲ្យធ្វើ។

S

បង្ហាញ

## តើអ្នកត្រូវបង្ហាញអ្វីខ្លះ?

- ប្រសិនបើលោកអ្នកត្រូវប្រមូលអាហារមកវិញ លោកអ្នកត្រូវបង្ហាញអ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ**កំណត់ត្រា**ស្តីពី៖
  - ◦ បែបបទវិភាគគ្រោះថ្នាក់/ហានិភ័យនៃការប្រមូលអាហាមកវិញដែលបានបំពេញរួច
  - ◦ សំណៅសេចក្តីប្រកាសពីការប្រមូលអាហារមកវិញ

អ្នកឯកទេស



# ការធ្វើស៊ុសស៊ី (sushi) ដោយប្រើបាយមានបន្ថែមជាតិជូរ

**K**

ដឹង

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- ថែមទឹកខ្មេះក្នុងបាយធ្វើឲ្យបាយមានសារធាតុអាស៊ីត។ មេរោគគ្រោះថ្នាក់មិនអាចកើតមានក្នុងបាយដែលមានបន្ថែមជាតិជូរទេ។
- លោកអ្នកអាចធ្វើ sushi ជាមួយបាយដែលមាន ឬគ្មានបន្ថែមជាតិជូរ។ Sushi ដែលធ្វើជាមួយបាយគ្មានបន្ថែមជាតិជូរទុកមិនបានយូរ ដូចជា sushi ដែលធ្វើជាមួយបាយបន្ថែមជាតិជូរនោះទេ។
- លោកអ្នកត្រូវវាស់កម្រិត pH ក្នុងបាយឲ្យបានត្រឹមត្រូវ ដើម្បីកុំឲ្យវាបង្កគ្រោះថ្នាក់ដល់អតិថិជន (ឧទាហរណ៍ ប្រសិនបើបាយមានជាតិអាស៊ីតច្រើនពេក (កម្រិត pH តិចជាង 2.4) វាអាចធ្វើអោយរលាកបំពង់កអ្នកបរិភោគបាន តែបើវាមិនមានជាតិអាស៊ីតគ្រប់គ្រាន់វិញ (ឧទាហរណ៍ មានកម្រិតខ្ពស់ជាង 4.6) មេរោគអាចលូតលាស់)។
- អង្ករសម្រូបមិនអាចបន្ថែមជាតិជូរបានទេ ដោយសារតែសំបករឹងដែលនៅគ្របពីលើគ្រាប់អង្ករវាឃាំងមិនអោយល្បាយទឹកខ្មេះជ្រាបចូលក្នុងគ្រាប់អង្ករបាន។
- មានបទដ្ឋានស្តីពីថាតើ sushi អាចទុកខាងក្រៅកន្លែងគ្រប់គ្រងសីតុណ្ហភាពបានយូរប៉ុណ្ណា។ បទដ្ឋាន 2 ម៉ោង/4 ម៉ោងត្រូវបានកែប្រែសម្រួលសម្រាប់ Sushi ដែលធ្វើពីបាយមានបន្ថែមជាតិជូរ។

**D**

ធ្វើ

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

**ធ្វើបាយដែលគ្មានថែមជាតិជូរដោយប្រើអង្ករសម្រិត ឬសម្រូប**

- ធ្វើឲ្យបាយដាំឆ្អិនត្រជាក់ចុះពីសីតុណ្ហភាព 60 អង្សាសេទៅដល់សីតុណ្ហភាពក្នុងបន្ទប់ ឬ 21 អង្សាសេ (យកសីតុណ្ហភាពណាដែលត្រជាក់ជាង) ក្នុងរយៈពេល 2 ម៉ោង ហើយចុះដល់ 5 អង្សាសេក្នុងរយៈពេល 4 ម៉ោងបន្ទាប់ទៀត។
- កុំរក្សាទុក sushi និង/ឬ onigiri នៅក្នុងសីតុណ្ហភាពខ្ពស់ជាង 5 អង្សាសេក្នុងរយៈពេល 4 ម៉ោង។

អ្នកឯកទេស

# D

ធ្វើ

## ធ្វើបាយមានបន្ថែមជាតិជូរ

- លោកអ្នកអាចបន្ថែមជាតិជូរតែក្នុងបាយដាំពីអង្ករសម្រិតតែប៉ុណ្ណោះ។
- ដាំបាយ និងដាក់ទឹកខ្មេះចូលក្នុងបាយភ្លាម នៅពេលវាឆ្អិន។ លោកអ្នកត្រូវកត់ត្រាចំនួនទឹកខ្មេះដែលលោកអ្នកប្រើ។
- បន្ទាប់ពីថែមជាតិជូរក្នុងបាយហើយ លោកអ្នកត្រូវធ្វើតេស្តកម្រិត pH ដោយលាយទឹកស្អាត 1 ភាគ ជាមួយនឹងបាយមានបន្ថែមជាតិជូរចំនួន 3 ភាគ (ឧទាហរណ៍ ទឹកស្អាត1/4 ពែងលាយជាមួយបាយមានថែមទឹកខ្មេះ 3/4 ពែង)។
- ធ្វើតេស្តកម្រិត pH ក្នុងល្បាយបាយមានបន្ថែមជាតិជូររបស់លោកអ្នក ដោយប្រើវិធីមួយក្នុងចំណោមវិធីខាងក្រោមនេះ (គូសយកវិធីសមស្រប)៖
  - ☐ បន្ទះជ្រលក់វាស់កម្រិត pH
  - ☐ ក្រដាសជ្រលក់វាស់កម្រិត pH
  - ☐ ម៉ាស៊ីនវាស់កម្រិត pH
- ក្រុមបាយនិមួយៗត្រូវមានកម្រិត pH ក្នុងចន្លោះពី 4.6 ទៅ 2.4។
- លោកអ្នកត្រូវវាស់ក្រុមបាយនិមួយៗដែលលោកអ្នកថែមជាតិជូរ រហូតដល់អាចបញ្ជាក់បានថា វិធីដែលលោកអ្នកថែមជាតិជូរមានប្រសិទ្ធិភាពអាចប្រើបានគ្រប់ពេល។ អានប័ណ្ណស្តីពី **'ការបញ្ជាក់ពីវិធីដែលអ្នកប្រើដើម្បីសម្លាប់មេរោគមានប្រសិទ្ធិភាពគ្រប់ពេល'**។
- លោកអ្នកត្រូវធ្វើឲ្យបាយមានថែមជាតិជូរត្រជាក់ចុះ ពី 60 អង្សាសេទៅសីតុណ្ហភាពក្នុងបន្ទប់ ឬ 21 អង្សាសេ (យកសីតុណ្ហភាពណាដែលត្រជាក់ជាង) ក្នុងរយៈពេល 2 ម៉ោង និងដល់ ឬទាបជាង 15 អង្សាសេក្នុងរយៈពេល 4 ម៉ោងបន្ទាប់មកទៀត។
- លោកអ្នកត្រូវរក្សាទុកបាយមានបន្ថែមជាតិជូរក្នុងសីតុណ្ហភាព ចន្លោះពី 5 អង្សាសេ ទៅ 15 អង្សាសេ មិនឲ្យលើសពី 8 ម៉ោងឡើយ ក្រោយពីរយៈពេលនេះទៅ ត្រូវបោះវាចោល។
- លោកអ្នកមិនត្រូវយកបាយនៅសល់ដាក់លាយជាមួយបាយដែលទើបរៀបចំថ្មីទេ។

អ្នកឯកទេស

**D**

ធ្វើ

### ដាក់តាំង sushi ដែលធ្វើពីបាយមានបន្ថែមជាតិជូរប្រកបដោយសុវត្ថិភាព

- លោកអ្នកត្រូវទុក៖
    - ដុំនីហ្គីរី (nigiri) នៅក្នុងចន្លោះសីតុណ្ហភាព 5 អង្សាសេ និង15 អង្សាសេមិនឲ្យលើសពី 8 ម៉ោង បើមិនដូច្នេះទេ ត្រូវបោះវាចោល
    - ដុំណូរី (nori) នៅក្នុងចន្លោះសីតុណ្ហភាព 5 អង្សាសេ និង15 អង្សាសេមិនឲ្យលើសពី 8 ម៉ោង បើមិនដូច្នេះទេ ត្រូវបោះវាចោល។

(រយៈពេលខាងលើរាប់បញ្ចូលពេលដែលបាយមានបន្ថែមជាតិជូរបានទុកនៅក្នុងចន្លោះសីតុណ្ហភាព 5 អង្សាសេ និង15 អង្សាសេ មុននឹងធ្វើ sushi)

**S**

បង្ហាញ

### តើអ្នកត្រូវបង្ហាញអ្វីខ្លះ?

បង្ហាញអ្នកផ្ទៀងផ្ទាត់នូវ៖

- វិធីដែលលោកអ្នកប្រើដើម្បីធ្វើ sushi ប្រកបដោយសុវត្ថិភាពដោយប្រើបាយគ្មានបន្ថែមជាតិជូរ
- វិធីដែលលោកអ្នកប្រើដើម្បីធ្វើ sushi ប្រកបដោយសុវត្ថិភាពដោយប្រើបាយដែលមានបន្ថែមជាតិជូរ៖
    - វិធីដែលលោកអ្នកប្រើដើម្បីធ្វើទឹកខ្មេះ
    - វិធីដែលលោកអ្នកប្រើដើម្បីវាស់កម្រិត pHនៅក្នុងបាយរបស់លោកអ្នក
    - **កំណត់ត្រា** នៃការវាស់កម្រិត pH នៅក្នុងបាយរបស់លោកអ្នក
- វិធីដែលលោកអ្នកប្រើដើម្បីដាក់តាំង sushi ឲ្យមានសុវត្ថិភាព។



# ការធ្វើទាខ្វៃតាមរបៀបចិន

**K**

ដឹង

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- មេរោគគ្រោះថ្នាក់អាចលូតលាស់យ៉ាងឆាប់រហ័សក្នុងតំបន់សីតុណ្ហភាពគ្រោះថ្នាក់។
- ទឹកពុះសម្លាប់មេរោគ។ ទឹកខ្មេះជួយបញ្ឈប់មេរោគកុំឲ្យលូតលាស់នៅពេលយើងកំពុងសម្ងួតទា។
- ការរក្សាទុកកុំឲ្យស្បែកវារហែក អាចជួយបញ្ឈប់មេរោគមិនឲ្យឆ្លងទៅក្នុងនិងលូតលាស់នៅក្នុងសាច់ទា។

**D**

ធ្វើ

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

### ការរៀបចំ

- រំលាយទឹកកកពីទាកកឲ្យបានសព្វកន្លែង។
- ជ្រលក់ទាក្នុងទឹកដាំពុះ ទឹកខ្មេះ និងគ្រឿងផ្សំផ្សេងៗទៀត (ដូចដែលប្រើក្នុងក្បួនធ្វើម្ហូបរបស់លោកអ្នក)។
- ព្យួរទាឲ្យស្ងួតក្នុងកន្លែងត្រជាក់ មិនឲ្យលើសពី 6 ម៉ោង។
- ពិនិត្យសីតុណ្ហភាពទាដោយប្រើឧបករណ៍វាស់សីតុណ្ហភាពនៅពេលចាប់ផ្តើម និងពាក់កណ្តាលពេលនៃដំណើរការសម្ងួត។ សីតុណ្ហភាពខាងក្នុងមិនត្រូវលើសពី 25 អង្សាសេទេ។

### ការចំអិន

- ទាត្រូវតែខ្វៃ។
  (សូមអាន **ប័ណ្ណស្តីពី ‘ការចំអិនបសុបក្សី សាច់ម៉ត់ និងថ្លើមមាន់')**។

អ្នកឯកទេស

D

ធ្វើ

## ការដាក់តាំង/ការទុកដាក់

- ប្រើទំពក់ដើម្បីយួរទា។ មិនត្រូវប៉ះពាល់ទាដោយផ្ទាល់ទេ។
- ធ្វើយ៉ាងណាកុំឲ្យស្បែកទារហែក។ ស្បែកទាមិនត្រូវរហែកពេលដាក់តាំង និងពេលរក្សាទុកឡើយ។ ប្រសិនបើស្បែកទារហែក យើងត្រូវកាប់សាច់វាជាដុំតូចៗ និងរក្សាទុកក្នុងកម្រិតសីតុណ្ហភាពលើសពី 60 អង្សាសេ រហូតដល់ពេលយកទៅបម្រើភ្ញៀវ។
- ដាក់តាំង និងទុកទាតែក្នុងកន្លែងមួយដែលមានខ្យល់ចេញចូលល្អ ត្រជាក់ និងស្ងួតប៉ុណ្ណោះ ដើម្បីការពារកុំឲ្យកើតមានសំណើម (ឧទាហរណ៍ដូចជាទូកញ្ចក់ត្រូវបិទជិត)។
- កុំឲ្យទាប៉ះគ្នា ឬប៉ះផលិតផលផ្សេងៗ នៅពេលដាក់តាំង ឬទុក។ យកទាចេញភ្លាម បើវាប៉ះគ្នា។
- ប្រសិនបើជាចៃដន្យទាបានប៉ះគ្នាយូរ លោកអ្នកត្រូវកាប់វាជាដុំតូចៗ និងកំដៅសាច់ឡើងវិញដល់សីតុណ្ហភាព 75 អង្សាសេ។ បន្ទាប់មកអ្នកអាច៖
    - រក្សាទុកសាច់ទាក្នុងសីតុណ្ហភាព 60 អង្សាសេ ឬខ្ពស់ជាងនេះ រហូតដល់ពេលត្រូវយកវាទៅបម្រើភ្ញៀវ ឬ
    - ធ្វើឲ្យសាច់ទាត្រជាក់ចុះសីតុណ្ហភាពពី 60 អង្សាសេទៅ 21 អង្សាសេក្នុងរយៈពេល 2 ម៉ោង និងចុះពី 21 សង្សាសេទៅ 5 អង្សាសេក្នុងរយៈពេល 4 ម៉ោងបន្ទាប់មកទៀត ហើយនិងទុកនៅក្នុងសីតុណ្ហភាព 4 អង្សាសេ ឬទាបជាងនេះ។
- មិនត្រូវដាក់តាំងទាដែលបានខ្ចប់រួចលើសពី 5 ម៉ោងឡើយ។
- យកចេញ និងបោះចោលទាណាដែលបានដាក់តាំងលើសពី 22 ម៉ោង។

## ការសម្ងួត

លោកអ្នកត្រូវតែ៖

- ដាំទឹកដែលប្រើជ្រលក់ទាឲ្យពុះឡើងវិញ ប្រសិនបើល្បាយទឹកចុះត្រជាក់
- យកទាណាដែលមានសីតុណ្ហភាពលើសពី 25 អង្សាសេ ក្នុងដំណើរការសម្ងួត ទៅដាក់ក្នុងទូក្លាសសេ រហូតដល់តែសីតុណ្ហភាពចុះមកក្រោម 25 អង្សាសេ
- បោះចោលទាណាដែលបានព្យួរឲ្យស្ងួតអស់ពេលយូរជាង 6 ម៉ោង។

S

បង្ហាញ

## តើអ្នកត្រូវបង្ហាញអ្វីខ្លះ?

- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ**កំណត់ត្រា**លាយលក្ខអក្សរនេះ៖
    - សីតុណ្ហភាពទានិមួយៗ នៅពេលព្យួរសម្ងួត និងពេលវេលាចាប់ផ្ដើមសម្ងួត
    - សីតុណ្ហភាពទាពេលសម្ងួតបានពាក់កណ្ដាលនៃដំណើរការសម្ងួត និង អ្វីដែលលោកអ្នកបានធ្វើដើម្បីឲ្យបញ្ចុះសីតុណ្ហភាព បើវាឡើងខ្ពស់ជាង 25 អង្សាសេ
    - ពេលវេលាដែលទាត្រូវបានយកចេញពីកន្លែងសម្ងួតទៅចំអិន។

អ្នកឯកទេស

# ការធ្វើកេបាបសាច់ចៀម (Doner Kebabs)

K

ដឹង

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- សាច់សម្រាប់ធ្វើ doner kebab នៅអាចមានមេរោគដែលអាចឆ្លងដល់អាហារដែលអាចបរិភោគបានភ្លាម។
- លោកអ្នកត្រូវចំអិនសាច់ឲ្យឆ្អិនសព្វដើម្បីសម្លាប់មេរោគ។

D

ធ្វើ

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

### ការរៀបចំចង្ក្រានអាំង kebab

- ប្រើតែសាច់ស្រស់មកពីក្រុមហ៊ុនផ្គត់ផ្គង់ដែលបានការអនុញ្ញាតត្រឹមត្រូវ។
- រក្សាទុកសាច់ក្នុងសីតុណ្ហភាពទាបជាង 5 អង្សាសេ រហូតដល់ពេលត្រូវការយកមកប្រើ។
- រៀបចំចង្ក្រានអាំងសាច់ឲ្យឆ្ងាយពីកន្លែងរក្សាទុកសាឡាដ គ្រឿងជ្រលក់ ទឹកជ្រលក់ និងអាហារឆ្អិន។
- ប្រើតែសាច់ដែលហាន់ស្ដើងៗ នៅពេលរៀបសាច់ដាក់លើចង្ក្រាន។
- ការពារចង្ក្រានអាំងកុំឲ្យប្រឡាក់ធូលី និងការឆ្លងមេរោគ។
- ប្រវែងនៃសាច់ដែលដោតស្នួចមិនត្រូវវែងជាងប្រវែងចង្ក្រានឡើយ។

### ការចំអិន និងការបម្រើ

- Doner kebab ដែលចំអិននៅលើចង្ក្រានបញ្ឈរត្រូវតែចំអិនមុនពេលយកទៅបម្រើភ្ញៀវ។
- ផ្នែកខាងក្រៅនៃ doner kebab ត្រូវតែចំអិនឲ្យសព្វ មុននឹងជៀរសាច់ជាចំណិតស្ដើងៗចេញពីស្រទាប់ខាងក្រៅ។

អ្នកឯកទេស

# D

ធ្វើ

- សាច់ដែលជៀរត្រូវតែប្រមូលយក មុននឹងវាធ្លាក់ចូលថាសត្រង។
- ត្រូវទុកចង្ក្រានអាំងឲ្យឆេះស្មើ មិនត្រូវបន្ថយកំដៅឡើយ នៅពេលអ្នកចាប់ផ្តើមចំអិន doner kebab។
- នៅពេលសាច់ម៉ត់ដោតត្រនួចត្រូវចំអិនពីកក សាច់ជៀរត្រូវតែចំអិនបន្ថែមទៀត នៅលើបន្ទះសំប៉ែត/ចង្ក្រានមុនពេលបរិភោគ។
- សាច់ជៀរណាដែលមិនទាន់ឆ្អិនសព្វត្រូវចំអិនបន្ថែមដោយប្រើថាសក្តៅ ឬចង្ក្រានអាំង។
- ប្រសិនបើ doner kebab ប្រើមិនអស់នៅពេលបិទហាង លោកអ្នកត្រូវ៖
    - ☐ បោះវាចោល ឬ
    - ☐ ជៀរសាច់ត្រង់ណាដែលឆ្អិនចេញពីចង្កាក់អាំង។ ចំអិនសាច់ចំណិតស្តើងៗនោះលើចង្ក្រាន/ថាសក្តៅ។ ធ្វើឲ្យសាច់ជៀរឆ្អិននោះត្រជាក់ គ្រប និងទុកវាក្នុងទូទឹកកក។ ថ្ងៃបន្ទាប់អាចកំដៅឡើងវិញ និងបរិភោគបាន។
- លោកអ្នកត្រូវទុកសាច់ឆៅដែលរុំជាប់ចង្កាក់ឲ្យត្រជាក់ក្នុងសីតុណ្ហភាពធម្មតា ឬ 21 អង្សាសេ (មួយណាក៏បានអោយតែត្រជាក់ជាង) ក្នុងរយៈពេលពេល2 ម៉ោង និងក្រោម 5 អង្សាសេ ក្នុងរយៈពេល 4 ម៉ោងបន្ទាប់មកទៀត។

អ្នកឯកទេស

S

បង្ហាញ

## តើអ្នកត្រូវបង្ហាញអ្វីខ្លះ?

- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ៖
    - កំណត់ត្រា **ជាលាយល័ក្ខអក្សរ** ស្តីពីវិធីដែលលោកអ្នកប្រើដើម្បីចំអិនសាច់សត្វបសុបក្សី និងសាច់ឲ្យមានសុវត្ថិភាពដោយរាប់បញ្ចូលទាំង៖
        - អាហារ
        - កាលបរិច្ឆេទចំអិន
        - សីតុណ្ហភាព អាហារដែលបានចំអិនដល់ និងរយៈពេលដែលអាហារនេះរក្សានៅក្នុងសីតុណ្ហភាពនេះ។
- បង្ហាញ និងរៀបរាប់ប្រាប់អ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ៖
    - វិធីដែលលោកអ្នកប្រើដើម្បីធ្វើអាហារក្តៅឲ្យត្រជាក់បានលឿន
    - វិធីដែលលោកអ្នកប្រើ ដើម្បីដឹងបានថាតើអាហារដែលលោកអ្នកយកមកកំដៅឡើងវិញមានសីតុណ្ហភាពលើសពី 75 អង្សាសេ
    - វិធីដែលលោកអ្នកប្រើដើម្បីរក្សាអាហារឲ្យក្តៅ
    - វិធីដែលលោកអ្នកប្រើដើម្បីវាស់សីតុណ្ហភាព

អ្នកឯកទេស




# ការចំអិនដែលប្រើវិធីចំអិនដោយដាក់អាហារក្នុងស្បោងគ្មានខ្យល់ ហើយចំអិនក្នុងឆ្នាំងមានទឹកទៅតាមសីតុណ្ហភាពត្រូវការ (sous vide)

**K**

ដឹង

## តើលោកអ្នកត្រូវដឹងអ្វីខ្លះ?

- វិធី sous vide ដើម្បីចំអិនអាហារក្នុងសីតុណ្ហភាពដែលស្ថិតក្នុងតំបន់គ្រោះថ្នាក់ (ក្នុងសីតុណ្ហភាព 60 អង្សាសេ ឬក្រោមនេះ)។ អាចចំអិនបែបនេះបានឲ្យមានសុវត្ថិភាព – ប៉ុន្តែទាល់តែយើងគ្រប់គ្រងដំណើរការនេះដោយផ្ចិតផ្ចង់ណាស់។ បើមានកំហុសក្នុងពេលចំអិន វាអាចនាំឲ្យអ្នកបរិភោគឈឺ ឬស្លាប់បាន។
- ការចំអិនអាហារនៅសីតុណ្ហភាពទាបត្រូវចំណាយពេលយូរដើម្បីសម្លាប់មេរោគ។
- ប្រសិនបើសីតុណ្ហភាពសម្រាប់ចំអិនវាទាបពេក គឺយើងមិនអាចសម្លាប់មេរោគនៅក្នុងអាហារបានទេ។
- មេរោគគ្រោះថ្នាក់នឹងអាចរស់បាន ហើយលូតលាស់ ប្រសិនបើលោកអ្នកមិនធ្វើតាមពេលវេលា និងសីតុណ្ហភាពដូចខាងក្រោមទេ។
- ដំណើការនេះមានប្រសិទ្ធិភាពសម្រាប់តែសាច់កាត់ដុំៗនៃបសុបក្សី និងសាច់ក្រហមប៉ុណ្ណោះ។
- ដំណើរការនេះមិនអាចអនុវត្តបានចំពោះសត្វស្លាបទាំងមូល (ឧទាហរណ៍ដូចជាមាន់ ទា) ត្រីទាំងមូល ឬការចំអិននៅក្នុងឡ sous vide ទេ។ ប្រសិនបើអ្នកប្រាថ្នាចង់ចំអិនរបៀបនេះ លោកអ្នកត្រូវធ្វើផែនការត្រួតពិនិត្យពីនាយកដ្ឋានគយ (custom FCP) និងបំពេញការស្រាវជ្រាវវិទ្យាសាស្ត្រដើម្បីបញ្ជាក់ថាលោកអ្នកអាចចំអិនអាហារតាមរបៀបនេះឲ្យមានសុវត្ថិភាព។

អ្នកឯកទេស

D

ធ្វើ

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

- ពេលរៀបចំដុំសាច់ក្រហម និងបសុបក្សីដើម្បីចំអិនតាមវិធី sous vide លោកអ្នកត្រូវទុកអាហារឆៅ និងអាហារអាចបរិភោគបានភ្លាមឲ្យនៅដាច់ដោយឡែកពីគ្នាដោយ៖ (គូសយកវិធីសមស្រប)
    - ☐ មិនប្រើម៉ាស៊ីនខ្ចប់គ្មានខ្យល់សម្រាប់អាហារបរិភោគបានភ្លាម ប្រសិនបើម៉ាស៊ីននោះបានប្រើសម្រាប់ខ្ចប់សាច់ឆៅរួចហើយ ឬ
    - ☐ ការលាងសម្អាត និងធ្វើអនាម័យម៉ាស៊ីនខ្ចប់គ្មានខ្យល់របស់លោកអ្នកក្នុងចន្លោះពេលប្រើវាសម្រាប់អាហារបរិភោគបានភ្លាម
    - កាត់សាច់ក្រហម និងសត្វបសុបក្សីទៅជាដុំស្មើៗគ្នាដើម្បីឲ្យវាមានទំហំទម្ងន់ និងទ្រង់ទ្រាយដូចគ្នា
    - ទុកសាច់ដែលបានខ្ចប់ក្នុងថង់គ្មានខ្យល់ រៀបចំសម្រាប់ចំអិនតាមរបៀប sous vide នៅក្នុងទូទឹកកករហូតដល់ពេលយកវាទៅប្រើប្រាស់។
- ពេលរៀបចំផើងទឹកសម្រាប់ចំអិនរបស់លោកអ្នក លោកអ្នកត្រូវតែ៖
    - ធ្វើតេស្តកែសម្រួលផើងទឹកសម្រាប់ចំអិនអាហារយ៉ាងតិចណាស់មួយខែម្តង
    - ត្រូវធានាថាទឹកអាចហូរទៅមកដោយសេរីជានិច្ច
    - ប្រើតែឧបករណ៍ចំអិនដែលអាចគ្រប់គ្រងសីតុណ្ហភាពបានត្រឹមត្រូវ និងនៅថេរ
    - កំដៅផើងទឹករបស់លោកអ្នកជាមុនឲ្យដល់សីតុណ្ហភាពយ៉ាងតិច 55 អង្សាសេ សម្រាប់ចំអិនសាច់ក្រហម និង 60 អង្សាសេសម្រាប់ចំអិនសាច់បសុបក្សី
    - មានលំហូរទឹកល្អក្នុងផើងទឹកសម្រាប់ចំអិនអាហារ
    - ដូរទឹកក្នុងផើងទឹកសម្រាប់ចំអិនអាហារចេញបន្ទាប់ពីចំអិនសាច់ម្តងៗ។
- នៅពេលចំអិនដោយប្រើវិធី sous vide លោកអ្នកត្រូវតែ៖
    - ជ្រមុជកញ្ចប់ឲ្យលិចទាំងស្រុងក្នុងទឹករាល់ពេល និងត្រូវធានាថាពួកវាបានបែងចែកស្មើគ្នា
    - កត់ត្រាសីតុណ្ហភាពផើងទឹកសម្រាប់ចំអិនអាហារឲ្យបានទៀងទាត់ ឬប្រើម៉ាស៊ីនវាស់និងកត់ត្រាទិន្នន័យដែលមាននៅក្នុងផើងនេះស្រាប់

អ្នកឯកទេស

# D

ធ្វើ

- ជានិច្ចកាល ត្រូវរក្សាសីតុណ្ហភាពផើងទឹកសម្រាប់ចំអិនអហារឲ្យលើសពី 55 អង្សាសេ នៅពេលចំអិនសាច់ក្រហម និង 60 អង្សាសេ នៅពេលចំអិនសាច់បសុបក្សីគ្រប់ពេលទាំងអស់
- សាច់ក្រហម ឬសាច់បសុបក្សីត្រូវមានសីតុណ្ហភាពឡើងស្មើនឹងសីតុណ្ហភាពផើងទឹកសម្រាប់ចំអិនអាហារក្នុងរយៈពេល 4 ម៉ោង ប្រសិនបើវាយូរជាងនេះ យើងត្រូវបោះវាចោល។
- ជានិច្ចកាល យើងត្រូវធ្វើតេស្តសីតុណ្ហភាពសាច់ក្រហម និងបសុបក្សី ដោយប្រើប្រដាប់វាស់សីតុណ្ហភាពមានចុងស្រួចចាក់ចូលផ្នែកដែលក្រាស់បំផុតនៃសាច់ក្រហម ឬបសុបក្សី
- ជានិច្ចកាល យើងត្រូវធ្វើតេស្តសីតុណ្ហភាពសាច់ក្រហម និងបសុបក្សី ដែលនៅកន្លែងដែលត្រជាក់បំផុតក្នុងផើងទឹកសម្រាប់ចំអិនអាហារ
- ពិនិត្យមើលសីតុណ្ហភាពនៅផ្នែកដែលក្រាស់បំផុតនៃសាច់ក្រហម ឬបសុបក្សី៖
    - នៅពេលចាប់ផ្តើមចំអិនក្រុមសាច់ និង
    - មុនពេលការចាប់ផ្តើមនៃរយៈពេលរក្សាសីតុណ្ហភាពតាមការកំណត់ និង
    - នៅចុងបញ្ចប់នៃការចំអិនក្រុមសាច់
- ពិនិត្យមើលថាមាត់ថង់មិនដាច់រហែកក្រោយពេលវាស់សីតុណ្ហភាពរួច
- ជានិច្ចកាល ត្រូវបញ្ចប់ការចំអិនសាច់មួយក្រុមសិន មុនពេលថែមអាហារត្រជាក់ចូលទៅក្នុងផើងទឹកសម្រាប់ចំអិនអាហារ។

អ្នកឯកទេស

# D

ធ្វើ

លោកអ្នកត្រូវប្រើតែបន្សំនៃពេលវេលា និងសីតុណ្ហភាពដូចខាងក្រោមប៉ុណ្ណោះ៖ (ពេលវេលាខាងក្រោមនេះជារយៈពេលរក្សាសីតុណ្ហភាពតាមការកំណត់ វាចាប់ផ្តើមតែនៅពេលអាហាររបស់លោកអ្នកឡើងដល់សីតុណ្ហភាពកំណត់)

## សីតុណ្ហភាពខាងក្នុង និងរយៈពេលរក្សាសីតុណ្ហភាព

| សីតុណ្ហភាពខាងក្នុងអាហារ អង្សាសេ | ចំអិន-បម្រើ: បម្រើភ្លាម ឬក៏ក្នុងអំឡុងពេល 2 ថ្ងៃដែលបានចំអិនរួច | | ចំអិន-ក្លាសសេ: បម្រើភ្លាម ឬក៏ក្នុងអំឡុងពេល 5 ថ្ងៃដែលបានចំអិនរួច |
|---|---|---|---|
| | សាច់ទាំងអស់លើកលែងតែរយៈពេលចំអិនសាច់បសុបក្សី (នាទី/ម៉ោង) | រយៈពេលសម្រាប់ចំអិនសាច់បសុបក្សី (នាទី/ម៉ោង) | រយៈពេលសម្រាប់ចំអិនសាច់ក្រហម និងសាច់បសុបក្សី (នាទី/ម៉ោង) |
| តំបន់សីតុណ្ហភាពគ្រោះថ្នាក់ * 55 | 420 នាទី / 7 ម៉ោង | សាច់បសុបក្សីមិនត្រូវចំអិនតាមវិធី sous vide ក្នុងសីតុណ្ហភាពទាបជាង 60អង្សាសេឡើយ | ប្រសិនបើទុកសាច់ក្រហមចំអិនដោយវិធី sous vide ឬសាច់បសុបក្សីយូរជាង 2 ថ្ងៃ **សូមកុំ**ចំអិនក្នុងសីតុណ្ហភាពដែលទាបជាង 60អង្សាសេ |
| 56 | 296 នាទី / 4 ម៉ោង 56 នាទី | | |
| 57 | 208 នាទី / 3 ម៉ោង 28 នាទី | | |
| 58 | 147 នាទី / 2 ម៉ោង 27 នាទី | | |
| 59 | 104 នាទី / 1 ម៉ោង 44 នាទី | | |
| 60 | 73 នាទី / 1 ម៉ោង 13 នាទី | 56 នាទី | 91 នាទី / 1 ម៉ោង 31នាទី |
| 61 | 52 នាទី | 40 នាទី | 63 នាទី / 1 ម៉ោង 3 នាទី |
| 62 | 36 នាទី | 29 នាទី | 44 នាទី |
| 63 | 26 នាទី | 21 នាទី | 30 នាទី |
| 64 | 18 នាទី | 15 នាទី | 21 នាទី |
| 65 | 13 នាទី | 11 នាទី | 15 នាទី |
| 66 | 9 នាទី | 8 នាទី | 10 នាទី |
| 67 | 7 នាទី | 6 នាទី | 7 នាទី |

*រយៈពេលអប្បបរមានៅពេលដែលផលិតផលបានដល់សីតុណ្ហភាពនេះ

អ្នកឯកទេស

D

ធ្វើ

- នៅពេលដែលសាច់ក្រហម និងសាច់បសុបក្សីបានឆ្អិន លោកអ្នកត្រូវរក្សាទុកវាក្នុងថង់រហូតដល់ពេលត្រូវប្រើប្រាស់វា ឬក៏ ៖
    - បម្រើវាផ្ទាល់ពីក្នុងថង់
    - យកវាចេញពីថង់ ដុតកំដៅវា (ឬចំអិនវាតាមវិធីផ្សេងមួយចំនួនទៀត) និងបម្រើវាភ្លាម
    - រក្សាទុកវាក្នុងថង់ ធ្វើវាឲ្យចុះត្រជាក់លឿនដោយអនុវត្តតាមប័ណ្ណស្តីពី 'ការធ្វើឲ្យអាហារចំអិនថ្មីៗឲ្យចុះត្រជាក់' និងទុកវាក្រោមសីតុណ្ហភាព 5 អង្សាសេរហូតដល់ 2 ថ្ងៃ (តែក្នុងករណីដែលលោកអ្នកប្រើវិធីចំអិន-បម្រើប៉ុណ្ណោះ)
    - រក្សាទុកវាក្នុងថង់ ធ្វើឲ្យវាត្រជាក់ចុះលឿន និងរក្សាទុកក្រោមសីតុណ្ហភាព 5 អង្សាសេរហូតដល់ 5 ថ្ងៃ (តែក្នុងករណីដែលលោកអ្នកប្រើវិធីចំអិន-ក្លាសសេ)។
- លោកអ្នកត្រូវបិទស្លាកលើអាហារដែលបានចំអិនរួចដោយមានកាលបរិច្ឆេទ និងពេលវេលាដែលបានចំអិន ប្រភេទអាហារ ថាវាចំអិនដោយប្រើវិធីចំអិន-បម្រើ ឬចំអិន-ក្លាសសេ ហើយនិងកាលបរិច្ឆេទបោះចោល។

**ការបញ្ជាក់ពីវិធីរបស់លោកអ្នក**

- ប្រសិនបើលោកអ្នកមិនចង់វាស់សីតុណ្ហភាពគ្រប់ក្រុមសាច់ដែលលោកអ្នកចំអិនទេ លោកអ្នកត្រូវបញ្ជាក់ឲ្យបានថា វិធីសាស្ត្រចំអិនរបស់លោកអ្នកមានប្រសិទ្ធិភាពគ្រប់ពេល។ អានប័ណ្ណស្តីពី 'ការបញ្ជាក់ពីវិធីដែលអ្នកប្រើដើម្បីសម្រាប់សត្វល្អិតមានប្រសិទ្ធិភាពគ្រប់ពេល'។

S

បង្ហាញ

## តើអ្នកត្រូវបង្ហាញអ្វីខ្លះ?

- បង្ហាញអ្នកផ្ទៀងផ្ទាត់របស់លោកអ្នកនូវ៖
    - វិធីដែលលោកអ្នកធ្វើតេស្តកែសម្រួលផើងទឹកសម្រាប់ចំអិនអាហារយ៉ាងតិចណាស់មួយខែម្តង
    - **កំណត់ត្រា** ស្តីពី៖
        - សីតុណ្ហភាពផើងទឹកសម្រាប់ចំអិនអាហារ មុនពេលបន្ថែមអាហារចូលទៅក្នុងទឹក
        - រយៈពេលត្រូវការសម្រាប់អាហារឡើងដល់សីតុណ្ហភាពខាងក្នុងដែលបានជ្រើសរើសរួច
        - ថិរវេលានៃរយៈពេលរក្សាសីតុណ្ហភាពតាមការកំណត់ នៅពេលដែលអាហារឡើងដល់សីតុណ្ហភាពអាហារដែលបានជ្រើសរើសរួច
        - សីតុណ្ហភាពខាងក្នុងអាហារនៅពេលចាប់ផ្តើម និងចុងបញ្ចប់នៃរយៈពេលរក្សាសីតុណ្ហភាពតាមការកំណត់
        - រយៈពេលចុះត្រជាក់ (សម្រាប់ផលិតផលត្រជាក់ និងទុកសម្រាប់លក់លើកក្រោយ)។

អ្នកឯកទេស



# ការរៀបចំសាច់ក្រហមសម្រាប់កិនឲ្យម៉ត់ និងការបម្រើសាច់-ស្ទើរឆ្អិន ឬឆៅ

**K**

ដឹង

## តើអ្នកត្រូវដឹងអ្វីខ្លះ?

- ដំណើរការនេះប្រើបានតែចំពោះសាច់ក្រហម – សាច់គោ សាច់ចៀម សាច់ក្តាន់ទេ។ ដំណើរការនេះមិនអាចប្រើបានចំពោះសាច់ជ្រូក សាច់មាន់ សាច់ទា ឬថ្លើមទេ។
- ដំណើរការនេះត្រូវអនុវត្តតាម តែនៅពេលដែលអ្នកជ្រើសរើសបម្រើសាច់ក្រហមស្ទើរឆ្អិន ឬឆៅប៉ុណ្ណោះទេ។
- ផ្ទៃខាងក្រៅនៃសាច់ដែលកាត់ជាដុំមានមេរោគ។ ការកិនសាច់ឲ្យម៉ត់ពង្រាយមេរោគពីផ្ទៃខាងក្រៅនៃសាច់ទៅពេញសាច់កិនទាំងអស់។
- មានមេរោគដែលបង្កគ្រោះថ្នាក់តែមួយចំនួនតូចប៉ុណ្ណោះអាចធ្វើឲ្យមនុស្សឈឺបាន។
- វិធីតែមួយប៉ុណ្ណោះដែលធ្វើឲ្យសាច់មានសុវត្ថិភាពដើម្បីបម្រើនៅស្ទើរឆ្អិន ឬឆៅ គឺសម្លាប់មេរោគនៅផ្ទៃខាងក្រៅនៃសាច់ នៅមុនពេលកិន។
- មានវិធី 3យ៉ាងដើម្បីកាត់បន្ថយចំនួនមេរោគនៅខាងក្រៅសាច់– កម្លោចវា ស្រុសវា ឬធ្វើអនាម័យវា។
- មេរោគអាចលាក់ខ្លួននៅក្រោមក្លែប ក្នុងប្រហោង និងនៅចន្លោះផ្ទេរសាច់ដែលកាត់ជាដុំ។ ធ្វើឲ្យផ្នែកខាងក្រៅសាច់រាបស្មើដោយកាត់ចេញនូវផ្នែកដែលធ្វើឲ្យយើងមិនអាចកម្លោច ស្រុស ឬប្រើល្បាយរាវសម្រាប់ធ្វើអនាម័យសាច់បាន និងមិនឲ្យយើងអាចសម្លាប់មេរោគបាន។
- គ្រឿងផ្សំបន្ថែមដែលប្រើប្រាស់ជាមួយសាច់ក្រហមដែលមានអនាម័យល្អ (ឧទាហរណ៍ដូចជាការដាក់គ្រឿងគ្រៅ សារធាតុលាយផ្សេងៗ ។ល។ ) ត្រូវតែរក្សាឲ្យមានសុវត្ថិភាព និងភាពសមស្របសម្រាប់បរិភោគ។
- អ្នកមិនចាំបាច់អនុវត្តតាមបទដ្ឋានស្តីពីការចម្អិនសាច់ក្រហមដែលកិនម៉ត់នៅក្នុងប័ណ្ណស្តីពី **‘ការចម្អិនសាច់បសុបក្សី សាច់កិនម៉ត់ និងថ្លើមមាន់’** ប្រសិនបើអ្នកអនុវត្តតាមនីតិវិធីនេះ។

D

ធ្វើ

## តើអ្នកត្រូវធ្វើអ្វីខ្លះ?

- អ្នកត្រូវតែជ្រើសរើសវិធីមួយក្នុងចំណោមវិធីខាងក្រោម៖
  - កម្លោច ឬ
  - ស្រុស ឬ
  - ការប្រើប្រាស់ល្បាយរាវសម្រាប់ធ្វើអនាម័យសាច់
- អ្នកគ្រាន់តែត្រូវប្រើសាច់ដែលកាត់ជាដុំដែលមានផ្ទៃខាងក្រៅរាបស្មើ។ (ឧទាហរណ៍ សាច់កាត់លេខមួយដូចជាសាច់ចំឡក សាច់ភ្លៅផ្នែកខាងមុខ សាច់ពោះក្រាស់ សាច់ភ្លៅផ្នែកកណ្ដាល សាច់ភ្លៅផ្នែកខាងក្រោយ)។
- អ្នកត្រូវតែ៖
  - តម្រឹមថ្នេរ ក្លែបធំៗ និង/ឬប្រហោងនៅមុនពេលកម្លោច ស្រុស ឬធ្វើអនាម័យដើម្បីឲ្យអាចសម្លាប់មេរោគនៅលើផ្ទៃខាងក្រៅនៃសាច់បានស្មើ ឬ
  - កាត់ ឬតម្រឹមសាច់ជាដុំតូចៗ (គឺថាគ្មានក្លែប ឬប្រហោង) នៅមុនពេលកម្លោច ស្រុស ឬធ្វើអនាម័យដើម្បីឲ្យអាចសម្លាប់មេរោគនៅលើផ្ទៃខាងក្រៅនៃសាច់បានស្មើ។

## ការកម្លោចសាច់

- នៅពេលកម្លោចសាច់ ផ្ទៃខាងក្រៅសាច់ទាំងអស់ (ដោយរាប់បញ្ចូលទាំងស្រទាប់ខ្លាញ់) ត្រូវតែដាក់ឲ្យប៉ះនឹងចានក្ដៅដែលមានខ្លាញ់ ចង្ក្រាន ឬឆ្នាំង។

## ការស្រុសសាច់

- នៅពេលស្រុសសាច់ អ្នកអាចជ្រើសរើសស្រុសសាច់ដោយមិនបាច់ខ្ចប់ ឬក៏ខ្ចប់ក្នុងស្បោងបិទខ្យល់ជិត។ ប្រសិនបើអ្នកប្រើស្បោងបិទខ្យល់ជិត ផ្ទៃខាងក្រៅនៃសាច់ត្រូវតែដាក់ឲ្យប៉ះផ្ទាល់ទៅនឹងស្បោង។
- ដាក់ទឹក ឬទឹកស៊ុបពុះគ្រុកៗឲ្យលិចសាច់ទាំងស្រុង ឲ្យបានយ៉ាងហោចណាស់៖
  - 30 វិនាទី ប្រសិនបើសាច់មិនបានដាក់ក្នុងស្បោងទេ ឬ
  - 60 វិនាទី ប្រសិនបើសាច់ដាក់ក្នុងស្បោងបិទខ្យល់ជិត។

## សម្រាប់កម្លោចផង និងស្រុសផង

- អ្នកត្រូវធ្វើឲ្យសាច់កម្លោច ឬស្រុសត្រជាក់លឿនដោយ៖
  - ដាក់សាច់នៅក្នុងទឹកកក ឬ
  - ដាក់សាច់នៅក្នុងទូទឹកកក ឬ
  - ដាក់សាច់នៅក្នុងទូបង្កក

អ្នកឯកទេស

D

ធ្វើ

## ការប្រើប្រាស់ល្បាយរាវសម្រាប់ធ្វើអនាម័យសាច់

- នៅពេលអនុវត្តវិធីអនាម័យសាច់ អ្នកត្រូវតែប្រើជាតិគីមីមួយប្រភេទក្នុងចំណោមនៃជាតិគីមីដូចខាងក្រោម៖ (សូមគូសសញ្ញា លើជាតិគីមីដែលសមស្រប)
  - ☐ អាស៊ីតឡាក់ទិច
  - ☐ អាស៊ីតពែអុកស៊ីអាសេទិច (POAA)
- អ្នកមិនត្រូវប្រើកំហាប់នៃល្បាយរាវសម្រាប់ធ្វើអនាម័យសាច់តិចជាង ឬច្រើនជាងទេ។
- ដុំសាច់ទាំងមូលត្រូវដាក់ឲ្យលិចក្នុងល្បាយរាវសម្រាប់ធ្វើអនាម័យសាច់ជានិច្ច។ ផ្ទៃខាងក្រៅសាច់ទាំងអស់ត្រូវដាក់ឲ្យប៉ះផ្ទាល់នឹងល្បាយរាវសម្រាប់ធ្វើអនាម័យសាច់។
- អ្នកត្រូវប្រើល្បាយរាវសម្រាប់ធ្វើអនាម័យសាច់ថ្មីសម្រាប់ដុំសាច់នីមួយៗដែលអ្នកធ្វើអនាម័យ។

## ការប្រើប្រាស់អាស៊ីតឡាក់ទិច

- អ្នកត្រូវប្រើល្បាយរាវអាស៊ីតឡាក់ទិចក្នុងចន្លោះ 2—5%។
- អ្នកត្រូវជ្រលក់ដុំសាច់ទាំងមូលនៅក្នុងល្បាយរាវអាស៊ីតឡាក់ទិចឲ្យបាន 9 វិនាទី។ អ្នកត្រូវប្រើល្បាយរាវនៅក្នុងសីតុណ្ហភាព 55 អង្សាសេ។

## ការប្រើប្រាស់អាស៊ីតពែអុកស៊ីអាសេទិច (POAA)

- អ្នកត្រូវប្រើកំហាប់អាស៊ីតពែអុកស៊ីអាសេទិចរវាង150—220 ផ្នែកក្នុងមួយលាន។
- កំហាប់អាស៊ីតពែអុកស៊ីត អ៊ីតដ្រូសែនត្រូវមាន 75 ផ្នែកក្នុងមួយលាន ឬតិចជាង (សូមកត់សម្គាល់: ប្រសិនប្រើកំហាប់ដែលលាយរួច អ្នកមិនត្រូវការធ្វើដូច្នេះទេ)។
- អ្នកត្រូវជ្រលក់ដុំសាច់ទាំងមូលនៅក្នុងល្បាយរាវឲ្យបាន 10—15 វិនាទី (មិនឲ្យលើសពី 30 វិនាទី) នៅក្នុងសីតុណ្ហភាពក្នុងបន្ទប់។

## សម្រាប់គ្រប់វិធីទាំងអស់

- សាច់ទាំងអស់ដែលបានកម្លោច ស្រុស ឬធ្វើអនាម័យហើយត្រូវតែប្រើក្នុងរយៈពេលយ៉ាងច្រើនបំផុត 48 ម៉ោង។
- សាច់ពូតជាដុំមូលសំប៉ែតត្រូវតែប្រើក្នុងរយៈពេល 24 ម៉ោង ឬក៏បង្កកវាភ្លាមសម្រាប់ប្រើលើកក្រោយ។

D

ធ្វើ

- សាច់ពូតជាដុំមូលសំប៉ែតដែលរលាយទឹកកកហើយត្រូវតែប្រើក្នុងរយៈពេល 24 ម៉ោង។
- សាច់ដែលបានកម្លោច ស្រុស ឬធ្វើអនាម័យហើយត្រូវរក្សាទុកក្នុងសីតុណ្ហភាព 5 អង្សាសេ ឬក៏ទាបជាង នៅពេលមិនបានប្រើប្រាស់ ឬចាត់ចែងវា។

S

បង្ហាញ

## តើអ្នកត្រូវបង្ហាញអ្វីខ្លះ?

បង្ហាញ ឬរៀបរាប់ប្រាប់អ្នកផ្ទៀងផ្ទាត់របស់អ្នកនូវ៖

- របៀបដែលអ្នកអនុវត្តវិធីដែលអ្នកជ្រើសរើសឲ្យបានត្រឹមត្រូវគ្រប់ពេល
- របៀបដែលអ្នកសម្លាប់មេរោគនៅលើផ្ទៃខាងក្រៅនៃសាច់ដែលកាត់ជាដុំ
- របៀបដែលអ្នកចាត់ចែងសាច់ បន្ទាប់ពីបានកម្លោច ស្រុស ឬធ្វើអនាម័យរួចហើយ
- របៀបដែលអ្នកធានាថាសាច់ដែលបានកម្លោច ស្រុស ឬធ្វើអនាម័យរួចហើយត្រូវតែប្រើក្នុងរយៈពេល 48 ម៉ោង
- របៀបដែលអ្នកកិនសាច់ក្រហមឲ្យម៉ត់ប្រកបដោយសុវត្ថិភាព ហើយត្រូវតែប្រើសាច់ពូតជាដុំមូលសំប៉ែតក្នុងរយៈពេល 24 ម៉ោង
- របៀបដែលអ្នកកិនសាច់ក្រហមឲ្យម៉ត់ប្រកបដោយសុវត្ថិភាព

## វិធីប្រើប្រាស់ល្បាយរាវសម្រាប់ធ្វើអនាម័យសាច់

- បង្ហាញ ឬរៀបរាប់ប្រាប់អ្នកផ្ទៀងផ្ទាត់របស់អ្នកនូវ៖
  - របៀបដែលអ្នករៀបចំលាយល្បាយរាវសម្រាប់ធ្វើអនាម័យសាច់
  - របៀបដែលអ្នកដឹងថាអ្នកបានប្រើ៖
    - ជាតិគីមីត្រឹមត្រូវ និង
    - កំហាប់ត្រឹមត្រូវ និង
    - សីតុណ្ហភាពត្រឹមត្រូវ និង
    - រយៈពេលសម្លាប់មេរោគ។